# ឆ្នាំ ខ


| | |
|---|---|
| រដូវរង់ចាំ ឬ រដូវរអបអរសាទរ ព្រះគ្រីស្តយាងមក | ២ |
| រដូវបុណ្យព្រះយេស៊ូប្រសូត | ៨ |
| រដូវសែសិបថ្ងៃ ឬ រដូវរអប់រំពិសេស | ២០ |
| សប្តាហ៍ពិសិដ្ឋ | ២៨ |
| រដូវបុណ្យចម្លង | ៥១ |
| រដូវធម្មតា | ៦៣ |

# ឆ្នាំ ២

# រដូវរង់ចាំ

# ឬ

# រដូវអបអរសាទរ ព្រះគ្រីស្ទយាងមក

# ថ្ងៃអាទិត្យទី ១ ក្នុងរដូវរង់ចាំ ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម ទន ៨៥,៨**

**អាលេលូយ៉ា! អាលេលូយ៉ា!** ឱព្រះអម្ចាស់អើយ! សូមសម្តែងព្រះហឫទ័យមេត្តាករុណា ចំពោះយើងខ្ញុំ! សូមយាងមកសង្គ្រោះយើងខ្ញុំផង! **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** **១៣,៣៣-៣៧**

ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ក្រុមសាវ័ក អំពីដំណើរនិវត្តន៍របស់ព្រះអង្គដូចតទៅ៖ [៣៣]«អ្នក
រាល់គ្នាមិនដឹងថា ពេលណាជាពេលកំណត់ទេ ។ ដូច្នេះ ចូរប្រុងប្រយ័ត្នប្រុងស្មារតីឲ្យមែនទែន! [៣៤]ដ្បិត
ពេលកំណត់នោះ ប្រៀបបាននឹងបុរសម្នាក់ដែលចេញដំណើរពីផ្ទះទៅ ។ គាត់ទុកឲ្យពួកអ្នកបម្រើមើល
ខុសត្រូវក្នុងផ្ទះ ដោយចែកមុខងារឲ្យរៀងៗខ្លួន ព្រមទាំងបង្គាប់ឲ្យអ្នកយាមផ្ទះប្រុងស្មារតីផង ។
[៣៥]អ្នករាល់គ្នាក៏ត្រូវប្រុងស្មារតីដូច្នោះដែរ ដ្បិតអ្នករាល់គ្នាពុំដឹងថា ម្ចាស់ផ្ទះនឹងវិលមកវិញនៅពេលណា
ឡើយ មិនដឹងជាយប់ពាក់កណ្តាលអធ្រាត្រ ពេលមាន់រងាវ ឬពេលព្រលឹមទេ [៣៦]ក្រែងលោកត្រឡប់មក
វិញដោយមិនបានឲ្យដំណឹងមុន ហើយឃើញអ្នករាល់គ្នាកំពុងតែដេកលក់ ។ [៣៧]ពាក្យដែលខ្ញុំនិយាយ
ប្រាប់អ្នករាល់គ្នានេះ ខ្ញុំក៏ចង់និយាយប្រាប់អ្នកឯទៀតៗគ្រប់គ្នាដែរ គឺថា ចូរប្រុងស្មារតី!» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២ ក្នុងរដូវរង់ចាំ ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** លក ៣,៤.៦

**អាលេលូយ៉ា! អាលេលូយ៉ា!** ចូររៀបចំផ្លូវរបស់ព្រះអម្ចាស់ ចូរតម្រង់ផ្លូវថ្វាយព្រះអង្គ នោះមនុស្សទាំងអស់នឹងឃើញការសង្គ្រោះរបស់ព្រះជាម្ចាស់ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** ១,១-៨

១ដំណឹងល្អអំពីព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រារបស់ព្រះជាម្ចាស់ចាប់ផ្ដើមដូចតទៅ៖ ២ក្នុងគម្ពីរព្យាការី
អេសាយ មានចែងទុកមកថា៖ «យើងចាត់ទូតយើងឲ្យទៅមុនព្រះអង្គ ដើម្បីរៀបចំផ្លូវថ្វាយព្រះអង្គ ។
៣មានសំឡេងបុរសម្នាក់ ស្រែកនៅវាលរហោស្ថានថា៖ "ចូររៀបចំផ្លូវរបស់ព្រះអម្ចាស់ ចូរតម្រង់ផ្លូវ
ថ្វាយព្រះអង្គ"» ។

៤ពេលនោះ លោកយ៉ូហានជាអ្នកធ្វើពិធីជ្រមុជទឹក មកដល់នៅវាលរហោស្ថានស្របតាមអត្ថបទ
គម្ពីរនេះមែន ។ លោកប្រកាសឲ្យមនុស្សម្នាប្រែចិត្តគំនិត ដោយទទួលពិធីជ្រមុជទឹក ដើម្បីព្រះជាម្ចាស់
លើកលែងទោសឲ្យរួចពីបាប ។ ៥អ្នកស្រុកយូដាទាំងអស់ និងអ្នកក្រុងយេរូសាឡឹមទាំងមូល នាំគ្នាចេញ
ទៅរកលោក ។ គេទទួលសារភាពអំពើបាបរបស់ខ្លួន ហើយលោកក៏ធ្វើពិធីជ្រមុជទឹកឲ្យគេ ក្នុងទន្លេ
យ័រដាន់ ។ ៦លោកយ៉ូហានស្លៀកសម្លៀកបំពាក់ធ្វើពីរោមអូដ្ឋ ពាក់ខ្សែក្រវាត់ធ្វើពីស្បែក ហើយ
បរិភោគកណ្ដូប និងទឹកឃ្មុំ ។ ៧លោកប្រកាសប្រាប់បណ្ដាជនថា៖ «លោកដែលមានកម្លាំងខ្លាំងជាងខ្ញុំ
នឹងមកតាមក្រោយខ្ញុំ ។ ខ្ញុំមានឋានៈទាបណាស់ សូម្បីតែឱនស្រាយខ្សែស្បែកជើងជូនលោក ក៏មិនសម
នឹងឋានៈដ៏ខ្ពង់ខ្ពស់របស់លោកផង ។ ៨ខ្ញុំបានធ្វើពិធីជ្រមុជឲ្យអ្នករាល់គ្នាក្នុងទឹក រីឯលោកវិញ លោកនឹង
ធ្វើពិធីជ្រមុជឲ្យអ្នករាល់គ្នា ក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃទី ៨ ខែធ្នូ៖ បុណ្យគោរពព្រះនាងព្រហ្មចារិនីម៉ារីមិនជំពាក់បាប

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម លក ១,២៨

**អាលេលូយ៉ា! អាលេលូយ៉ា!** បពិត្រព្រះនាងព្រហ្មចារិនីម៉ារី! សូមនាងមានអំណរសប្បាយ!
ព្រះអម្ចាស់គង់ជាមួយនាង! ព្រះអង្គប្រទានពរមកនាងលើសស្ត្រីទាំងឡាយ ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត លូកា** ១,២៦-២៨

២៦ព្រះជាម្ចាស់បានចាត់ទេវទូតកាព្រីអែល ឲ្យទៅភូមិណាសារ៉ែត ក្នុងស្រុកកាលីឡេ ២៧ដើម្បីជួបនឹង
ស្ត្រីក្រមុំព្រហ្មចារីម្នាក់ ជាគូដណ្ដឹងរបស់កំឡោះម្នាក់ ឈ្មោះយ៉ូសែប ដែលត្រូវជាញាតិវង្សព្រះបាទ
ដាវីឌ ។ ស្ត្រីក្រមុំនោះឈ្មោះនាងម៉ារី ។ ២៨ទេវទូតចូលទៅក្នុងផ្ទះនាងម៉ារី ហើយពោលទៅកាន់នាង
ថា៖ «នាងជាទីគាប់ព្រះហឫទ័យព្រះអម្ចាស់អើយ! ចូរមានអំណរសប្បាយឡើង! ព្រះអង្គគង់ជាមួយ
នាង» ។ ២៩ពេលឮពាក្យនេះ នាងម៉ារីរន្ធត់យ៉ាងខ្លាំង ហើយនឹករិះគិតថា តើពាក្យជម្រាបសួរនេះមាន
ន័យដូចម្ដេច ។ ៣០ទេវទូតពោលទៅកាន់នាងថា៖ «កុំខ្លាចអី ម៉ារីអើយ! ដ្បិតព្រះជាម្ចាស់គាប់ព្រះហឫ
ទ័យនឹងនាងហើយ ។ ៣១នាងនឹងមានគភ៌ ហើយសម្រាលបានបុត្រមួយ ដែលនាងត្រូវថ្វាយព្រះនាមថា
"យេស៊ូ" ។ ៣២បុត្រនោះនឹងមានឋានៈដ៏ប្រសើរឧត្ដម ហើយគេនឹងថ្វាយព្រះនាមថា "ព្រះបុត្រានៃព្រះ
ដ៏ខ្ពង់ខ្ពស់បំផុត" ។ ព្រះជាម្ចាស់នឹងតាំងបុត្រនោះឲ្យគ្រងរាជ្យលើបល្ល័ង្ករបស់ព្រះបាទដាវីឌ ជាព្រះ
អយ្យកោរបស់ព្រះអង្គ ៣៣ទ្រង់នឹងគ្រងរាជ្យលើប្រជារាស្ត្រអ៊ីស្រាអែលអស់កល្បជានិច្ច ហើយរាជ្យរបស់
ព្រះអង្គនឹងនៅស្ថិតស្ថេរ ឥតមានទីបញ្ចប់ឡើយ» ។ ៣៤នាងម៉ារីសួរទៅទេវទូតថា៖ «តើធ្វើដូចម្ដេចនឹង
ឲ្យការនេះកើតឡើងបាន បើនាងខ្ញុំមិនរួមរស់ជាមួយបុរសណាផងដូច្នេះ?» ។ ៣៥ទេវទូតឆ្លើយទៅនាង
វិញថា៖ «ព្រះវិញ្ញាណដ៏វិសុទ្ធនឹងយាងមកសណ្ឋិតលើនាង គឺឫទ្ធានុភាពរបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុតនឹង
គ្របបាំងនាង ។ ហេតុនេះ គេនឹងថ្វាយព្រះនាមដល់បុត្រដ៏វិសុទ្ធ ដែលត្រូវប្រសូតមកនោះថា "ព្រះ
បុត្រារបស់ព្រះជាម្ចាស់" ។ ៣៦ម្យ៉ាងទៀត នាងអេលីសាបិតជាញាតិរបស់នាង មានផ្ទៃពោះប្រាំមួយខែ
ហើយ ថ្វីដ្បិតតែគាត់មានវ័យចាស់ជែមទាំងជាស្ត្រីអារទៀតផងក៏ដោយ ៣៧ព្រោះគ្មានការអ្វីដែលព្រះជា
ម្ចាស់ធ្វើមិនកើតនោះឡើយ» ។ ៣៨នាងម៉ារីពោលទៅទេវទូតថា៖ «នាងខ្ញុំជាអ្នកបម្រើរបស់ព្រះអម្ចាស់
សូមឲ្យបានសម្រេចតាមពាក្យរបស់លោកចុះ!» ។ បន្ទាប់មក ទេវទូតចាកចេញពីនាងទៅ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៣ ក្នុងរដូវរង់ចាំ ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម លក ២,៧៦

**អាលេលូយ៉ា! អាលេលូយ៉ា!** លោកយ៉ូហានជាព្យាការីរបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុត លោកដើរខាងមុខ ដើម្បីរៀបចំផ្លូវថ្វាយព្រះអម្ចាស់ និងធ្វើជាសាក្សីថ្វាយព្រះពន្លឺ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** ១,៦-៨.១៩-២៨

[៦]ព្រះជាម្ចាស់បានចាត់បុរសម្នាក់ឈ្មោះ យ៉ូហាន ឲ្យមក ។ [៧]លោកមកធ្វើជាបន្ទាល់ផ្ដល់សក្ខីភាពអំពី
ពន្លឺ ដើម្បីឲ្យមនុស្សទាំងអស់ជឿដោយសារលោក ។ [៨]លោកយ៉ូហានមិនមែនជាពន្លឺទេ គឺលោកគ្រាន់តែ
មកផ្ដល់សក្ខីភាពអំពីពន្លឺប៉ុណ្ណោះ ។

សក្ខីភាពរបស់លោកយ៉ូហានមានដូចតទៅ៖ [១៩]ជនជាតិយូដាចាត់ពួកបូជាចារ្យ និងពួកលេវីពីក្រុង
យេរូសាឡឹម ឲ្យទៅជួបលោកយ៉ូហាន ដើម្បីសួរថា៖ «លោកជានរណា?» ។ [២០]លោកយ៉ូហានប្រកាស
ប្រាប់គេ ដោយពុំលាក់លៀមអ្វីឡើយ គឺលោកបានបញ្ជាក់យ៉ាងច្បាស់ថា៖ «ខ្ញុំមិនមែនជាព្រះគ្រីស្ដទេ»
។ [២១]ពួកគេសួរលោកថា៖ «ដូច្នេះតើលោកជានរណា? តើលោកជាព្យាការីអេលីឬ?» ។ លោក
ឆ្លើយថា៖ «ទេ! មិនមែនទេ!» ។ គេក៏សួរទៀតថា៖ «តើលោកជាព្យាការីដែលយើងរង់ចាំនោះ
ឬ?» ។ លោកឆ្លើយថា៖ «មិនមែនទេ!» ។ [២២]គេសួរលោកទៀតថា៖ «តើលោកជានរណា? ដ្បិត
យើងខ្ញុំចង់បានចម្លើយ យកទៅជម្រាបអស់លោកដែលចាត់យើងខ្ញុំឲ្យមក ។ តើលោកថា ខ្លួនលោកជា
នរណា!» ។ [២៣]លោកយ៉ូហានមានប្រសាសន៍ថា៖ «ខ្ញុំជាសំឡេងបុរសម្នាក់ដែលស្រែកនៅវាលរហោ
ស្ថានថា៖ "ចូរតម្រង់ផ្លូវថ្វាយព្រះអម្ចាស់" ត្រូវនឹងសេចក្ដី ដែលព្យាការីអេសាយបានថ្លែងទុកមក» ។
[២៤]អ្នកដែលគេចាត់ឲ្យមកនោះ ជាពួកខាងគណៈផារីស៊ី ។ [២៥]គេសួរលោកយ៉ូហានទៀតថា៖ «បើលោក
មិនមែនជាព្រះគ្រីស្ដ មិនមែនជាព្យាការីអេលី ហើយក៏មិនមែនជាព្យាការីដែលយើងរង់ចាំនោះទេ ហេតុ
ដូចម្ដេច បានជាលោកធ្វើពិធីជ្រមុជទឹកដូច្នេះ?» ។ [២៦]លោកយ៉ូហានឆ្លើយទៅគេថា៖ «ខ្ញុំធ្វើពិធី
ជ្រមុជក្នុងទឹកមែន ប៉ុន្តែ ក្នុងចំណោមអ្នករាល់គ្នា មានម្នាក់ដែលអ្នករាល់គ្នាពុំស្គាល់ [២៧]លោកមកក្រោយ
ខ្ញុំ លោកមានឋានៈខ្ពង់ខ្ពស់ណាស់ សូម្បីតែឲ្យខ្ញុំស្រាយខ្សែស្បែកជើងជូនលោក ក៏មិនសមនឹងឋានៈរបស់
លោកផង» ។ [២៨]ហេតុការណ៍នេះកើតមាននៅភូមិបេតថានី ខាងនាយទន្លេយ័រដាន់ ត្រង់កន្លែងលោក
យ៉ូហានធ្វើពិធីជ្រមុជទឹក ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៤ ក្នុងរដូវរង់ចាំ ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** លក ១,៣៨

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះនាងព្រហ្មចារិនីម៉ារីទទួលព្រះបន្ទូល ហើយមានប្រសាសន៍ថា៖
«នាងខ្ញុំជាអ្នកបម្រើរបស់ព្រះអម្ចាស់ សូមឲ្យបានសម្រេចតាមពាក្យរបស់ព្រះអង្គចុះ!» ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត លូកា** ១,២៦-២៨

[២៦]ព្រះជាម្ចាស់បានចាត់ទេវទូតកាព្រីអែល ឲ្យទៅភូមិណាសារ៉ែត ក្នុងស្រុកកាលីឡេ [២៧]ដើម្បីជួបនឹង
ស្ត្រីក្រមុំព្រហ្មចារីម្នាក់ ជាគូដណ្ដឹងរបស់កំឡោះម្នាក់ ឈ្មោះយ៉ូសែប ដែលត្រូវជាញាតិវង្សព្រះបាទ
ដាវីឌ ។ ស្ត្រីក្រមុំនោះឈ្មោះនាងម៉ារី ។ [២៨]ទេវទូតចូលទៅក្នុងផ្ទះនាងម៉ារី ហើយពោលទៅកាន់នាង
ថា៖ «នាងជាទីគាប់ព្រះហឫទ័យព្រះអម្ចាស់អើយ! ចូរមានអំណរសប្បាយឡើង! ព្រះអង្គគង់ជាមួយ
នាង» ។ [២៩]ពេលឮពាក្យនេះ នាងម៉ារីរន្ធត់យ៉ាងខ្លាំង ហើយនឹករិះគិតថា តើពាក្យជម្រាបសួរនេះមាន
ន័យដូចម្ដេច ។ [៣០]ទេវទូតពោលទៅកាន់នាងថា៖ «កុំខ្លាចអី ម៉ារីអើយ! ដ្បិតព្រះជាម្ចាស់គាប់ព្រះហឫ
ទ័យនឹងនាងហើយ ។ [៣១]នាងនឹងមានគភ៌ ហើយសម្រាលបានបុត្រមួយ ដែលនាងត្រូវថ្វាយព្រះនាមថា
"យេស៊ូ" ។ [៣២]បុត្រនោះនឹងមានឋានៈដ៏ប្រសើរឧត្ដម ហើយគេនឹងថ្វាយព្រះនាមថា "ព្រះបុត្រានៃព្រះ
ដ៏ខ្ពង់ខ្ពស់បំផុត" ។ ព្រះជាម្ចាស់នឹងតាំងបុត្រនោះឲ្យគ្រងរាជ្យលើបល្ល័ង្ករបស់ព្រះបាទដាវីឌ ជាព្រះ
អយ្យកោរបស់ព្រះអង្គ [៣៣]ទ្រង់នឹងគ្រងរាជ្យលើប្រជារាស្ត្រអ៊ីស្រាអែលអស់កល្បជានិច្ច ហើយរាជ្យរបស់
ព្រះអង្គនឹងនៅស្ថិតស្ថេរ ឥតមានទីបញ្ចប់ឡើយ» ។ [៣៤]នាងម៉ារីសួរទៅទេវទូតថា៖ «តើធ្វើដូចម្ដេចនឹង
ឲ្យការនេះកើតឡើងបាន បើនាងខ្ញុំមិនរួមរស់ជាមួយបុរសណាផងដូច្នេះ?» ។ [៣៥]ទេវទូតឆ្លើយទៅនាង
វិញថា៖ «ព្រះវិញ្ញាណដ៏វិសុទ្ធនឹងយាងមកសណ្ឋិតលើនាង គឺឫទ្ធានុភាពរបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុតនឹង
គ្របបាំងនាង ។ ហេតុនេះ គេនឹងថ្វាយព្រះនាមដល់បុត្រដ៏វិសុទ្ធ ដែលត្រូវប្រសូតមកនោះថា "ព្រះ
បុត្រារបស់ព្រះជាម្ចាស់" ។ [៣៦]ម្យ៉ាងទៀត នាងអេលីសាបិតជាញាតិរបស់នាង មានផ្ទៃពោះប្រាំមួយខែ
ហើយ ថ្វីដ្បិតតែគាត់មានវ័យចាស់ថែមទាំងជាស្ត្រីអារទៀតផងក៏ដោយ [៣៧]ព្រោះគ្មានការអ្វីដែលព្រះជា
ម្ចាស់ធ្វើមិនកើតនោះឡើយ» ។ [៣៨]នាងម៉ារីពោលទៅទេវទូតថា៖ «នាងខ្ញុំជាអ្នកបម្រើរបស់ព្រះអម្ចាស់
សូមឲ្យបានសម្រេចតាមពាក្យរបស់លោកចុះ!» ។ បន្ទាប់មក ទេវទូតចាកចេញពីនាងទៅ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# រដូវបុណ្យព្រះយេស៊ូប្រសូត

# បុណ្យព្រះអម្ចាស់យេស៊ូប្រសូត
# អភិបូជានៅពេលយប់

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** — **តាម លក ២,១០-១១**

**អាលេលូយ៉ា! អាលេលូយ៉ា!** ខ្ញុំនាំដំណឹងល្អមួយមកប្រាប់អ្នករាល់គ្នា ។ ដំណឹងនេះនឹងធ្វើឲ្យប្រជារាស្ត្រទាំងមូលមានអំណរដ៏លើសលប់ គឺយប់នេះព្រះសង្គ្រោះរបស់អ្នករាល់គ្នាបានប្រសូតហើយ ទ្រង់ជាព្រះគ្រីស្ត ជាព្រះអម្ចាស់ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត លូកា** — **២,១-១៤**

[១]នៅគ្រានោះ ព្រះចៅអធិរាជរ៉ូម៉ាំង ព្រះនាមអូគូស្ត មានព្រះរាជបញ្ជាឲ្យជំរឿនចំនួនប្រជាជនទាំង
អស់ ក្នុងចក្រភពរ៉ូម៉ាំងទាំងមូល ។ [២]ការជំរឿនប្រជាជនលើកដំបូងនេះ បានធ្វើឡើងក្នុងអំឡុងពេល
ដែលលោកគីរីញូស ធ្វើជាទេសាភិបាលនៅស្រុកស៊ីរី ។ [៣]អ្នកស្រុកទាំងអស់ត្រូវទៅចុះឈ្មោះក្នុងបញ្ជី
តាមស្រុកកំណើតរៀងៗខ្លួន ។ [៤]រីឯលោកយ៉ូសែបក៏ចេញដំណើរពីភូមិណាសារ៉ែត ក្នុងស្រុកកាលីឡេ
ឆ្ពោះទៅភូមិបេថ្លេហិម ក្នុងស្រុកយូដា ជាភូមិកំណើតរបស់ព្រះបាទដាវីឌ ព្រោះលោកជាព្រះញាតិវង្ស
នឹងព្រះបាទដាវីឌ ។ [៥]លោកទៅចុះឈ្មោះជាមួយនាងម៉ារីជាភរិយាដែលមានផ្ទៃពោះ ។ [៦]ពេលអ្នកទាំង
ពីរនៅឯភូមិបេថ្លេហិម នាងម៉ារីគ្រប់ខែហើយ ។ [៧]នាងសម្រាលបានបុត្រមួយ ជាបុត្រច្បង ។ នាងរុំ
បុត្រនោះនឹងសំពត់ រួចដាក់ឲ្យផ្ទំក្នុងស្នូកសត្វ ដ្បិតពុំមានសល់កន្លែងសំណាក់ក្នុងផ្ទះ ។

[៨]ក្នុងស្រុកនោះ ពេលយប់មានពួកគង្វាលនៅមើលហ្វូងសត្វរបស់គេតាមវាលស្មៅ ។ [៩]ពេលនោះ
ទេវទូតរបស់ព្រះអម្ចាស់ មកឈរនៅក្បែរពួកគេ សិរីរុងរឿងរបស់ព្រះអម្ចាស់បានភ្លឺចិញ្ចែងចិញ្ចាចនៅ
ជុំវិញគេ នាំឲ្យគេភ័យខ្លាចយ៉ាងខ្លាំង ។ [១០]ទេវទូតពោលទៅគេថា៖ «កុំខ្លាចអ្វីឡើយ! ខ្ញុំនាំដំណឹងល្អ
មួយមកប្រាប់អ្នករាល់គ្នា ។ ដំណឹងនេះនឹងធ្វើឲ្យប្រជារាស្ត្រទាំងមូលមានអំណរដ៏លើសលប់ ។ [១១]គឺយប់
នេះនៅក្នុងភូមិកំណើតរបស់ព្រះបាទដាវីឌ ព្រះសង្គ្រោះរបស់អ្នករាល់គ្នាប្រសូតហើយ ទ្រង់ជាព្រះគ្រីស្ត
ជាអម្ចាស់ ។ [១២]នេះជាសញ្ញាសម្គាល់ឲ្យអ្នករាល់គ្នាដឹង គឺអ្នករាល់គ្នានឹងឃើញទារកមួយទើបនឹងកើត
មក រុំដោយសំពត់ នៅក្នុងស្នូកសត្វ» ។

[១៣]រំពេចនោះ មានទេវទូតច្រើនកុះករចុះពីស្ថានបរមសុខមក រួមជាមួយទេវទូតនោះ ច្រៀងសរសើរ
ព្រះជាម្ចាស់ថា៖ [១៤]«សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅស្ថានដ៏ខ្ពស់បំផុត ហើយសូមឲ្យ
មនុស្សលោកដ៏ជាទីស្រឡាញ់របស់ព្រះអង្គ បានប្រកបដោយសេចក្ដីសុខសាន្តនៅលើផែនដី! » ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# បុណ្យព្រះអម្ចាស់យេស៊ូប្រសូត
# អភិបូជានៅពេលព្រឹកព្រលឹម

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **លក ២,១៤**

**អាលេលូយ៉ា! អាលេលូយ៉ា!** សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅស្ថានដ៏ខ្ពស់បំផុត ហើយសូមឲ្យមនុស្សលោកដ៏ជាទីស្រឡាញ់របស់ព្រះអង្គ បានប្រកបដោយសេចក្ដីសុខសាន្តនៅលើផែនដី ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត លូកា** **២,១៥-២០**

[១៥]ពេលពួកទេវទូតត្រឡប់ទៅស្ថានបរមសុខវិញអស់ទៅ ពួកគង្វាលបបួលគ្នាថា៖ «ទៅ! យើងនាំ
គ្នាទៅបេថ្លេហិម មើលហេតុការណ៍ដែលកើតមាន ដូចព្រះអម្ចាស់បានសម្ដែងឲ្យយើងដឹងនោះមើល៍» ។
[១៦]ពួកគេប្រញាប់ប្រញាល់នាំគ្នាធ្វើដំណើរទៅ ឃើញនាងម៉ារី លោកយ៉ូសែប ព្រមទាំងព្រះឱរសផ្ទំក្នុង
ស្នូកសត្វ ។ [១៧] ពេលពួកគង្វាលឃើញព្រះឱរសហើយ គេក៏រៀបរាប់អំពីសេចក្ដីដែលទេវទូតបានប្រាប់
អំពីព្រះឱរសនេះ ។ [១៨]អស់អ្នកដែលបានឮពួកគង្វាលនិយាយនឹកឆ្ងល់យ៉ាងខ្លាំង ។ [១៩]រីឯនាងម៉ារីវិញ
នាងចងចាំហេតុការណ៍ទាំងនេះទុកក្នុងចិត្ត ព្រមទាំងត្រិះរិះពិចារណាថែមទៀតផង ។ [២០]បន្ទាប់មក ពួក
គង្វាលត្រឡប់ទៅវិញ ទាំងច្រៀងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ព្រោះហេតុការណ៍ទាំងអស់
ដែលគេបានឃើញបានឮ ស្របតាមសេចក្ដីដែលទេវទូតបានប្រាប់គេ ឥតមានខ្វះត្រង់ណាឡើយ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# បុណ្យព្រះអម្ចាស់យេស៊ូប្រសូត
# អភិបូជានៅពេលថ្ងៃ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ**

**អាលេលូយ៉ា! អាលេលូយ៉ា!** នៅថ្ងៃនេះ ព្រះពន្លឺបានបំភ្លឺមនុស្សលោក ។
ប្រជាជនទាំងឡាយនៅលើផែនដីអើយ! សូមអញ្ជើញចូលមកក្នុងពន្លឺរបស់ព្រះជាម្ចាស់!
សូមអញ្ជើញមកក្រាបថ្វាយបង្គំព្រះអម្ចាស់! **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** **១,១-១៨ (ឬយ៉ាងខ្លី ១,១-៥.៩-១៤)**

១កាលពីដើមដំបូងបង្អស់ ព្រះបន្ទូលមានព្រះជន្មគង់នៅ ។ ព្រះបន្ទូលបែរទៅរកព្រះជាម្ចាស់ ហើយ
ព្រះបន្ទូលជាព្រះជាម្ចាស់ ។ ២ព្រះបន្ទូលបែរទៅរកព្រះជាម្ចាស់ កាលពីដើមដំបូងបង្អស់ ។ ៣អ្វីៗសព្វ
សារពើ សុទ្ធតែកើតឡើងដោយសារព្រះបន្ទូល គឺក្នុងបណ្ដាអ្វីៗដែលកើតមក គ្មានអ្វីមួយកើតមកក្រៅពី
ព្រះអង្គបង្កើតនោះឡើយ ។ ៤ព្រះបន្ទូលជាប្រភពនៃជីវិត ហើយជីវិតនោះជាពន្លឺបំភ្លឺមនុស្សលោក ។
៥ពន្លឺភ្លឺក្នុងសេចក្ដីងងឹត តែសេចក្ដីងងឹតពុំបានទទួលពន្លឺទេ ។

៦ព្រះជាម្ចាស់បានចាត់បុរសម្នាក់ ឈ្មោះយ៉ូហានឲ្យមក ។ ៧លោកមកធ្វើជាបន្ទាល់ផ្ដល់សក្ខីភាពអំពី
ពន្លឺ ដើម្បីឲ្យមនុស្សទាំងអស់ជឿដោយសារលោក ។ ៨លោកយ៉ូហានមិនមែនជាពន្លឺទេ គឺលោកគ្រាន់តែ
មកផ្ដល់សក្ខីភាពអំពីពន្លឺប៉ុណ្ណោះ ។

៩ព្រះបន្ទូលជាពន្លឺដ៏ពិតប្រាកដតែមួយ ដែលមកក្នុងពិភពលោក ហើយបំភ្លឺមនុស្សគ្រប់ៗរូប ។
១០ព្រះបន្ទូលបានគង់ក្នុងពិភពលោក ហើយពិភពលោកកើតឡើងដោយសារព្រះអង្គ ប៉ុន្តែ ពិភពលោក
ពុំបានទទួលស្គាល់ព្រះអង្គទេ ។ ១១ព្រះបន្ទូលបានយាងមក គង់ជាមួយប្រជារាស្ត្ររបស់ព្រះអង្គផ្ទាល់ តែ
ប្រជារាស្ត្រនោះពុំបានទទួលព្រះអង្គឡើយ ។ ១២រីឯអស់អ្នកដែលបានទទួលព្រះអង្គ គឺអស់អ្នកដែលជឿ
លើព្រះនាមព្រះអង្គ ព្រះអង្គប្រទានឲ្យគេអាចទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ។ ១៣អ្នកទាំងនោះពុំ
មែនកើតពីលោហិត ពីចំណង់តណ្ហា ឬពីការប៉ងប្រាថ្នារបស់មនុស្សទេ គឺកើតពីព្រះជាម្ចាស់វិញ ។ ១៤ព្រះ
បន្ទូលកើតមកជាមនុស្ស ហើយគង់នៅក្នុងចំណោមយើងរាល់គ្នា យើងបានឃើញសិរីរុងរឿងរបស់ព្រះ
អង្គ ជាសិរីរុងរឿងនៃព្រះបុត្រាតែមួយគត់ ដែលមកពីព្រះបិតាព្រះអង្គពោរពេញទៅដោយព្រះហឫទ័
យប្រណីសន្ដោស និងសេចក្ដីពិត ។

[១៥]លោកយ៉ូហានបានផ្តល់សក្ខីភាពអំពីព្រះអង្គ ដោយប្រកាសថា៖ «គឺលោកនេះហើយ ដែលខ្ញុំ
និយាយថា “អ្នកមកក្រោយខ្ញុំ ប្រសើរជាងខ្ញុំ ដ្បិតលោកមានជីវិតមុនខ្ញុំ”» ។ [១៦]យើងទាំងអស់គ្នាទទួល
ព្រះហឫទ័យប្រណីសន្ដោស មិនចេះអស់មិនចេះហើយ ពីគ្រប់លក្ខណសម្បត្តិរបស់ព្រះអង្គ [១៧]ដ្បិតព្រះជា
ម្ចាស់ប្រទានធម្មវិន័យដោយសារលោកម៉ូសេ តែទ្រង់បានសម្តែងព្រះហឫទ័យប្រណីសន្ដោស និងសេចក្តី
ពិត ដោយសារព្រះយេស៊ូគ្រីស្ត ។ [១៨]ពុំដែលមាននរណាម្នាក់បានឃើញព្រះជាម្ចាស់ទេ មានតែព្រះបុត្រា
មួយព្រះអង្គប៉ុណ្ណោះ ដែលបាននាំយើងឲ្យស្គាល់ព្រះអង្គ ដ្បិតព្រះបុត្រាមានព្រះជន្មរួមជាមួយ
ព្រះបិតា ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# បុណ្យគ្រួសារដ៏វិសុទ្ធរបស់ព្រះយេស៊ូ ឆ្នាំ ខ

ថ្ងៃអាទិត្យក្រោយបុណ្យព្រះអម្ចាស់យេស៊ូប្រសូត

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម ទន ១១៨(១១៧),២៦-២៧**

**អាលេលូយ៉ា! អាលេលូយ៉ា!** សូមលើកតម្កើងព្រះអង្គដែលយាងមកក្នុងនាមនៃព្រះអម្ចាស់
ព្រះអម្ចាស់ប្រទានពន្លឺរបស់ព្រះអង្គមកបំភ្លឺយើង ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត លូកា** **២,២២-៤០ (ឬយ៉ាងខ្លី ២,២២.៣៩-៤០)**

២២ដល់ពេលកំណត់ដែលលោកយ៉ូសែប និងនាងម៉ារី ត្រូវធ្វើពិធីជំរះកាយឲ្យបានបរិសុទ្ធតាមធម្មវិ
ន័យលោកម៉ូសេ ។ អ្នកទាំងពីរនាំព្រះឱរសទៅថ្វាយព្រះអម្ចាស់ នៅក្រុងយេរូសាឡឹម ។

២៣ដ្បិតក្នុងធម្មវិន័យរបស់ព្រះអម្ចាស់ មានចែងទុកមកថា៖ «កូនប្រុសច្បងទាំងអស់ត្រូវញែកទុក
ថ្វាយព្រះអម្ចាស់» ។ ២៤អ្នកទាំងពីរថ្វាយយញ្ញបូជា តាមធម្មវិន័យរបស់ព្រះអម្ចាស់ចែងទុកមកគឺថ្វាយ
“លលកមួយគូ ឬព្រាបស្ទាវពីរ” ។

២៥នៅក្រុងយេរូសាឡឹម មានបុរសម្នាក់ឈ្មោះស៊ីម៉ូន ជាមនុស្សសុចរិត ។ គាត់គោរពកោតខ្លាចព្រះ
ជាម្ចាស់ ព្រមទាំងទន្ទឹងរង់ចាំពេលព្រះអង្គយាងមកសម្រាលទុក្ខប្រជារាស្ត្រអ៊ីស្រាអែល ។ ព្រះវិញ្ញាណដ៏
វិសុទ្ធសណ្ឋិតលើគាត់ ២៦ហើយសម្តែងឲ្យគាត់ដឹងថា គាត់មិនត្រូវស្លាប់ ដរាបណាមិនទាន់បានឃើញព្រះ
គ្រិស្ត ដែលព្រះអម្ចាស់ចាត់ឲ្យមកទេនោះ ។ ២៧ព្រះវិញ្ញាណនាំលោកតាស៊ីម៉ូនចូលក្នុងព្រះវិហារ ។ ពេល
មាតាបិតានាំព្រះឱរសយេស៊ូមកថ្វាយព្រះជាម្ចាស់តាមធម្មវិន័យ ២៨លោកតាស៊ីម៉ូនក៏យកព្រះឱរសមកបី
រួចសរសើរតម្កើងព្រះជាម្ចាស់ថា៖ ២៩«បពិត្រព្រះដ៏ជាចៅហ្វាយ! ឥឡូវនេះ ព្រះអង្គបានសម្រេចតាម
ព្រះបន្ទូលសន្យាហើយ ។ ដូច្នេះ សូមឲ្យទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គ លាចាកលោកនេះទៅដោយ
សុខសាន្តជងចុះ ៣០ដ្បិតភ្នែកទូលបង្គំបានឃើញការសង្គ្រោះ ៣១ដែលព្រះអង្គបានប្រទានមកឲ្យប្រជាជាតិ
ទាំងអស់ ៣២គឺជាពន្លឺដែលនាំឲ្យមនុស្សគ្រប់ជាតិសាសន៍ស្គាល់ព្រះអង្គ និងជាសិរីរុងរឿងរបស់អ៊ីស្រាអែល
ជាប្រជារាស្ត្រព្រះអង្គ» ។

៣៣មាតាបិតារបស់ព្រះយេស៊ូ ងឿងឆ្ងល់នឹងសេចក្តីដែលលោកតាស៊ីម៉ូនមានប្រសាសន៍ អំពីព្រះឱរស
ណាស់ ។ ៣៤លោកតាស៊ីម៉ូនជូនពរអ្នកទាំងពីរ ហើយនិយាយទៅកាន់នាងម៉ារីជាមាតាថា៖ «ព្រះជា
ម្ចាស់បានចាត់បុត្រនេះមក ដើម្បីឲ្យជនជាតិអ៊ីស្រាអែលច្រើននាក់ដួល ឬងើបឡើងវិញ ។ បុត្រនេះជា

ទីសម្គាល់មួយ បង្ហាញអំពីការសង្គ្រោះរបស់ព្រះជាម្ចាស់ តែមានមនុស្សជាច្រើននឹងជំទាស់ប្រឆាំង ។
៣៥បុត្រនេះ ធ្វើឲ្យគំនិតលាក់កំបាំងរបស់មនុស្សជាច្រើន លេចច្បាស់ឡើង ។ រីឯនាងវិញ នាងនឹងឈឺចុក
ចាប់យ៉ាងខ្លាំង ដូចមានដាវមួយមកចាក់ទម្លុះដួងចិត្តរបស់នាង» ។

៣៦មានព្យាការិនីម្នាក់ ឈ្មោះហាណ្ណា ជាកូនរបស់លោកផានូអែល ក្នុងកុលសម្ព័ន្ធអេស៊ែរ ។ គាត់រៀប
ការបានប្រាំពីរឆ្នាំ ប្ដីគាត់ក៏ទទួលមរណភាពបោលទៅ ៣៧គាត់នៅមេម៉ាយរហូត ឥឡូវនេះគាត់មានវ័យ
ចាស់ណាស់ទៅហើយ អាយុប៉ែតសិបបួនឆ្នាំ ។ គាត់មិនទៅណាឆ្ងាយពីព្រះវិហារទេ គាត់នៅគោរពបម្រើ
ព្រះអង្គទាំងយប់ទាំងថ្ងៃ ដោយតមអាហារ និងអធិស្ឋានផង ។ ៣៨ពេលនោះ លោកយាយហាណ្ណាក៏នៅ
ទីនោះដែរ គាត់សរសើរតម្កើងព្រះជាម្ចាស់ រួចតំណាលអំពីព្រះឱរសនោះ ប្រាប់អស់អ្នកដែលទន្ទឹងរង់ចាំ
ព្រះជាម្ចាស់យាងមកលោះក្រុងយេរូសាឡឹម ។

៣៩កាលមាតាបិតារបស់ព្រះយេស៊ូបានបំពេញកិច្ចការទាំងអស់ ស្របតាមធម្មវិន័យរបស់ព្រះអម្ចាស់
សព្វគ្រប់ហើយ គាត់ក៏នាំគ្នាវិលត្រឡប់ទៅណាសារ៉ែត ជាភូមិរបស់គាត់ក្នុងស្រុកកាលីឡេវិញ ។ ៤០ព្រះ
កុមារមានវ័យចម្រើនឡើងជាលំដាប់ មានកម្លាំងកាន់តែមាំមួនឡើង និងពោរពេញទៅដោយព្រះប្រាជ្ញា
ញាណ ។ ព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹងព្រះកុមារនេះណាស់ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃទី ១ ខែមករា៖ បុណ្យគោរពព្រះនាងម៉ារី ជាមាតារបស់ព្រះជាម្ចាស់

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម ហប ១,១-២

**អាលេលូយ៉ា! អាលេលូយ៉ា!** នៅជំនាន់ដើម ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់បុព្វបិរស
ដោយសារអស់លោកព្យាការី ។ តែឥឡូវនេះ ព្រះអង្គមានព្រះបន្ទូលមកយើង
ដោយសារព្រះបុត្រា! ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត លូកា** ២,១៦-២១

១៦កាលពួកគង្វាលនាំគ្នាធ្វើដំណើរទៅដល់ភូមិបេថ្លេហិមហើយ គេឃើញនាងម៉ារី លោកយ៉ូសែប
ព្រមទាំងព្រះឱរសផ្ទំក្នុងស្នូកសត្វ ។ ១៧ពេលពួកគង្វាលឃើញព្រះឱរសហើយ គេក៏រៀបរាប់អំពីសេចក្ដី
ដែលទេវទូតបានប្រាប់អំពីព្រះឱរសនេះ ។ ១៨អស់អ្នកដែលបានឮពួកគង្វាលនិយាយនឹកឆ្ងល់យ៉ាងខ្លាំង ។
១៩រីឯនាងម៉ារីវិញ នាងចងចាំហេតុការណ៍ទាំងនេះទុកក្នុងចិត្ត ព្រមទាំងត្រិះរិះពិចារណាថែមទៀតផង ។
២០បន្ទាប់មក ពួកគង្វាលត្រឡប់ទៅវិញ ទាំងច្រៀងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ព្រោះ
ហេតុការណ៍ទាំងអស់ដែលគេបានឃើញ និងបានឮ ស្របតាមសេចក្ដីដែលទេវទូតបានប្រាប់គេ ឥតមាន
ខ្វះត្រង់ណាឡើយ ។

២១ប្រាំបីថ្ងៃក្រោយមក ដល់ពេលកំណត់ធ្វើពិធីកាត់ស្បែកថ្វាយព្រះឱរស គេថ្វាយព្រះនាមថា
"យេស៊ូ" ជាព្រះនាមដែលទេវទូតបានប្រាប់នាងម៉ារី មុនពេលមានផ្ទៃពោះ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២ ក្រោយបុណ្យព្រះយេស៊ូប្រសូត

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ**

**អាលេលូយ៉ា! អាលេលូយ៉ា!** នៅថ្ងៃនេះ ព្រះពន្លឺបានបំភ្លឺមនុស្សលោក ។
ប្រជាជនទាំងឡាយនៅលើផែនដីអើយ! សូមអញ្ជើញចូលមកក្នុងពន្លឺរបស់ព្រះជាម្ចាស់!
សូមអញ្ជើញមកក្រាបថ្វាយបង្គំព្រះអម្ចាស់! **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** **១,១-១៨ (ឬយ៉ាងខ្លី ១,១-៥.៩-១៤)**

១កាលពីដើមដំបូងបង្អស់ ព្រះបន្ទូលមានព្រះជន្មគង់នៅ ។ ព្រះបន្ទូលបែរទៅរកព្រះជាម្ចាស់ ហើយ
ព្រះបន្ទូលជាព្រះជាម្ចាស់ ។ ២ព្រះបន្ទូលបែរទៅរកព្រះជាម្ចាស់ កាលពីដើមដំបូងបង្អស់ ។ ៣អ្វីៗសព្វ
សារពើ សុទ្ធតែកើតឡើងដោយសារព្រះបន្ទូល គឺក្នុងបណ្ដាអ្វីៗដែលកើតមក គ្មានអ្វីមួយកើតមកក្រៅពី
ព្រះអង្គបង្កើតនោះឡើយ ។ ៤ព្រះបន្ទូលជាប្រភពនៃជីវិត ហើយជីវិតនោះជាពន្លឺបំភ្លឺមនុស្សលោក ។
៥ពន្លឺភ្លឺក្នុងសេចក្ដីងងឹត តែសេចក្ដីងងឹតពុំបានទទួលពន្លឺទេ ។

៦ព្រះជាម្ចាស់បានចាត់បុរសម្នាក់ ឈ្មោះយ៉ូហានឲ្យមក ។ ៧លោកមកធ្វើជាបន្ទាល់ផ្ដល់សក្ខីភាពអំពី
ពន្លឺ ដើម្បីឲ្យមនុស្សទាំងអស់ជឿដោយសារលោក ។ ៨លោកយ៉ូហានមិនមែនជាពន្លឺទេ គឺលោកគ្រាន់តែ
មកផ្ដល់សក្ខីភាពអំពីពន្លឺប៉ុណ្ណោះ ។

៩ព្រះបន្ទូលជាពន្លឺដ៏ពិតប្រាកដតែមួយ ដែលមកក្នុងពិភពលោក ហើយបំភ្លឺមនុស្សគ្រប់ៗរូប ។
១០ព្រះបន្ទូលបានគង់ក្នុងពិភពលោក ហើយពិភពលោកកើតឡើងដោយសារព្រះអង្គ ប៉ុន្តែ ពិភពលោក
ពុំបានទទួលស្គាល់ព្រះអង្គទេ ។ ១១ព្រះបន្ទូលបានយាងមក គង់ជាមួយប្រជារាស្ត្ររបស់ព្រះអង្គផ្ទាល់ តែ
ប្រជារាស្ត្រនោះពុំបានទទួលព្រះអង្គឡើយ ។ ១២រីឯអស់អ្នកដែលបានទទួលព្រះអង្គ គឺអស់អ្នកដែលជឿ
លើព្រះនាមព្រះអង្គ ព្រះអង្គប្រទានឲ្យគេអាចទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ។ ១៣អ្នកទាំងនោះពុំ
មែនកើតពីលោហិត ពីចំណង់តណ្ហា ឬពីការប៉ងប្រាថ្នារបស់មនុស្សទេ គឺកើតពីព្រះជាម្ចាស់វិញ ។ ១៤ព្រះ
បន្ទូលកើតមកជាមនុស្ស ហើយគង់នៅក្នុងចំណោមយើងរាល់គ្នា យើងបានឃើញសិរីរុងរឿងរបស់ព្រះ
អង្គ ជាសិរីរុងរឿងនៃព្រះបុត្រាតែមួយគត់ ដែលមកពីព្រះបិតាព្រះអង្គពោរពេញទៅដោយព្រះហឫទ័
យប្រណីសន្ដោស និងសេចក្ដីពិត ។

១៥លោកយ៉ូហានបានផ្ដល់សក្ខីភាពអំពីព្រះអង្គ ដោយប្រកាសថា៖ «គឺលោកនេះហើយ ដែលខ្ញុំ

និយាយថា “អ្នកមកក្រោយខ្ញុំ ប្រសើរជាងខ្ញុំ ដ្បិតលោកមានជីវិតមុនខ្ញុំ” » ។ ១៦យើងទាំងអស់គ្នាទទួល
ព្រះហឫទ័យប្រណីសន្ដោស មិនចេះអស់មិនចេះហើយ ពីគ្រប់លក្ខណសម្បត្តិរបស់ព្រះអង្គ ១៧ដ្បិតព្រះជា
ម្ចាស់ប្រទានធម្មវិន័យដោយសារលោកម៉ូសេ តែទ្រង់បានសម្តែងព្រះហឫទ័យប្រណីសន្ដោស និងសេចក្ដី
ពិត ដោយសារព្រះយេស៊ូគ្រីស្ត ។ ១៨ពុំដែលមាននរណាម្នាក់បានឃើញព្រះជាម្ចាស់ទេ មានតែព្រះបុត្រា
មួយព្រះអង្គប៉ុណ្ណោះ ដែលបាននាំយើងឲ្យស្គាល់ព្រះអង្គ ដ្បិតព្រះបុត្រាមានព្រះជន្មរួមជាមួយ
ព្រះបិតា ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# បុណ្យព្រះយេស៊ូសម្ដែងព្រះអង្គ

ថ្ងៃអាទិត្យរវាងថ្ងៃទី ២ និងថ្ងៃទី ៨ ខែមករា

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **មថ ២,២**

**អាលេលូយ៉ា! អាលេលូយ៉ា!** យើងខ្ញុំបានឃើញផ្កាយរបស់ព្រះអង្គរះនៅទិសខាងកើត ហើយយើងខ្ញុំមកថ្វាយបង្គំព្រះអង្គ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** **២,១-១២**

[១]ព្រះយេស៊ូប្រសូតនៅភូមិបេថ្លេហិម ក្នុងស្រុកយូដា នារជ្ជកាលព្រះបាទហេរ៉ូដ ។ មានពួក
ហោរាចារ្យនាំគ្នាធ្វើដំណើរពីទិសខាងកើត មកដល់ក្រុងយេរូសាឡឹម [២]សួរថា៖ «ព្រះមហាក្សត្ររបស់
ជនជាតិយូដាដែលទើបនឹងប្រសូតគង់នៅឯណា? យើងខ្ញុំបានឃើញផ្កាយរបស់ព្រះអង្គរះនៅទិសខាង
កើត ហើយយើងខ្ញុំមកថ្វាយបង្គំព្រះអង្គ» ។ [៣]កាលព្រះបាទហេរ៉ូដឮដំណឹងនេះ ទ្រង់រន្ធត់ព្រះហឫទ័យ
យ៉ាងខ្លាំង ហើយអ្នកក្រុងយេរូសាឡឹមទាំងអស់ ក៏រន្ធត់ចិត្តជាមួយព្រះអង្គដែរ ។ [៤]ព្រះរាជាត្រាស់ហៅ
ពួកនាយកបូជាចារ្យ និងពួកធម្មាចារ្យទាំងប៉ុន្មានរបស់ប្រជាជនមក ដើម្បីសួរគេពីទីកន្លែងដែលព្រះគ្រី
ស្ដត្រូវប្រសូត ។ [៥]គេទូលស្ដេចថា ព្រះគ្រីស្ដត្រូវប្រសូតនៅភូមិបេថ្លេហិម ក្នុងស្រុកយូដា ដ្បិតមាន
សេចក្ដីចែងទុកមកដោយសារព្យាការីថា៖ [៦]«ភូមិបេថ្លេហិមជាដែនដីយូដាអើយ! ក្នុងបណ្ដាក្រុង
សំខាន់ៗនៃស្រុកយូដា អ្នកមិនមែនតូចជាងគេទេ ដ្បិតនឹងមានគង្វាលម្នាក់កើតចេញពីអ្នក លោកនឹង
ថែរក្សាជនជាតិអ៊ីស្រាអែលជាប្រជារាស្ដ្ររបស់យើង» ។ [៧]ពេលនោះ ព្រះបាទហេរ៉ូដហៅពួក
ហោរាចារ្យមកជាសម្ងាត់ សួរបញ្ជាក់អំពីពេលដែលផ្កាយរះឡើង ។ [៨]បន្ទាប់មក ទ្រង់ចាត់ហោរាចារ្យ
ទាំងនោះឲ្យទៅភូមិបេថ្លេហិម ដោយមានរាជឱង្ការថា៖ «សុំអស់លោកនាំគ្នាទៅចុះ ហើយស៊ើបសួរ
ដំណឹងអំពីព្រះឱរសនោះឲ្យបានច្បាស់លាស់ ។ កាលបានឃើញហើយ ចូរមកប្រាប់យើងវិញផង ដើម្បី
ឲ្យយើងទៅថ្វាយបង្គំព្រះអង្គដែរ» ។ [៩]ក្រោយពីបានទទួលរាជឱង្ការហើយ គេក៏នាំគ្នាចេញទៅ ។ ពេល
នោះ ផ្កាយដែលគេឃើញនៅទិសខាងកើត នាំមុខគេរហូតដល់កន្លែងដែលព្រះឱរសគង់ទើបឈប់ ។
[១០]កាលហោរាចារ្យទាំងនោះឃើញផ្កាយ គេសប្បាយចិត្តពន់ប្រមាណ ។ [១១]គេចូលទៅក្នុងផ្ទះ ឃើញព្រះ
ឱរសគង់នៅជាមួយនាងម៉ារីជាមាតា គេក៏នាំគ្នាក្រាបថ្វាយបង្គំព្រះអង្គ រួចបើកហិបយកទ្រព្យរបស់ខ្លួន
គឺមាស គ្រឿងក្រអូប និងជ័រល្វីងទេសមកថ្វាយព្រះអង្គ ។ [១២]បន្ទាប់មក គេវិលត្រឡប់ទៅស្រុករបស់ខ្លួន
វិញ តាមផ្លូវមួយផ្សេងទៀត ដ្បិតព្រះជាម្ចាស់មានព្រះបន្ទូលប្រាប់គេ ក្នុងសុបិននិមិត្ត មិនឲ្យវិលទៅ
គាល់ព្រះបាទហេរ៉ូដវិញឡើយ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# បុណ្យព្រះអម្ចាស់យេស៊ូទទួលពិធីជ្រមុជទឹក ឆ្នាំ ខ

ថ្ងៃអាទិត្យ ឬ ថ្ងៃចន្ទក្រោយបុណ្យព្រះយេស៊ូសម្តែងព្រះអង្គ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **មថ ៣,១៦-១៧ ; ទន ២៨,៣**

**អាលេលូយ៉ា!** **អាលេលូយ៉ា!** នៅថ្ងៃនេះ ផ្ទៃមេឃបក់ចំហ ព្រះវិញ្ញាណយាងចុះមក
សណ្ឋិតលើព្រះយេស៊ូ ហើយព្រះសូរសៀងរបស់ព្រះបិតាលាន់ឮនៅលំទឹកថា៖
«លោកនេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង!» ។ **អាលេលូយ៉ា!**

## ✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស **១,៧-១១**

៧លោកយ៉ូហានបាទីស្តប្រកាសប្រាប់បណ្តាជនថា៖ «លោកដែលមានកម្លាំងខ្លាំងជាងខ្ញុំ នឹងមកតាម
ក្រោយខ្ញុំ ។ ខ្ញុំមានឋានៈទាបណាស់ សូម្បីតែឱនស្រាយខ្សែស្បែកជើងជូនលោក ក៏មិនសមនឹងឋានៈ ដ៏
ខ្ពង់ខ្ពស់របស់លោកផង ។ ៨ខ្ញុំបានធ្វើពិធីជ្រមុជឲ្យអ្នករាល់គ្នាក្នុងទឹក រីឯលោកវិញ លោកនឹងធ្វើពិធី
ជ្រមុជឲ្យអ្នករាល់គ្នាក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ» ។

៩នៅគ្រានោះ ព្រះយេស៊ូយាងមកពីភូមិណាសារ៉ែតក្នុងស្រុកកាលីឡេ ។ ព្រះអង្គទទួលពិធីជ្រមុជទឹក
ពីលោកយ៉ូហានក្នុងទន្លេយ័រដាន់ ។ ១០ពេលព្រះអង្គយាងឡើងពីទឹកមកភ្លាម ទ្រង់ទតឃើញផ្ទៃមេឃ
របែកជាពីរ ហើយព្រះវិញ្ញាណយាងចុះដូចសត្វព្រាប មកសណ្ឋិតលើព្រះអង្គ ។ ១១មានឮព្រះសូរសៀង
ពីលើមេឃមកថា៖ «ព្រះអង្គជាបុត្រដ៏ជាទីស្រឡាញ់របស់យើង យើងគាប់ចិត្តនឹងព្រះអង្គណាស់!» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# រដូវសែសិបថ្ងៃ

# ឬ

# រដូវអប់រំពិសេស

# ថ្ងៃពុធរោយផេះ

## ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ — តាម ទន ៨០,៨.១៩-២០

**បន្ទរ-** បពិត្រព្រះអម្ចាស់! ព្រះបន្ទូលព្រះអង្គ ជាសេចក្ដីពិត!
ធម្មវិន័យរបស់ព្រះអង្គរំដោះយើងខ្ញុំ!

**អត្ថបទ-** ឱ! ព្រះអម្ចាស់អើយ! សូមនាំយើងខ្ញុំមកវិញ យើងខ្ញុំនឹងមិនបែកចិត្តពីព្រះអង្គទៀតឡើយ ។ សូមនាំយើងខ្ញុំមកវិញ! នោះយើងខ្ញុំនឹងបានរួចជីវិត! **បន្ទរ-** ...

## ✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ — ៦,១-៦.១៦-១៨

នៅគ្រានោះ ក្រុមសាវ័កជួបជុំជាមួយព្រះយេស៊ូនៅលើភ្នំ ។ ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ [១]«កុំ
ធ្វើបុណ្យទាននៅមុខមនុស្សម្នា ដើម្បីឲ្យតែគេឃើញនោះឡើយ ។ ធ្វើបែបនេះអ្នករាល់គ្នាពុំបានទទួល
រង្វាន់អ្វី ពីព្រះបិតារបស់អ្នករាល់គ្នា ដែលគង់នៅស្ថានបរមសុខទេ ។ [២]ពេលណាអ្នកធ្វើទានដល់ជនក្រី
ក្រ កុំស្រែកប្រកាសខ្លែងៗ ដូចពួកមានពុតតែងធ្វើនៅក្នុងធម្មសាលា ឬនៅតាមផងផ្លូវ ដើម្បីឲ្យមនុស្ស
ម្នាកោតសរសើរនោះឡើយ ។ ខ្ញុំសុំប្រាប់អ្នករាល់គ្នាឲ្យដឹងច្បាស់ថា អ្នកទាំងនោះបានទទួលរង្វាន់របស់
គេហើយ ។ [៣]រីឯអ្នកវិញ កាលណាដៃស្ដាំអ្នកធ្វើទានមិនបាច់ឲ្យដៃឆ្វេងដឹងឡើយ [៤]ដើម្បីឲ្យទានរបស់
អ្នកនៅស្ងាត់កំបាំង ។ ព្រះបិតារបស់អ្នកទតឃើញអំពើដែលអ្នកធ្វើនៅក្នុងទីស្ងាត់កំបាំង ទ្រង់នឹង
ប្រទានរង្វាន់មកអ្នកវិញ ។ [៥]កាលណាអ្នករាល់គ្នាអធិស្ឋាន កុំធ្វើដូចពួកអ្នកមានពុត ដែលចូលចិត្តឈរ
អធិស្ឋាននៅក្នុងធម្មសាលានិងនៅត្រង់ថ្នល់កែង ដើម្បីឲ្យមនុស្សម្នាឃើញនោះឡើយ ។ ខ្ញុំសុំប្រាប់ឲ្យអ្នក
រាល់គ្នាដឹងច្បាស់ថា ពួកទាំងនោះបានទទួលរង្វាន់របស់គេហើយ ។ [៦]រីឯអ្នកវិញ កាលណាអ្នកអធិស្ឋាន
ត្រូវចូលទៅក្នុងបន្ទប់ បិទទ្វារឲ្យជិត ហើយទូលទៅកាន់ព្រះបិតារបស់អ្នក ដែលគង់នៅក្នុងទីស្ងាត់
កំបាំង ។ ព្រះបិតារបស់អ្នកដែលទតឃើញ នៅក្នុងទីស្ងាត់កំបាំង ទ្រង់នឹងប្រទានរង្វាន់មកអ្នកជាពុំខា
ន ។ [១៦]កាលណាអ្នករាល់គ្នាតមអាហារ កុំធ្វើមុខក្រៀមដូចពួកអ្នកមានពុតនោះឡើយ ។ ពួកគេបង្ហាញ
ទឹកមុខឲ្យអ្នកដទៃឃើញថា ខ្លួនតមអាហារ ។ ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នកទាំងនោះបាន
ទទួលរង្វាន់របស់គេហើយ ។ [១៧]រីឯអ្នកវិញ កាលណាអ្នកតមអាហារ ត្រូវលាបទឹកអប់លើក្បាលហើយ
លុបមុខផង [១៨]កុំឲ្យមនុស្សម្នាឃើញថា អ្នកតមឡើយ គឺឲ្យតែព្រះបិតារបស់អ្នកដែលគង់នៅក្នុងទីស្ងាត់
កំបាំង ទតឃើញប៉ុណ្ណោះ ពេលនោះព្រះបិតារបស់អ្នក ដែលទតឃើញនៅក្នុងទីស្ងាត់កំបាំងនឹងប្រទាន
រង្វាន់មកអ្នកជាមិនខាន» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ១ ក្នុងរដូវសែសិបថ្ងៃ ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** មថ ៤,៤

**ប-** បពិត្រព្រះអម្ចាស់! ព្រះបន្ទូលព្រះអង្គ ជាសេចក្ដីពិត!
ហើយធម្មវិន័យរបស់ព្រះអង្គ រំដោះមនុស្សលោកដែរ!

**គ-** មនុស្សមិនមែនរស់ដោយសារតែអាហារប៉ុណ្ណោះទេ
គឺរស់ដោយសារគ្រប់ព្រះបន្ទូល ដែលចេញមកពីព្រះឱស្ឋ របស់ព្រះជាម្ចាស់ ។ **ប-** ...

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** ១,១២-១៥

ក្រោយពីព្រះយេស៊ូទទួលពិធីជ្រមុជទឹក [១២]ព្រះវិញ្ញាណនាំព្រះអង្គឆ្ពោះទៅវាលរហោស្ថាន ។ [១៣]ព្រះ
អង្គគង់នៅវាលរហោស្ថាន អស់រយៈពេលសែសិបថ្ងៃ ទាំងត្រូវមារសាតាំងល្បួង ។ ព្រះអង្គគង់នៅ
ជាមួយសត្វព្រៃ ហើយមានពួកទេវទូតបម្រើព្រះអង្គផង ។

[១៤]ក្រោយគេចាប់លោកយ៉ូហានបាទីស្ដ យកទៅឃុំឃាំង ព្រះយេស៊ូយាងទៅស្រុកកាលីឡេ ហើយ
ទ្រង់ប្រកាសដំណឹងល្អរបស់ព្រះជាម្ចាស់ ។ [១៥]ព្រះអង្គមានព្រះបន្ទូលថា៖ «ពេលកំណត់មកដល់ហើយ រី
ឯព្រះរាជ្យរបស់ព្រះជាម្ចាស់ ក៏មកជិតបង្កើយដែរ ។ ចូរនាំគ្នាប្រែចិត្តគំនិត ហើយជឿលើដំណឹងល្អ
ចុះ!» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២ ក្នុងរដូវសែសិបថ្ងៃ ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** មថ ៩,៥

**ប-** សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះគ្រីស្ត ជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ ។

**គ-** មានព្រះសូរសៀងបន្លឺពីក្នុងពពកមកថា៖ "អ្នកនេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង ចូរស្ដាប់ព្រះអង្គចុះ!" ។ **ប-** ...

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** ៩,២-១០

[២]ព្រះយេស៊ូនាំលោកសិលា លោកយ៉ាកុប និងលោកយ៉ូហានឡើងទៅលើភ្នំ គឺព្រះអង្គនាំតែលោក
ទាំងបីទៅដាច់ឡែកពីគេ ។ ពេលនោះ ព្រះអង្គប្រែជាមានទ្រង់ទ្រាយប្លែកពីមុន នៅមុខសាវ័កទាំងបី
នាក់ [៣]គឺព្រះពស្ត្ររបស់ព្រះអង្គ ត្រឡប់ជាមានពណ៌សភ្លឺត្រចះត្រចង់ ដែលគ្មានមនុស្សណានៅលើផែនដី
អាចធ្វើឲ្យសយ៉ាងនេះបានឡើយ ។ [៤]ពេលនោះ សាវ័កទាំងបីនាក់ ឃើញព្យាការីអេលីនិងលោកម៉ូសេ
សន្ទនាជាមួយព្រះយេស៊ូ ។ [៥]លោកសិលាទូលព្រះអង្គថា៖ «ព្រះគ្រូ! យើងខ្ញុំនៅទីនេះប្រសើរណាស់
យើងខ្ញុំនឹងសង់ពន្លាបី គឺមួយសម្រាប់ព្រះគ្រូ មួយសម្រាប់លោកម៉ូសេ និងមួយទៀតសម្រាប់លោកអេ
លី» ។ [៦]លោកសិលាមានប្រសាសន៍ដូច្នេះ មកពីលោកពុំដឹងថា ចង់និយាយអំពីអ្វីឡើយ ដ្បិតសាវ័កទាំង
បី ភ័យខ្លាចយ៉ាងខ្លាំង ។ [៧]ពេលនោះ ស្រាប់តែមានពពកមកគ្របបាំងគេទាំងអស់គ្នា មានព្រះសូរសៀង
បន្លឺពីក្នុងពពកមកថា៖ «អ្នកនេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង ចូរស្ដាប់ព្រះអង្គចុះ!» ។ [៨]រំពេច
នោះ ពួកសាវ័កក្រឡេកមើលជុំវិញខ្លួន ពុំឃើញនរណាទៀតឡើយ ឃើញតែព្រះយេស៊ូមួយព្រះអង្គ
ប៉ុណ្ណោះ ដែលគង់ជាមួយគេ ។

[៩]ពេលព្រះយេស៊ូយាងចុះពីលើភ្នំជាមួយសាវ័កទាំងបី ទ្រង់ហាមប្រាមគេមិនឲ្យនិយាយអំពីហេតុ
ការណ៍ដែលខ្លួនបានឃើញ ប្រាប់នរណាឡើយ រហូតដល់បុត្រមនុស្សទទួលជីវិតថ្មី ។ [១០]អ្នកទាំងបីធ្វើតាម
ព្រះបន្ទូលរបស់ព្រះអង្គ តែសាកសួរគ្នាថា៖ «តើ "ទទួលជីវិតថ្មី" មានន័យដូចម្ដេច?» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៣ ក្នុងរដូវសែសិបថ្ងៃ ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **កឡ ២,៩**

**ប-** សូមលើកតម្កើងសិរីរុងរឿងព្រះគ្រីស្ត! ព្រះអង្គជាព្រះប្រាជ្ញាញាណនៃព្រះជាម្ចាស់ ដ៏មានព្រះជន្មគង់នៅអស់កល្បជានិច្ច ។ សូមលើកតម្កើងសិរីរុងរឿងព្រះអម្ចាស់ ។

**គ-** គ្រប់លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ ស្ថិតនៅយ៉ាងពោពេញក្នុងរូបកាយព្រះគ្រីស្ត ។ **ប-** ...

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** **២,១៣-២៥**

[១៣]បុណ្យចម្លងរបស់ជនជាតិយូដា ជិតមកដល់ហើយ ព្រះយេស៊ូក៏យាងឡើងទៅក្រុងយេរូសាឡឹម ។
[១៤]នៅក្នុងបរិវេណព្រះវិហារ ព្រះអង្គឃើញអ្នកលក់គោ លក់ចៀម លក់ព្រាប និងអ្នកអង្គុយដូរប្រាក់ ។
[១៥]ព្រះអង្គយកខ្សែធ្វើរំពាត់ដេញអ្នកទាំងនោះ ព្រមទាំងចៀម និងគោរបស់គេ ចេញពីបរិវេណព្រះ
វិហារ ព្រះអង្គបាចប្រាក់អ្នកដូរប្រាក់ចោល ហើយផ្កាប់តុរបស់គេផង ។ [១៦]ព្រះអង្គមានព្រះបន្ទូលទៅ
អ្នកលក់ព្រាបថា៖ «ចូរយករបស់ទាំងអស់នេះចេញទៅ កុំយកដំណាក់ព្រះបិតាខ្ញុំ ធ្វើជាកន្លែងលក់ដូរ
ដូច្នេះឡើយ» ។ [១៧]ពួកសាវ័កនឹកឃើញសេចក្ដីដែលមានចែងទុកក្នុងគម្ពីរថា៖ «មកពីទូលបង្គំ
ស្រឡាញ់ព្រះដំណាក់របស់ព្រះអង្គ បានជាគេប្រហារជីវិតទូលបង្គំ» ។

[១៨]ពេលនោះ ជនជាតិយូដាទូលសួរព្រះអង្គថា៖ «តើលោកបង្ហាញទីសម្គាល់អ្វី ឲ្យយើងដឹងថា លោក
មានសិទ្ធិធ្វើការទាំងនេះ?» ។ [១៩]ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយទៅគេថា៖ «ចូររុះព្រះវិហារនេះចោល
ទៅ ខ្ញុំនឹងសង់ឡើងវិញក្នុងរវាងបីថ្ងៃ» ។ [២០]ជនជាតិយូដាតបថា៖ «គេបានចំណាយពេលសែសិប
ប្រាំមួយឆ្នាំ ដើម្បីសង់ព្រះវិហារនេះ រីឯលោក លោកនឹងសង់ឡើងវិញក្នុងរវាងតែបីថ្ងៃប៉ុណ្ណោះឬ?» ។
[២១]តាមពិត ព្រះយេស៊ូមានព្រះបន្ទូលសំដៅទៅលើព្រះវិហារ ដែលជារូបកាយរបស់ព្រះអង្គវិញឯ
ណោះ ។

[២២]ពេលព្រះអង្គទទួលព្រះជន្មថ្មី ក្រុមសាវ័កនឹកឃើញថា ព្រះអង្គមានព្រះបន្ទូល ដូច្នេះគេក៏ ជឿ
ព្រះគម្ពីរ ព្រមទាំងជឿព្រះបន្ទូលរបស់ព្រះយេស៊ូដែរ ។ [២៣]ពេលព្រះយេស៊ូគង់នៅក្រុងយេរូសាឡឹម ក្នុង
ឱកាសបុណ្យចម្លង មានមនុស្សជាច្រើនបានជឿលើព្រះនាមព្រះអង្គ ដោយឃើញទីសម្គាល់ដែលព្រះអង្គ
ធ្វើ ។ [២៤]ប៉ុន្តែ ព្រះយេស៊ូពុំទុកចិត្តគេទេ ដ្បិតព្រះអង្គស្គាល់ចិត្តគំនិតអ្នកទាំងនោះ [២៥]មិនបាច់មាននរណា
ពន្យល់ព្រះអង្គ អំពីចិត្តមនុស្សឡើយ ព្រោះព្រះអង្គឈ្វេងយល់អ្វីៗទាំងអស់ នៅក្នុងចិត្តមនុស្ស ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៤ ក្នុងរដូវសែសិបថ្ងៃ ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** យហ ៣,១៦

**ប-** បពិត្រព្រះយេស៊ូជាអម្ចាស់! សូមលើកតម្កើងសិរីរុងរឿង របស់ព្រះអង្គ ។

**គ-** ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយបានជា
ព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមក ដើម្បីឲ្យអស់អ្នកដែលជឿលើព្រះបុត្រា
មានជីវិតអស់កល្បជានិច្ច ។ **ប-** ...

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** ៣,១៤-២១

[១៤]កាលនៅវាលរហោស្ថាន លោកម៉ូសេបានលើកពស់ឡើងយ៉ាងណា បុត្រមនុស្សនឹងត្រូវគេលើក
ឡើងយ៉ាងនោះដែរ [១៥]ដើម្បីឲ្យអស់អ្នកដែលជឿលើព្រះអង្គ មានជីវិតអស់កល្បជានិច្ច ។ [១៦]ព្រះជាម្ចាស់
ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយ បានជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គ
មក ដើម្បីឲ្យអស់អ្នកដែលជឿលើព្រះបុត្រា មានជីវិតអស់កល្បជានិច្ច គឺមិនឲ្យគេវិនាសឡើយ ។
[១៧]ព្រះជាម្ចាស់បានចាត់ព្រះបុត្រារបស់ព្រះអង្គឲ្យយាងមកក្នុងលោកនេះ ពុំមែនដើម្បីដាក់ទោសមនុស្ស
លោកទេ គឺដើម្បីសង្គ្រោះមនុស្សលោកដោយសារព្រះបុត្រាវិញ ។ [១៨]អ្នកជឿលើព្រះបុត្រា មិនត្រូវ
ទទួលទោសទេ រីឯអ្នកមិនជឿបានទទួលទោសរួចស្រេចទៅហើយ ព្រោះគេពុំបានជឿលើព្រះនាមព្រះ
បុត្រាតែមួយរបស់ព្រះជាម្ចាស់ ។ [១៩]ហេតុដែលបណ្ដាលឲ្យមានទោសនោះ គឺពន្លឺបានយាងមកក្នុងពិភព
លោក ប៉ុន្តែ មនុស្សលោកចូលចិត្តភាពងងឹតជាងពន្លឺ ដ្បិតអំពើរបស់គេសុទ្ធតែអាក្រក់ ។ [២០]អស់អ្នក
ដែលប្រព្រឹត្តអំពើអាក្រក់ តែងតែស្អប់ពន្លឺ ហើយមិនចូលមករកពន្លឺឡើយ ព្រោះខ្លាចគេឃើញអំពើ
ដែលខ្លួនប្រព្រឹត្ត ។ [២១]ផ្ទុយទៅវិញអស់អ្នកដែលប្រព្រឹត្តតាមសេចក្ដីពិត តែងតែចូលមករកពន្លឺ ដើម្បីឲ្យ
គេឃើញថា អំពើដែលខ្លួនប្រព្រឹត្តនោះ ស្របតាមព្រះជាម្ចាស់មែន ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៥ ក្នុងរដូវសែសិបថ្ងៃ ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** យ៉ូហ ៣,១៤-១៥

**ប-** បពិត្រព្រះអម្ចាស់! យើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងព្រះអង្គ ។

**គ-** បពិត្របុត្រនៃមនុស្ស! ដោយគេលើកព្រះអង្គឡើងនៅលើឈើឆ្កាង មនុស្សទាំងអស់ទទួលជីវិត ។ **ប-** ...

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** ១២,២០-៣៣

[២០]ក្នុងចំណោមអស់អ្នកដែលឡើងទៅថ្វាយបង្គំព្រះជាម្ចាស់ក្នុងឱកាសបុណ្យចម្លង មានជនជាតិក្រិក
ខ្លះដែរ ។ [២១]គេចូលទៅជិតលោកភីលីព ជាអ្នកភូមិបេតសៃដាក្នុងស្រុកកាលីឡេ ទាំងពោលថា៖
«លោកម្ចាស់! យើងខ្ញុំចង់ជួបលោកយេស៊ូ» ។ [២២]លោកភីលីពទៅប្រាប់លោកអន់ទ្រេ ហើយលោកអន់
ទ្រេនិងលោកភីលីព ចូលទៅទូលព្រះយេស៊ូ ។ [២៣]ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ឥឡូវនេះ ដល់
ពេលកំណត់ដែលបុត្រមនុស្សត្រូវសំដែងសិរីរុងរឿងហើយ ។ [២៤]ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា
គ្រាប់ស្រូវធ្លាក់ដល់ដី ហើយបើមិនងាប់ទេ គ្រាប់នោះនៅតែមួយដដែល ។ ផ្ទុយទៅវិញ បើគ្រាប់ស្រូវ
នោះងាប់ វានឹងបង្កើតផលបានច្រើន ។ [២៥]អ្នកណាស្រឡាញ់ជីវិតរបស់ខ្លួន អ្នកនោះនឹងបាត់បង់ជីវិតទៅ
រីឯអ្នកដែលមិនជំពាក់ចិត្តនឹងជីវិតរបស់ខ្លួនក្នុងពិភពលោកនេះទេ នឹងរក្សាជីវិតខ្លួនឲ្យនៅស្ថិតស្ថេរអស់
កល្បជានិច្ច ។ [២៦]បើអ្នកណាចង់បំរើខ្ញុំ អ្នកនោះត្រូវមកតាមខ្ញុំ ខ្ញុំនៅទីណា អ្នកបំរើរបស់ខ្ញុំ ក៏នឹងនៅទី
នោះដែរ ។ បើអ្នកណាបំរើខ្ញុំ ព្រះបិតានឹងលើកកិត្តិយសអ្នកនោះ ។ [២៧]ឥឡូវនេះទូលបង្គំរន្ធត់ចិត្តណាស់
មិនដឹងជានឹងទូលថាដូចម្ដេចឡើយ ។ ឱព្រះបិតាអើយ! សូមសង្គ្រោះទូលបង្គំឲ្យរួចផុតពីទុក្ខលំបាកនៅ
ពេលកំណត់នេះផង! ។ ប៉ុន្តែ ទូលបង្គំមកដើម្បីរងទុក្ខលំបាកក្នុងពេលកំណត់នេះហើយ ។ [២៨]ឱព្រះបិតា
អើយ! សូមសម្តែងសិរីរុងរឿងព្រះនាមរបស់ព្រះអង្គឡើង» ។ ពេលនោះ មានឮព្រះសូរសៀងពីលើ
មេឃមកថា៖ «យើងបានសម្តែងសិរីរុងរឿងរបស់យើង ហើយយើងក៏នឹងសម្តែងសិរីរុងរឿងជាថ្មី
ទៀត» ។

[២៩]បណ្ដាជននៅទីនោះបានឮព្រះសូរសៀងក៏ពោលថា៖ «សន្ធឹកផ្គរលាន់» ។ អ្នកខ្លះទៀតពោល
ថា៖ «មានទេវទូតនិយាយមកលោក» ។ [៣០]ព្រះយេស៊ូមានព្រះបន្ទូលថា៖ «សំឡេងនេះបន្លឺឡើង
សម្រាប់អ្នករាល់គ្នា មិនមែនសម្រាប់ខ្ញុំទេ ។ [៣១]ឥឡូវនេះ ដល់ពេលកាត់ទោសមនុស្សលោកហើយ!

ហើយចៅហ្វាយរបស់មនុស្សលោក នឹងត្រូវបណ្តេញចេញទៅក្រៅ ។ [៣២]រីឯខ្ញុំវិញ កាលណាគេលើកខ្ញុំ
ឡើងពីដី ខ្ញុំនឹងទាញមនុស្សទាំងអស់មកឯខ្ញុំ» ។ [៣៣]ព្រះអង្គមានព្រះបន្ទូលដូច្នេះ ដើម្បីប្រាប់គេអំពី
របៀបដែលព្រះអង្គ ត្រូវសោយទិវង្គត ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# សប្តាហ៍ពិសិដ្ឋ

# ថ្ងៃអាទិត្យបុណ្យហែស្លឹក ឆ្នាំ ខ

# ព្រះយេស៊ូយាងចូលក្រុងយេរូសាឡឹម

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** **១១,១-១០**

[១]ព្រះយេស៊ូយាងមកជាមួយសាវ័កជិតដល់ក្រុងយេរូសាឡឹមហើយ ។ លុះមកដល់ជិតភូមិបេតផាសេ
និងភូមិបេថានី ដែលនៅចង្កេះភ្នំដើមអូលីវ ព្រះអង្គចាត់សាវ័កពីររូបឲ្យទៅមុន ដោយមានព្រះបន្ទូល
ថា៖ [២]«ចូរទៅភូមិនៅមុខអ្នករាល់គ្នា ពេលទៅដល់ភ្លាម អ្នកនឹងឃើញកូនលាមួយដែលគេចងទុក ពុំ
ទាន់ដែលមាននរណាជិះនៅឡើយទេ ចូរស្រាយវាដឹកមក ។ [៣]ប្រសិនបើមានគេសួរថា “ហេតុអ្វីបានជា
អ្នកស្រាយវា?” ចូរឆ្លើយប្រាប់គេថា “ព្រះអម្ចាស់ត្រូវការវា តែព្រះអង្គនឹងឲ្យគេដឹកមកវិញភ្លាមជា
មិនខាន”» ។

[៤]សាវ័កទាំងពីររូបចេញដំណើរទៅឃើញ កូនលាមួយដែលគេចងទុកនៅមាត់ទ្វារខាងក្រៅផ្ទះក្បែរ
ផ្លូវ ហើយក៏ស្រាយវា ។ [៥]មានអ្នកខ្លះនៅទីនោះ សួរអ្នកទាំងពីរថា៖ «តើអ្នកធ្វើអ្វីហ្នឹង ហេតុអ្វីបានជា
អ្នកស្រាយកូនលានេះ?» ។ [៦]សាវ័កទាំងពីរឆ្លើយទៅគេតាមពាក្យដែលព្រះយេស៊ូបានបង្គាប់មក គេក៏
ឲ្យដឹកចេញទៅ ។ [៧]សាវ័កទាំងពីរដឹកវាយកមកថ្វាយព្រះយេស៊ូ ហើយយកអាវរបស់ខ្លួនក្រាលពីលើខ្នង
កូនលា ព្រះអង្គក៏ឡើង គង់លើខ្នងកូនលានោះ ។ [៨]មានមនុស្សម្នាជាច្រើននាំគ្នាយកអាវរបស់ខ្លួនក្រាល
តាមផ្លូវ ហើយខ្លះទៀតយកស្លឹកឈើពីចម្ការមករាយលើផ្លូវដែរ ។ [៩]អស់អ្នកដែលដើរហែហមព្រះយេស៊ូ
ពីមុខពីក្រោយនាំគ្នាស្រែកឡើងថា៖ «ជយោ! សូមព្រះជាម្ចាស់ប្រទានពរដល់ព្រះអង្គដែលយាងមកក្នុង
ព្រះនាមព្រះអម្ចាស់ [១០]សូមព្រះជាម្ចាស់ប្រទានពរដល់ព្រះរាជ្យដែលកំពុងតែមកដល់ គឺព្រះរាជ្យរបស់
ព្រះបាទដាវីឌជាបិតារបស់យើង! ជយោ! ព្រះជាម្ចាស់នៅស្ថានដ៏ខ្ពង់ខ្ពស់បំផុត!» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យបុណ្យហែស្លឹក ឆ្នាំ ខ

# ពិធីរំលឹកទុក្ខលំបាករបស់ព្រះយេស៊ូ

## ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ

ប- បពិត្រព្រះអម្ចាស់យេស៊ូ! យើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងតបស់ព្រះអង្គ ។

គ- ព្រោះតែយើង ព្រះគ្រីស្តដាក់ខ្លួនធ្វើតាមព្រះបញ្ជា រហូតដល់សោយទិវង្គត គឺរហូតដល់សោយទិវង្គតលើឈើឆ្កាងថែមទៀតផង ។ ហេតុនេះហើយបានជាព្រះជាម្ចាស់លើកតម្កើងព្រះអង្គឡើងយ៉ាងខ្ពង់ខ្ពស់បំផុត ព្រមទាំងប្រោសប្រទានឱ្យព្រះអង្គមានព្រះនាមដ៏ប្រសើរលើសអ្វីៗទាំងអស់ -ប

**✠ សូមថ្លែងព្រះគម្ពីរស្តីអំពីទុក្ខលំបាករបស់ព្រះយេស៊ូជាអម្ចាស់តាមសន្ត ម៉ាកុស** **១៤,១-១៥,៤៧**

**ឬ យ៉ាងខ្លី មក ១៥,១-៣៩**

« អ » អ្នកអានដំណើររឿង

« យ » អ្នកអានព្រះបន្ទូលព្រះយេស៊ូ

« ឆ » អ្នកអានពាក្យអ្នកដទៃទៀត

អ- [១]នៅពីរថ្ងៃមុនបុណ្យចម្លង និងបុណ្យនំប៉័ងឥតមេ ក្រុមនាយកបូជាចារ្យ និងពួកធម្មាចារ្យនាំគ្នារកមធ្យោបាយ ដើម្បីចាប់ព្រះយេស៊ូ ដោយកលល្បិចយកទៅធ្វើគុត ។ [២]ប៉ុន្តែគេនិយាយគ្នាថា៖

ឆ- «កុំចាប់ក្នុងពេលបុណ្យនេះឡើយ ក្រែងកើតចលាចលក្នុងចំណោមប្រជាជន» ។

អ- [៣]ព្រះយេស៊ូគង់នៅភូមិបេថានី ក្នុងផ្ទះបុរសម្នាក់ឈ្មោះស៊ីម៉ូន ជាមនុស្សឃ្លង់ ។ ពេលព្រះអង្គកំពុងសោយព្រះស្ងោយ មានស្ត្រីម្នាក់ចូលមក ទាំងកាន់ដបថ្មកែវផង ។ នៅក្នុងដបនោះមានប្រេងទេព្វិរូសុទ្ធដ៏មានតម្លៃលើសលប់ ។ នាងបំបែកដបថ្មកែវ ហើយចាក់ប្រេងក្រអូប លើព្រះសិរសារបស់ព្រះយេស៊ូ ។ [៤]មានអ្នកខ្លះនៅទីនោះ ទាស់ចិត្តយ៉ាងខ្លាំងគេនិយាយគ្នាថា៖

ឆ- «ម្តេចក៏ខ្ជះខ្ជាយប្រេងក្រអូបដូច្នេះ! [៥]បើយកប្រេងនេះទៅលក់ មុខជាបានប្រាក់ជាងបីរយដួង ហើយចែកទានដល់ជនក្រីក្រវិញ» ។

អ- អ្នកទាំងនោះខឹងនឹងនាងណាស់ ។ [៦]ព្រះយេស៊ូមានព្រះបន្ទូលថា៖

យ- «ទុកឲ្យនាងធ្វើតាមចិត្តនាងទៅ! ហេតុអ្វីបានជារករឿងនាង! នាងបានធ្វើអំពើដ៏ល្អចំពោះខ្ញុំ ។ ៧
អ្នករាល់គ្នាមានអ្នកក្រីក្រនៅជាមួយ រហូតអ្នករាល់គ្នាអាចធ្វើទានដល់គេ តាមតែចិត្តអ្នករាល់គ្នា
ចង់ រីឯខ្ញុំវិញ ខ្ញុំមិននៅជាមួយអ្នករាល់គ្នារហូតទេ ។ ៨ស្ត្រីនេះបានធ្វើតាមសមត្ថភាពរបស់នាង គឺ
នាងលាបប្រេងក្រអូបលើរូបកាយខ្ញុំ ទុកជាមុនសម្រាប់យកទៅបញ្ចុះក្នុងផ្នូរ ។ ៩ខ្ញុំសុំប្រាប់ឲ្យអ្នក
រាល់គ្នាដឹងច្បាស់ថា នៅគ្រប់ទីកន្លែងក្នុងពិភពលោកទាំងមូល កាលណាគេប្រកាសដំណឹងល្អ គេក៏
នឹងតំណាលអំពីកិច្ចការដែលនាងបានធ្វើនេះដែរដើម្បីរំលឹកអំពីនាង ។

* * *

អ- ១០យូដាអ៊ីស្ការីយ៉ុតជាសាវ័កម្នាក់ ក្នុងក្រុមដប់ពីររូប បានទៅជួបពួកនាយកបូជាចារ្យ ដើម្បីគិតគូរ
នាំគេទៅចាប់ព្រះយេស៊ូ ។ ១១កាលអ្នកទាំងនោះស្ដាប់ពាក្យយូដានិយាយ គេសប្បាយចិត្តណាស់
ហើយសន្យាថានឹងឲ្យប្រាក់គាត់ ។ យូដាក៏រកឱកាសល្អ ដើម្បីនាំគេទៅចាប់ព្រះអង្គ ។

* * *

អ- ១២នៅថ្ងៃដំបូងនៃពិធីបុណ្យនំបុ័ងឥតមេ ជាថ្ងៃដែលគេត្រូវសម្លាប់កូនចៀមធ្វើយញ្ញបូជា សម្រាប់
បុណ្យចម្លង ក្រុមសាវ័កទូលសួរព្រះយេស៊ូថា៖

ឆ- «តើព្រះគ្រូចង់ឲ្យយើងខ្ញុំ រៀបចំពិធីជប់លៀងជូនក្នុងឱកាសបុណ្យចម្លង នៅកន្លែងណា? » ។

អ- ១៣ព្រះអង្គចាត់សាវ័កពីររូបឲ្យទៅ ដោយមានព្រះបន្ទូលថា៖

យ- «ចូរអ្នកទៅទីក្រុង អ្នកនឹងជួបបុរសម្នាក់លីក្អមទឹក ។ ចូរដើរតាមគាត់ទៅ ១៤ គាត់ចូលផ្ទះណាអ្នក
ត្រូវនិយាយទៅម្ចាស់ផ្ទះនោះថា លោកគ្រូមានប្រសាសន៍ថា "បន្ទប់ដែលខ្ញុំនឹងត្រូវជប់លៀង
ជាមួយពួកសិស្សក្នុងពេលបុណ្យចម្លង នៅឯណា?" ។ ១៥ម្ចាស់ផ្ទះនឹងបង្ហាញបន្ទប់មួយយ៉ាងធំនៅ
ជាន់ខាងលើ ដែលមានប្រដាប់ប្រដាសព្វគ្រប់រៀបចំជាស្រេច ចូររៀបចំម្ហូបអាហារសម្រាប់យើង
នៅក្នុងបន្ទប់នោះចុះ» ។

អ- ១៦សាវ័កទាំងពីរក៏ចេញទៅ លុះដល់ទីក្រុងគេបានឃើញដូចព្រះយេស៊ូមានព្រះបន្ទូលប្រាប់មែន គេ
ក៏រៀបចំម្ហូបអាហារសម្រាប់បុណ្យចម្លង ។ ១៧លុះដល់ល្ងាច ព្រះអង្គយាងមកដល់ជាមួយសាវ័ក
ទាំងដប់ពីររូប ។ ១៨នៅពេលព្រះយេស៊ូរួមតុសោយព្រះស្ងោយជាមួយក្រុមសាវ័ក ព្រះអង្គមានព្រះ
បន្ទូលថា៖

យ- «ខ្ញុំសុំប្រាប់អ្នករាល់គ្នាឲ្យបានដឹងច្បាស់ថា ក្នុងចំណោមអ្នករាល់គ្នា ដែលបរិភោគជាមួយខ្ញុំ មាន
ម្នាក់នឹងនាំគេមកចាប់ខ្ញុំ » ។

អ- ១៩ក្រុមសាវ័កព្រួយចិត្តក្រៃលែង គេទូលសួរព្រះអង្គបន្តបន្ទាប់គ្នាថា៖

ឆ- «តើទូលបង្គំឬ ? » ។

អ- [២០]ព្រះអង្គមានព្រះបន្ទូលទៅគេថា៖

យ- «គឺម្នាក់ក្នុងចំណោមអ្នកទាំងដប់ពីរ ដែលកំពុងជ្រលក់នំប៉័ងក្នុងចានជាមួយខ្ញុំនេះហើយ ។ [២១]បុត្រមនុស្សត្រូវតែស្លាប់ដូចមានចែងទុកក្នុងគម្ពីរអំពីលោកស្រាប់ហើយ ។ ប៉ុន្តែអ្នកដែលនាំគេមកចាប់បុត្រមនុស្ស នឹងត្រូវវេទនាជាមិនខាន ។ ចំពោះអ្នកនោះ បើមិនបានកើតមកទេ ទើបប្រសើរជាង» ។

អ- [២២]នៅពេលកំពុងបរិភោគ ព្រះយេស៊ូយកនំប៉័ងមកកាន់ ព្រះអង្គលើកតម្កើងព្រះជាម្ចាស់ ហើយកាច់ប្រទានឲ្យគេ ទាំងមានព្រះបន្ទូលថា៖

យ- «សុំពិសាចុះ នេះជារូបកាយរបស់ខ្ញុំ» ។

អ- [២៣]បន្ទាប់មក ព្រះអង្គយកពែងមកកាន់ អរព្រះគុណព្រះជាម្ចាស់ រួចប្រទានឲ្យក្រុមសាវ័ក ក្រុមសាវ័កក៏បរិភោគទាំងអស់គ្នា ។ [២៤]ព្រះអង្គមានព្រះបន្ទូលទៅគេថា៖

យ- «នេះជាលោហិតរបស់ខ្ញុំ គឺលោហិតនៃសម្ពន្ធមេត្រីដែលត្រូវបង្ហូរសម្រាប់មនុស្សទាំងអស់ ។ [២៥]ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា ខ្ញុំនឹងមិនពិសាស្រាទំពាំងបាយជូរទៀតឡើយ រហូតដល់ថ្ងៃ ដែលខ្ញុំនឹងពិសាស្រាទំពាំងបាយជូរថ្មី នៅក្នុងព្រះរាជ្យព្រះជាម្ចាស់» ។

អ- [២៦]ក្រោយពីបានច្រៀងទំនុកតម្កើង រួចហើយ ព្រះយេស៊ូយាងឆ្ពោះទៅភ្នំដើមអូលីវជាមួយក្រុមសាវ័ក ។ [២៧]ព្រះយេស៊ូមានព្រះបន្ទូល ទៅក្រុមសាវ័កថា៖

យ- «អ្នកទាំងអស់គ្នានឹងឃ្លាតចាកពីជំនឿ ដ្បិតមានចែងទុកមកថា "យើងនឹងវាយសម្លាប់គង្វាល ហើយចៀមនឹងត្រូវខ្ចាត់ខ្ចាយ" ។ [២៨]ក៏ប៉ុន្តែក្រោយពេលខ្ញុំមានជីវិតរស់ឡើងវិញ ខ្ញុំនឹងទៅស្រុកកាលីឡេមុនអ្នករាល់គ្នា» ។

អ- [២៩]លោកសិលាទូលព្រះអង្គថា៖

ឆ- «ទោះបីអ្នកឯទៀតៗបោះបង់ជំនឿក៏ដោយ ក៏ទូលបង្គំមិនបោះបង់បោលជំនឿជាដាច់ខាត» ។

អ- [៣០]ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖

យ- «ខ្ញុំសុំប្រាប់ឲ្យអ្នកដឹងច្បាស់ថា នៅយប់នេះឯង មុនមាន់រងាវពីរដង អ្នកនឹងបដិសេធបីដងថា មិនស្គាល់ខ្ញុំ» ។

អ- [៣១]ប៉ុន្តែលោកសិលាប្រកែក រឹតតែខ្លាំងឡើងថា៖

ឆ- «ទោះបីទូលបង្គំត្រូវស្លាប់ជាមួយព្រះអង្គក៏ដោយ ក៏ទូលបង្គំមិនបដិសេធថាមិនស្គាល់ព្រះអង្គជាដាច់ខាត» ។

អ-  សាវ័កឯទៀតៗក៏ទូលព្រះអង្គ ដូចលោកសិលាដែរ ។

* * *

អ-  [៣២]ព្រះយេស៊ូយាងទៅដល់កន្លែងមួយ ឈ្មោះកេតសេម៉ានី ជាមួយក្រុមសាវ័ក ។ ព្រះអង្គមានព្រះបន្ទូលថា៖

យ-  «ចូរអ្នករាល់គ្នាអង្គុយនៅទីនេះ ហើយចាំខ្ញុំអធិស្ឋានសិន» ។

អ-  [៣៣]ព្រះអង្គនាំលោកសិលា លោកយ៉ាកុប និងលោកយ៉ូហានទៅជាមួយ ។ ពេលនោះ ព្រះអង្គចាប់ផ្ដើមភ័យតក់ស្លុត ព្រមទាំងចុកចាប់អន្ទះសាពន់ប្រមាណ ។ [៣៤]ព្រះអង្គមានព្រះបន្ទូលទៅកាន់អ្នកទាំងបីថា៖

យ-  «ខ្ញុំព្រួយចិត្តយ៉ាងខ្លាំង ស្ទើរតែស្លាប់ អ្នករាល់គ្នានៅទីនេះសិនហើយ ចូរប្រុងស្មារតី» ។

អ-  [៣៥]ព្រះអង្គយាងទៅមុខបន្តិច ក្រាបចុះដល់ដី ទូលអង្វរសូមឲ្យទុក្ខលំបាកនេះ ចេញឆ្ងាយពីព្រះអង្គទៅបើសិនជាអាចកន្លងផុតទៅបាន ។ [៣៦]ព្រះអង្គទូលថា៖

យ-  «អ័ប្បា ឱព្រះបិតាអើយ! ព្រះអង្គអាចសំរេចគ្រប់កិច្ចការទាំងអស់បាន សូមដកយកពែងនៃទុក្ខលំបាកនេះ ចេញឲ្យឆ្ងាយពីទូលបង្គំទៅ ប៉ុន្តែសូមកុំតាមបំណងចិត្តទូលបង្គំឡើយគឺសូមឲ្យបានសម្រេច តាមព្រះហឫទ័យព្រះអង្គវិញ» ។

អ-  [៣៧]ព្រះអង្គយាងទៅរកក្រុមសាវ័ក ឃើញគេកំពុងតែដេកលក់ ព្រះអង្គមានព្រះបន្ទូលទៅលោកសិលាថា៖

យ-  «ស៊ីម៉ូនអើយ ម្ដេចក៏អ្នកដេកលក់ដូច្នេះ? អ្នកនៅស៊ូទ្រាំប្រុងស្មារតី សូម្បីតែមួយម៉ោងក៏មិនបានដែរឬ? [៣៨]ចូរប្រុងស្មារតី ហើយអធិស្ឋាន កុំឲ្យចាញ់ការល្បួង វិញ្ញាណរបស់មនុស្សប្រុងប្រៀបជាស្រេចមែន ប៉ុន្តែ ខ្លួនគេនៅខ្សោយទេ ! » ។

អ-  [៣៩]ព្រះអង្គយាងចេញទៅឆ្ងាយពីគេ សាជាថ្មីហើយទូលអង្វរដោយប្រើពាក្យដដែល ។ [៤០]ព្រះអង្គវិលត្រឡប់មករកក្រុមសាវ័កម្ដងទៀត ឃើញគេដេកលក់ ដ្បិតគេងងុយពេក បើកភ្នែកមិនរួចមិនដឹងទូលព្រះអង្គដូចម្ដេច ។ [៤១]ព្រះយេស៊ូវិលមករកគេជាលើកទីបី មានព្រះបន្ទូលទៅគេថា៖

យ-  «អ្នករាល់គ្នានៅតែដេកលក់ អ្នករាល់គ្នាសម្រាកដល់អង្កាល់ទៀត? ប៉ុណ្ណឹងល្មមហើយ! ឥឡូវនេះពេលកំណត់មកដល់ហើយ បុត្រមនុស្សត្រូវគេបញ្ជូនទៅក្នុងកណ្ដាប់ដៃរបស់មនុស្សបាប ។ [៤២]ចូរក្រោកឡើង យើងនាំគ្នាទៅ ដ្បិតអ្នកដែលនាំគេមកចាប់ខ្ញុំ ជិតមកដល់ហើយ! » ។

* * *

អ- [៤៣]ព្រះអង្គកំពុងតែមានព្រះបន្ទូលនៅឡើយ ស្រាប់តែយូដា ជាសាវ័កម្នាក់ ក្នុងចំណោមសាវ័កទាំង
ដប់ពីររូបមកដល់ ដោយមានបណ្ដាជនមួយក្រុម កាន់ដាវ កាន់ដំបងមកជាមួយផង ។ ពួកនាយក
បូជាចារ្យ ពួកធម្មាចារ្យនិងពួកព្រឹទ្ធាចារ្យ បានចាត់អ្នកទាំងនោះឲ្យមក ។ [៤៤]យូដា ដែលនាំគេមក
ចាប់ព្រះយេស៊ូ បានសន្មតជាមួយអ្នកទាំងនោះនូវសញ្ញាមួយថា៖

ឆ- «ខ្ញុំថើបអ្នកណាគឺអ្នកនោះហើយ សុំចាប់គាត់នាំយកទៅ ដោយប្រយ័ត្នប្រយែងឲ្យមែនទែន» ។

អ- [៤៥]កាលមកដល់ភ្លាមយូដាដើរតម្រង់មករកព្រះយេស៊ូពោលថា៖

ឆ- «លោកគ្រូ ! »

អ- រួចគាត់ថើបព្រះអង្គ [៤៦]ពួកគេនាំគ្នាចាប់ព្រះយេស៊ូ ។ [៤៧]មានម្នាក់ដែលនៅទីនោះ ហូតដាវកាប់អ្នក
បម្រើរបស់មហាបូជាចារ្យដាច់ស្លឹកត្រចៀកម្ខាង ។ [៤៨]ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖

យ- «ខ្ញុំជាចោរព្រៃឬ! បានជាអស់លោកកាន់ដាវ កាន់ដំបង មកចាប់ខ្ញុំដូច្នេះ? ។ [៤៩]ជារៀងរាល់ថ្ងៃ
ខ្ញុំនៅក្នុងព្រះវិហារ ជាមួយអស់លោក ទាំងបង្រៀនផង តែអស់លោកពុំបានចាប់ខ្ញុំទេ ។ ការណ៍
ទាំងនេះកើតឡើង ដើម្បីឲ្យបានស្របតាមសេចក្ដីដែលមានចែងទុកក្នុងគម្ពីរ» ។

អ- [៥០]ពេលនោះ ក្រុមសាវ័កបោះបង់ព្រះយេស៊ូចោល ហើយរត់បាត់អស់ទៅ ។ [៥១]មានកំឡោះម្នាក់
ដែលបានទៅតាមព្រះអង្គ មានតែសំពត់មួយផ្ទាំងបិទបាំងកាយប៉ុណ្ណោះ គេបានចាប់គាត់ដែរ [៥២]តែ
គាត់បោលសំពត់រត់ទៅខ្លួនទទេ ។

* * *

អ- [៥៣]គេបណ្ដើរព្រះយេស៊ូ នាំយកទៅដល់ដំណាក់របស់លោកមហាបូជាចារ្យ ។ ពួកនាយកបូជាចារ្យ
ពួកព្រឹទ្ធាចារ្យ និងពួកធម្មាចារ្យ មកជួបជុំទាំងអស់គ្នានៅទីនោះ ។ [៥៤]លោកសិលាដើរតាមព្រះអង្គ
ពីចម្ងាយ រហូតដល់ខាងក្នុងទីធ្លាដំណាក់មហាបូជាចារ្យ ហើយអង្គុយអាំងភ្លើងជាមួយកងរក្សាព្រះ
វិហារ ។ [៥៥]ពួកនាយកបូជាចារ្យ និងក្រុមប្រឹក្សាជាន់ខ្ពស់ទាំងមូល នាំគ្នារកពាក្យចោទប្រកាន់ព្រះ
យេស៊ូ ដើម្បីកាត់ទោសប្រហារជីវិតព្រះអង្គ តែរកមិនបានសោះ ។ [៥៦]មនុស្សជាច្រើនបានប្រឌិត
រឿងក្លែងក្លាយចោទប្រកាន់ព្រះអង្គ ប៉ុន្តែពាក្យចោទទាំងនោះមិនស្របគ្នាឡើយ ។ [៥៧]មានអ្នកខ្លះ
ក្រោកឈរឡើងពោលរឿងក្លែងក្លាយ ចោទប្រកាន់ព្រះអង្គថា៖

ឆ- [៥៨]«យើងបានឮអ្នកនេះពោលថា "ខ្ញុំនឹងរុះព្រះវិហារដែលសង់ឡើងដោយដៃមនុស្សចោលហើយ
ក្នុងរវាងបីថ្ងៃ ខ្ញុំនឹងសង់ព្រះវិហារមួយផ្សេងទៀតដែលមិនមែនសង់ដោយដៃមនុស្សទេ"» ។

អ- [៥៩]ប៉ុន្តែ ទោះបីក្នុងរឿងនេះក៏ដោយ ក៏ពាក្យរបស់គេនៅតែពុំស្របគ្នាដដែល ។ [៦០]ពេលនោះ
លោកមហាបូជាចារ្យក្រោកឈរឡើង នៅមុខក្រុមប្រឹក្សាជាន់ខ្ពស់សួរព្រះយេស៊ូថា៖

ឆ- «ម្ដេចក៏អ្នកមិនឆ្លើយនឹងពាក្យចោទប្រកាន់របស់លោកទាំងនេះ? »
អ- [៦១]ព្រះយេស៊ូនៅស្ងៀម ពុំឆ្លើយតបទាល់តែសោះ ។ លោកមហាបូជាចារ្យ សួរព្រះអង្គម្ដងទៀតថា ៖
ឆ- «តើអ្នកពិតជាព្រះគ្រីស្ដ ជាព្រះបុត្រារបស់ព្រះ ដែលយើងសរសើរតម្កើងមែនឬ? » ។
អ- [៦២]ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយថា៖
យ- «មែន គឺខ្ញុំហ្នឹងហើយ ។ អស់លោកនឹងឃើញបុត្រមនុស្ស គង់នៅខាងស្ដាំព្រះដ៏មានឫទ្ធានុភាព ហើយនឹងយាងមកជាមួយពពក នៅលើមេឃ» ។
អ- [៦៣]លោកមហាបូជាចារ្យឮដូច្នេះក៏ហែកអាវរបស់លោក ហើយមានប្រសាសន៍ថា៖
ឆ- «យើងមិនបាច់រកសាក្សីឯណាទៀតទេ [៦៤]អស់លោកឮជននេះពោលពាក្យប្រមាថព្រះជាម្ចាស់ស្រាប់ហើយ តើអស់លោកគិតដូចម្ដេច ? » ។
អ- គេបានសំរេចចិត្តទាំងអស់គ្នាកាត់ទោសប្រហារជីវិតព្រះយេស៊ូ ។ [៦៥]អ្នកខ្លះនាំគ្នាស្ដោះទឹកមាត់ដាក់ព្រះអង្គ គេគ្របព្រះភ័ក្ត្រព្រះអង្គ វាយតប់ព្រះអង្គ ហើយសួរថា៖
ឆ- «ទាយមើល៍! » ។
អ- កងរក្សាព្រះវិហារយកព្រះយេស៊ូមកទះកំផ្លៀង ។

* * *

អ- [៦៦]ពេលលោកសិលានៅក្នុងទីធ្លា មានស្ត្រីបម្រើម្នាក់របស់លោកមហាបូជាចារ្យមកដល់ ។ [៦៧]នាងឃើញលោកសិលាកំពុងអាំងភ្លើង ក៏សំឡឹងមើលមុខគាត់ឲ្យបានច្បាស់ រួចពោលថា៖
ឆ- «អ្នកឯងក៏ជាបក្សពួករបស់យេស៊ូ ជាអ្នកភូមិណាសារ៉ែតដែរ ! » ។
អ- [៦៨]ប៉ុន្តែលោកប្រកែកឡើងថា៖
ឆ- «ខ្ញុំមិនដឹងទេខ្ញុំមិនយល់ថា នាងចង់និយាយអំពីរឿងអ្វីឡើយ» ។
អ- លោកសិលាក៏ចេញពីទីនោះ ឆ្ពោះទៅខ្លោងទ្វារខាងក្រៅ ពេលនោះមាន់រងាវឡើង ។ [៦៩]ស្ត្រីបម្រើឃើញលោកសិលា ក៏ប្រាប់អស់អ្នកដែលនៅទីនោះម្ដងទៀតថា៖
ឆ- «អ្នកនេះជាបក្សពួកគេដែរ» ។
អ- [៧០]លោកសិលាប្រកែកសាជាថ្មី ។ បន្តិចក្រោយមកអស់អ្នក ដែលនៅទីនោះ និយាយទៅលោកសិលាទៀតថា៖
ឆ- «អ្នកឯងប្រាកដជាបក្សពួកអ្នកទាំងនោះមែន ព្រោះអ្នកឯងជាអ្នកស្រុកកាលីឡេដូចគ្នា» ។
អ- [៧១]លោកសិលាក៏និយាយឡើងថា៖

ឆ- «បើខ្ញុំកុហក សូមឲ្យព្រះជាម្ចាស់ដាក់ទោសខ្ញុំចុះ ខ្ញុំសុំស្បថថា ខ្ញុំមិនដែលស្គាល់អ្នកនោះទាល់តែសោះ» ។

អ- [៧២]ភ្លាមនោះមាន់រងាវឡើងជាលើកទីពីរ លោកសិលាក៏នឹកឃើញព្រះបន្ទូលរបស់ព្រះយេស៊ូ ដែលថា "មុនមាន់រងាវពីរដង អ្នកនឹងបដិសេធបីដងថាមិនស្គាល់ខ្ញុំ" គាត់ក៏ទ្រហោយំ ។

* * *

*ប្រសិនបើអានយ៉ាងខ្លី សូមចាប់ផ្ដើមពីនេះទៅ*

អ- ១៥[១]លុះព្រលឹមឡើង ពួកនាយកបូជាចារ្យប្រជុំគ្នាជាមួយពួកព្រឹទ្ធាចារ្យ ពួកធម្មាចារ្យ និងក្រុមប្រឹក្សាជាន់ខ្ពស់ទាំងមូល ។ គេបានចងព្រះយេស៊ូ ហើយបញ្ជូនព្រះអង្គទៅលោកពីឡាត ។ [២]លោកពីឡាតសួរព្រះអង្គថា៖

ឆ- «តើអ្នកជាស្ដេចយូដាមែនឬ?» ។

អ- ព្រះយេស៊ូមានព្រះបន្ទូលតបថា៖

យ- «លោកទេតើ ដែលមានប្រសាសន៍ដូច្នេះ!» ។

អ- [៣]ពួកនាយកបូជាចារ្យបានយករឿងជាច្រើន មកចោទប្រកាន់ព្រះយេស៊ូ ។ [៤]លោកពីឡាតសួរព្រះអង្គម្ដងទៀតថា៖

ឆ- «ហេតុដូចម្ដេចបានជា អ្នកមិនឆ្លើយអ្វីសោះដូច្នេះ ? អ្នកមិនឮពាក្យទាំងប៉ុន្មាន ដែលគេចោទប្រកាន់អ្នកទេឬ ? » ។

អ- [៥]ព្រះយេស៊ូពុំបានឆ្លើយតបទៀតឡើយ ជាហេតុនាំឲ្យលោកពីឡាតងឿងឆ្ងល់ជាខ្លាំង ។ [៦]ជារៀងរាល់ឆ្នាំ ក្នុងឱកាសបុណ្យចម្លង លោកពីឡាតតែងលែងអ្នកទោសម្នាក់ តាមពាក្យសុំរបស់បណ្ដាជន ។ [៧]មានបុរសម្នាក់ឈ្មោះបារ៉ាបាសជាប់ឃុំឃាំងជាមួយពួកបះបោរ ដែលសម្លាប់មនុស្សម្នាក់នៅពេលកើតចលាចល ។ [៨]បណ្ដាជននាំគ្នាឡើងទៅជួបលោកពីឡាត សុំឲ្យលោកដោះលែងអ្នកទោសម្នាក់ តាមទម្លាប់ដែលលោកធ្លាប់អនុគ្រោះដល់គេ ។ [៩]លោកពីឡាតមានប្រសាសន៍សួរថា៖

ឆ- «តើអ្នករាល់គ្នាចង់ឲ្យ ខ្ញុំដោះលែងស្ដេចយូដាឬ?» ។

អ- [១០]លោកមានប្រសាសន៍ដូច្នេះ មកពីលោកជ្រាបថាពួកនាយកបូជាចារ្យបញ្ជូនព្រះយេស៊ូ មកលោក ព្រោះពួកគេមានចិត្តប្រណែន ។ [១១]ពួកនាយកបូជាចារ្យ នាំគ្នាបញ្ឆុះបញ្ឆុលបណ្ដាជន សុំឲ្យលោកពីឡាតដោះលែងបារ៉ាបាសវិញ ។ [១២]លោកពីឡាតមានប្រសាសន៍ទៅគេម្ដងទៀតថា៖

ឆ- «បើដូច្នេះ តើអ្នករាល់គ្នាចង់ឲ្យខ្ញុំធ្វើអ្វីដល់អ្នកដែលអ្នករាល់គ្នាហៅថា ស្ដេចយូដានេះ?» ។

អ- [១៣]គេស្រែកឡើងថា៖

ឆ- «ឆ្កាងទៅ!» ។

អ- ១៤លោកពីឡាតសួរថា៖

ឆ- «តើអ្នកនេះបានប្រព្រឹត្តអំពើអាក្រក់អ្វី?» ។

អ- ប៉ុន្តែ គេនាំគ្នាស្រែកកាន់តែខ្លាំងឡើងៗថា៖

ឆ- «ឆ្កាងទៅ!» ។

អ- ១៥លោកពីឡាតចង់បំពេញចិត្តបណ្ដាជនក៏ដោះលែងបារ៉ាបាស ។ បន្ទាប់ពីបញ្ជាឲ្យគេវាយព្រះ
យេស៊ូ នឹងរំពាត់ រួចហើយលោកប្រគល់ទៅឲ្យគេឆ្កាង ។

* * *

អ- ១៦ពួកទាហានបណ្ដើរព្រះយេស៊ូ ទៅក្នុងទីធ្លាបន្ទាយ ហើយហៅកងទាហានទាំងមូលមក ។ ១៧គេ
យកអាវពណ៌ក្រហមទុំមកពាក់ឲ្យព្រះអង្គ រួចយកបន្លាមកក្រងធ្វើភួងបំពាក់ជាមកុដលើព្រះសិរ
សាព្រះអង្គ ។ ១៨គេក៏នាំគ្នាសំពះព្រះអង្គទាំងពោលថា៖

ឆ- «សូមគោរពថ្វាយបង្គំស្ដេចយូដា ! » ។

អ- ១៩គេយកដំបងវាយព្រះសិរសាព្រះអង្គគេស្ដោះទឹកមាត់ដាក់ព្រះអង្គ ព្រមទាំងលុតជង្គង់ថ្វាយបង្គំ
ព្រះអង្គថែមទៀតផង ។ ២០ក្រោយពីបានប្រមាថមើលងាយព្រះអង្គ រួចហើយពួកគេដោះអាវពណ៌
ក្រហមចេញយកព្រះពស្ត្ររបស់ព្រះអង្គ មកពាក់ថ្វាយព្រះអង្គវិញ ហើយបណ្ដើរយកទៅឆ្កាង ។

* * *

អ- ២១ពេលនោះ មានបុរសម្នាក់ជាអ្នកស្រុកគីរ៉ែនត្រឡប់មកពីចំការ គេបាប់បង្ខំគាត់ឲ្យលីឈើឆ្កាង
របស់ព្រះយេស៊ូ ។ អ្នកនោះឈ្មោះស៊ីម៉ូន ជាឪពុករបស់អឡិចសង់ និង រូភូស ។ ២២គេបណ្ដើរព្រះ
យេស៊ូមកដល់កន្លែងមួយឈ្មោះ"កុលកូថា" ដែលប្រែថា "ភ្នំលលាដ៍ក្បាល" ។ ២៣គេយកស្រា
ទំពាំងបាយជូរលាយជាមួយគ្រឿងញាណម៉្យាង មកថ្វាយព្រះអង្គសោយ ប៉ុន្តែព្រះអង្គពុំបានសោយ
ទេ ។ ២៤គេក៏ឆ្កាងព្រះអង្គហើយយកសម្លៀកបំពាក់របស់ព្រះអង្គមកចាប់ឆ្នោតចែកគ្នា ។ ២៥គេ
ឆ្កាងព្រះអង្គនៅម៉ោងប្រាំបួនព្រឹក ។ ២៦គេសរសេរប្រកាសអំពីហេតុដែលគេធ្វើទោសព្រះអង្គថា «
ស្ដេចជនជាតិយូដា» ។ ២៧គេក៏បានឆ្កាងចោរព្រៃពីរនាក់ជាមួយព្រះយេស៊ូដែរ ម្នាក់នៅខាងស្ដាំ
ព្រះអង្គ ម្នាក់ទៀតនៅខាងឆ្វេងព្រះអង្គ ។ ២៨ហេតុការណ៍នេះកើតឡើងស្របតាមសេចក្ដី ដែល
មានចែងទុកក្នុងគម្ពីរថា «ព្រះអង្គត្រូវគេរាប់បញ្ចូលជាមួយមនុស្សអាក្រក់» ។ ២៩មនុស្សម្នាដើរ
កាត់តាមនោះ ប្រមាថមើលងាយព្រះអង្គ ទាំងគ្រវីក្បាលដាក់ព្រះអង្គ និងពោលថា៖

ឆ-	«នែ៎អ្នករុះព្រះវិហារ ហើយសង់ឡើងវិញតែបីថ្ងៃអើយ [៣០]សង្គ្រោះខ្លួនឯងទៅអញ្ជើញចុះពីឈើឆ្កាងមក ! » ។

អ-	[៣១]រីឯពួកនាយកបូជាចារ្យ និង ធម្មាចារ្យក៏និយាយគ្នាចំអកឲ្យព្រះអង្គដូចគេដែរ ពួកគេពោលថា៖

ឆ-	«គាត់បានសង្គ្រោះអ្នកឯទៀតៗ តែមិនអាចសង្គ្រោះខ្លួនឯង ! ។ [៣២]សូមព្រះគ្រីស្តជាស្តេចអ៊ីស្រាអែលអញ្ជើញចុះពីឈើឆ្កាងឥឡូវនេះមក ដើម្បីឲ្យយើងឃើញនិងជឿផង ! » ។

អ-	អ្នកដែលជាប់ឆ្កាងជាមួយព្រះយេស៊ូ ក៏ជេរប្រមាថព្រះអង្គដែរ ។

* * *

អ-	[៣៣]នៅពេលថ្ងៃត្រង់ ស្រាប់តែផែនដីទាំងមូលងងឹតសូន្យ រហូតដល់ម៉ោងបីរសៀល ។ [៣៤]នៅវេលាម៉ោងបីរសៀល ព្រះយេស៊ូស្រែកអង្វរខ្លាំងៗថា៖

យ-	«អេឡូយ អេឡូយ ឡាម៉ាសាបាច់ថានី ? »

អ-	ពាក្យនេះប្រែថា

យ-	«ឱព្រះនៃទូលបង្គំ ព្រះនៃទូលបង្គំអើយ ហេតុអ្វីបានជា ព្រះអង្គបោះបង់ទូលបង្គំចោលដូច្នេះ? » ។

អ-	[៣៥]អ្នកខ្លះឈរនៅទីនោះបានឮព្រះបន្ទូលរបស់ព្រះអង្គ ក៏ពោលថា៖

ឆ-	«ឃើញទេ ! គាត់ហៅលោកអេលី ! » ។

អ-	[៣៦]មានម្នាក់រត់ទៅយកសារាយស្ងួតជ្រលក់ទឹកខ្មេះជោក រុំជាប់នៅចុងត្រែងមួយដើមហុចថ្វាយព្រះអង្គសោយទាំងពោលថា៖

ឆ-	«ចាំមើលមើល៍ តើលោកអេលីមកយកគាត់ចុះពីឈើឆ្កាងឬទេ? » ។

អ-	[៣៧]រីឯព្រះយេស៊ូវិញ ទ្រង់បន្លឺព្រះសូរសៀងយ៉ាងខ្លាំង រួចរលត់វិញ្ញាណទៅ ។

* * *

*សូមផ្កាកមួយស្របក់ ទុកអោយគ្រីស្តបរិស័ទស្មឹងស្មាធិ៍*

អ-	[៣៨]វាំងននៅក្នុងព្រះវិហាររហែកជាពីរ តាំងពីលើរហូតដល់ក្រោម ។ [៣៩]នាយទាហានរ៉ូម៉ាំង ដែលឈរនៅខាងមុខព្រះយេស៊ូ ឃើញព្រះអង្គរលត់វិញ្ញាណរបៀបនេះក៏ពោលឡើងថា៖

ឆ-	«បុរសនេះពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន! » ។

អ- [៤០]មានស្ត្រីៗខ្លះទៀត មើលពីចម្ងាយក្នុងចំណោមស្ត្រីទាំងនោះ មាននាងម៉ារី ជាអ្នកស្រុកម៉ាដាឡា
នាងម៉ារី ជាម្ដាយរបស់យ៉ាកុបតូច និងយ៉ូសេ ព្រមទាំងនាងសាឡូមេផង ។ [៤១]ស្ត្រីទាំងនោះមក
ជាមួយ ហើយបម្រើព្រះអង្គតាំងពីព្រះអង្គនៅស្រុកកាលីឡេម្ល៉េះ ។ មានស្ត្រីឯទៀតៗជាច្រើនបាន
ឡើងមកក្រុងយេរូសាឡឹមជាមួយព្រះអង្គដែរ ។

*ប្រសិនបើអានយ៉ាងខ្លី សូមចប់ត្រឹមនេះ*

អ- [៤២]ថ្ងៃនោះ ជាថ្ងៃដែលគេរៀបចំបុណ្យចម្លង គឺមួយថ្ងៃមុនថ្ងៃសប្ប័ទ ។ លុះដល់ល្ងាច [៤៣]លោកយ៉ូ
សែប ជាអ្នកស្រុកអារីម៉ាថេ មកដល់លោកជាសមាជិក ដែលមានកេរ្តិ៍ឈ្មោះល្អ ក្នុងក្រុមប្រឹក្សា
ជាន់ខ្ពស់ ហើយលោកក៏រង់ចាំព្រះរាជ្យរបស់ព្រះជាម្ចាស់ដែរ ។ លោកមានចិត្តក្លាហានហ៊ានទៅ
ជួបលោកពីឡាត សុំយកព្រះសពព្រះយេស៊ូ ។ [៤៤]លោកពីឡាតនឹកឆ្ងល់ណាស់ ដោយឮថាព្រះយេស៊ូ
សោយទិវង្គតយ៉ាងឆាប់ដូច្នេះ ។ លោកហៅនាយទាហានមកសួរឲ្យដឹងថាព្រះយេស៊ូសោយទិវង្គត
យូរហើយឬ ។ [៤៥]បន្ទាប់ពីបានទទួលសេចក្ដីរាយការណ៍ពីនាយទាហាន រួចហើយលោកក៏អនុញ្ញាត
ឲ្យគេប្រគល់ព្រះសពទៅលោកយ៉ូសែប ។ [៤៦]លោកយ៉ូសែបទិញក្រណាត់ជាឌឹប លោកយកព្រះសព
ព្រះយេស៊ូ ចុះពីឈើឆ្កាង ហើយរុំនឹងក្រណាត់រួចដាក់ក្នុងរូងថ្មមួយដែលគេដាប់ធ្វើជាផ្នូរ ។ បន្ទាប់
មក លោកប្រមៀលថ្មមួយដុំបិទមាត់ផ្នូរ ។ [៤៧]នាងម៉ារី ជាអ្នកស្រុកម៉ាដាឡា និងនាងម៉ារីជាម្ដាយ
យ៉ូសេ នាំគ្នាមើលកន្លែង ដែលគេបញ្ចុះព្រះសពព្រះអង្គ ។

[— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។]

# ថ្ងៃព្រហស្បតិ៍ពិសិដ្ឋ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម យហ ១៣,៣៤**

ប- បពិត្រព្រះអម្ចាស់យេស៊ូ! យើងខ្ញុំសូមលើកតម្កើងសិរីរុងរឿងតបស់ព្រះអង្គ ។

គ- ព្រះអង្គប្រទានវិន័យថ្មីឱ្យយើងខ្ញុំ "គឺត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ" ។ -ប

**✠ សូមថ្លែងព្រះគម្ពីរស្ដីអំពីទុក្ខលំបាករបស់ព្រះយេស៊ូជាអម្ចាស់តាមសន្ត យ៉ូហាន** **១៣,១-១៥**

[១]នៅមុនថ្ងៃបុណ្យចម្លង ព្រះយេស៊ូជ្រាបថា ដល់ពេលកំណត់ ដែលព្រះអង្គត្រូវឆ្លងពីលោកនេះ ឆ្ពោះ
ទៅព្រះបិតាហើយ ។ ដោយព្រះអង្គស្រឡាញ់សាវ័ករបស់ព្រះអង្គ ដែលរស់នៅក្នុងលោកនេះ ទ្រង់ក៏
ស្រឡាញ់គេរហូតដល់ទីបំផុត ។

[២]ពេលនោះ ព្រះយេស៊ូ និងក្រុមសាវ័កកំពុងបរិភោគអាហារ មារសាតាំងបានធ្វើឲ្យយូដាអ៊ីស្ការីយ៉ុត
ជាកូនលោកស៊ីម៉ូន មានគំនិតនាំគេមកចាប់ព្រះអង្គ ។ [៣]ព្រះយេស៊ូជ្រាបថា ព្រះបិតាបានប្រគល់អ្វីៗទាំង
អស់មកក្រោមអំណាចព្រះអង្គ ហើយជ្រាបថា ព្រះអង្គយាងមកពីព្រះជាម្ចាស់ និងយាងទៅឯព្រះជា
ម្ចាស់វិញ ។ [៤]ព្រះអង្គក្រោកឡើង ដោះព្រះពស្ត្រចេញ យកក្រមាមកក្រវាត់ចង្កេះ ។ [៥]បន្ទាប់មក ព្រះ
អង្គចាក់ទឹកក្នុងជើងមួយ រួចចាប់ផ្ដើមលាងជើងក្រុមសាវ័ក ព្រមទាំងយកក្រមាពីចង្កេះមកជូតផង ។ [៦]
ពេលព្រះអង្គហៀបនឹងលាង ជើងឲ្យលោកស៊ីម៉ូនសិលា លោកទូលព្រះអង្គថា៖ «ព្រះអម្ចាស់អើយ មិន
សមនឹងព្រះអង្គលាងជើងឲ្យទូលបង្គំសោះ!» ។ [៧]ព្រះយេស៊ូមានព្រះបន្ទូល ទៅគាត់ថា៖ «ពេលនេះ
អ្នកមិនទាន់ដឹងថា ខ្ញុំកំពុងធ្វើអ្វីឡើយ ថ្ងៃក្រោយអ្នកមុខតែយល់ជាមិនខាន» ។ [៨]លោកសិលាទូលព្រះ
អង្គថា៖ «ទេ! ព្រះអង្គមិនត្រូវលាងជើងទូលបង្គំជាដាច់ខាត!» ។ ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់
ថា៖ «ប្រសិនបើខ្ញុំមិនលាងជើងអ្នកទេ នោះអ្នកមិនអាចរួមជាមួយខ្ញុំតទៅទៀតបានឡើយ» ។ [៩]លោក
ស៊ីម៉ូនក៏ទូលព្រះអង្គថា៖ «ព្រះអម្ចាស់អើយ! បើដូច្នេះ សូមកុំលាងតែជើងប៉ុណ្ណោះ សូមលាងទាំងដៃ
ទាំងក្បាលផង» ។ [១០]ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «អ្នក ដែលបានងូតទឹករួច មិនបាច់លាងខ្លួនទេ
គឺលាងតែជើង ដ្បិតខ្លួនគេស្អាតបរិសុទ្ធទាំងមូលហើយ ។ អ្នករាល់គ្នាបានស្អាតបរិសុទ្ធ តែមិនមែនគ្រប់
គ្នាទេ» ។ [១១]ព្រះអង្គមានព្រះបន្ទូលថា "អ្នករាល់គ្នាមិនមែនបរិសុទ្ធគ្រប់គ្នា"ដូច្នេះ មកពីព្រះអង្គជ្រាប
អំពីអ្នក ដែលហៀបនឹងនាំគេមកចាប់ព្រះអង្គ ។

១២កាលព្រះយេស៊ូលាងជើងឲ្យគេរួចហើយ ព្រះអង្គស្លៀកពាក់ឡើងវិញ យាងមកតុទាំងមានព្រះ
បន្ទូលសួរទៅគេថា៖ «តើអ្នករាល់គ្នាយល់អំពីកិច្ចការដែលខ្ញុំបានធ្វើ ចំពោះអ្នករាល់គ្នានេះឬទេ?
១៣អ្នករាល់គ្នាហៅខ្ញុំថា ព្រះគ្រូ និងព្រះអម្ចាស់ នោះត្រូវមែន គឺខ្ញុំហ្នឹងហើយ! ។ ១៤បើខ្ញុំជា ព្រះអម្ចាស់
និងជាព្រះគ្រូបានលាងជើងឲ្យអ្នករាល់គ្នាទៅហើយ អ្នករាល់គ្នាក៏ត្រូវតែលាងជើងឲ្យគ្នាទៅវិញទៅមក
ដែរ ។ ១៥ខ្ញុំបានធ្វើជាគំរូឲ្យអ្នករាល់គ្នាប្រព្រឹត្ត ដូចខ្ញុំបានប្រព្រឹត្តដល់អ្នករាល់គ្នា ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃសុក្រពិសិដ្ឋ

## ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ

ព្រះអង្គបានដាក់ខ្លួន ធ្វើតាមព្រះបញ្ជា រហូតដល់សោយទិវង្គត
គឺរហូតដល់សោយទិវង្គតលើឈើឆ្កាងថែមទៀតផង ។
ហេតុនេះហើយ បានជាព្រះជាម្ចាស់លើកតម្កើងព្រះអង្គឡើងយ៉ាងខ្ពង់ខ្ពស់បំផុត
ព្រមទាំងប្រោសប្រទានឲ្យព្រះអង្គមានព្រះនាមប្រសើរលើស អ្វីៗទាំងអស់ ។

**✠ សូមថ្លែងព្រះគម្ពីរស្តីអំពីទុក្ខលំបាករបស់ព្រះយេស៊ូជាអម្ចាស់តាមសន្ត យ៉ូហាន** ១៨,១-១៩,៤២

« អ » អ្នកអានដំណើររឿង
« យ » អ្នកអានព្រះបន្ទូលព្រះយេស៊ូ
« ឆ » អ្នកអានពាក្យអ្នកដទៃទៀត

អ- បន្ទាប់ពីជប់លៀងរួចហើយ ១៨[១]ព្រះយេស៊ូយាងទៅខាងនាយជ្រោះកេដ្រូនជាមួយក្រុមសាវ័ក ។
នៅទីនោះ មានសួនឧទ្យានមួយ ព្រះអង្គយាងចូលទៅក្នុងសួនឧទ្យាននោះជាមួយក្រុមសាវ័ក ។ [២]រី
ឯយូដាជាអ្នកក្បត់ ព្រះអង្គក៏ស្គាល់កន្លែងនោះដែរ ព្រោះជាកន្លែង ដែលព្រះយេស៊ូ និងក្រុមសាវ័
កធ្លាប់ជួបជុំគ្នាជាញឹកញាប់ ។ [៣]ដូច្នេះ យូដានាំកងទាហាន និងកងរក្សាព្រះវិហារចូលមក ទាំង
កាន់ចន្លុះ កាន់គោម កាន់អាវុធផង ។ ពួកនាយកបូជាចារ្យ និងពួកខាងគណៈផារីស៊ី បានចាត់អ្នក
ទាំងនោះឲ្យមក ។ [៤]ព្រះយេស៊ូឈ្វេងយល់ហេតុការណ៍ទាំងប៉ុន្មាន ដែលត្រូវកើតដល់ព្រះអង្គ ព្រះ
អង្គក៏យាងទៅមុខ ហើយមានព្រះបន្ទូលសួរគេថា៖

យ- «អ្នករាល់គ្នាមករកនរណា ? » ។

អ- [៥]គេទូលព្រះអង្គថា៖

ឆ- «រកឈ្មោះយេស៊ូជាអ្នកភូមិណាសារ៉ែត» ។

អ- ព្រះអង្គមានព្រះបន្ទូលទៅគេថា៖

យ- «គឺខ្ញុំហ្នឹងហើយ» ។

អ- រីឯយូដាស ជាអ្នកក្បត់ព្រះអង្គក៏នៅជាមួយពួកគេដែរ ។ [៦]កាលព្រះយេស៊ូមានព្រះបន្ទូលទៅគេថា
"គឺខ្ញុំហ្នឹងហើយ" ដូច្នេះ គេថយក្រោយ ហើយដួលដាច់ផ្ងារទាំងអស់គ្នា ។ [៧]ព្រះយេស៊ូមានព្រះ
បន្ទូលសួរគេម្តងទៀតថា៖

យ- «អ្នករាល់គ្នាមករកនរណា ?»

អ- គេទូលថា៖

ឆ- «រកឈ្មោះយេស៊ូ ជាអ្នកភូមិណាសារ៉ែត» ។

អ- ៨ព្រះយេស៊ូមានព្រះបន្ទូល ទៅគេថា៖

យ- «ខ្ញុំបានប្រាប់អ្នករាល់គ្នាថា ខ្ញុំហ្នឹងហើយ បើអ្នករាល់គ្នាមករកខ្ញុំ ទុកឲ្យអ្នកទាំងនេះចេញទៅចុះ»
។

អ- ៩ព្រះអង្គមានព្រះបន្ទូលដូច្នេះ ស្របតាមសេចក្ដី ដែលព្រះអង្គបានថ្លែងទុកមកថា “អស់អ្នក ដែល
ព្រះអង្គប្រទានមកទូលបង្គំ ឥតមាននរណាម្នាក់ត្រូវវិនាសឡើយ” ។ ១០លោកស៊ីម៉ូន សិលាមានដាវ
មួយ គាត់ហូតកាប់អ្នកបំរើម្នាក់របស់លោកមហាបូជាចារ្យដាច់ស្លឹកត្រចៀកស្ដាំ អ្នកបំរើនោះ
ឈ្មោះម៉ាល់ឃូស ។ ១១ព្រះយេស៊ូមាន ព្រះបន្ទូលទៅលោកសិលាថា៖

យ- «ស៊កដាវទៅក្នុងស្រោមវិញទៅ តើអ្នកមិនចង់ឲ្យខ្ញុំផឹកពីពែងនៃទុក្ខលំបាក ដែលព្រះបិតាប្រទាន
មកខ្ញុំទេឬ? » ។

អ- ១២ពួកទាហាន និងមេបញ្ជាការរបស់គេ ព្រមទាំងកងរក្សាព្រះវិហារ*របស់ជនជាតិយូដា នាំគ្នា
ចាប់ព្រះយេស៊ូហើយចងព្រះអង្គ ។ ១៣គេនាំព្រះអង្គទៅជួបលោកហាណ្ណាមុនគេ ព្រោះលោកត្រូវ
ជាឪពុកក្មេករបស់លោកកៃផាស ដែលកាន់តំណែងជាមហាបូជាចារ្យនៅឆ្នាំនោះ ១៤គឺលោកកៃ
ផាសនេះហើយ ដែលបានឲ្យយោបល់ទៅជនជាតិយូដាថា “គួរឲ្យមនុស្សតែម្នាក់ស្លាប់ ជា
ប្រយោជន៍ដល់ប្រជារាស្ដ្រ” ។

* * *

អ- ១៥លោកស៊ីម៉ូនសិលាដើរតាមព្រះយេស៊ូជាមួយសាវ័ក*ម្នាក់ទៀត លោកមហាបូជាចារ្យស្គាល់សាវ័ក
ម្នាក់នោះ ហេតុនេះហើយបានជាគាត់អាចចូលជាមួយព្រះយេស៊ូ ទៅទីធ្លាខាងក្នុងដំណាក់របស់
លោកមហាបូជាចារ្យ ។ ១៦រីឯលោកសិលាវិញ គាត់ឈរនៅខាងក្រៅក្បែរមាត់
ទ្វារ ។ សាវ័កដែលលោកមហាបូជាចារ្យស្គាល់នោះ ក៏ចេញមកនិយាយជាមួយស្ដ្រីម្នាក់ជាអ្នកយាម
ទ្វារ ហើយនាំលោកសិលាចូលទៅខាងក្នុងដែរ ។ ១៧ស្ដ្រីបំរើជាអ្នក យាមទ្វារនិយាយទៅកាន់លោក
សិលាថា៖

ឆ- «អ្នកឯងជាសាវ័ករបស់អ្នកនោះដែរ មែនឬ ? » ។

អ- លោកសិលាតបថា៖

ឆ- «ទេ ! មិនមែនទេ ! » ។

អ- [១៨]ពួកអ្នកបំរើរបស់លោក មហាបូជាចារ្យ និងកងរក្សាព្រះវិហារនាំគ្នាបង្កាត់ភ្លើងអាំង ព្រោះពេល
នោះរងាណាស់ ។ លោកសិលាក៏នៅអាំងភ្លើងជាមួយពួកគេដែរ ។

* * *

អ- [១៩]លោកមហាបូជាចារ្យសួរព្រះយេស៊ូអំពីក្រុមសាវ័ក*របស់ព្រះអង្គ និងអំពីសេចក្ដីដែលព្រះអង្គប
ង្រៀន ។ [២០]ព្រះយេស៊ូមានព្រះបន្ទូលតបទៅលោកវិញថា៖

យ- «ខ្ញុំបាននិយាយ ដោយបេញមុខប្រាប់មនុស្សលោក ខ្ញុំតែងបង្រៀននៅក្នុងធម្មសាលា និងនៅក្នុង
ព្រះវិហារ ជាកន្លែង ដែលជនជាតិយូដាទាំងអស់ជួបជុំគ្នា គឺឥតនិយាយក្នុងទីលាក់កំបាំងទេ ។ [២១]
ហេតុដូចម្ដេចបានជា លោកសួរខ្ញុំ ? សូមលោកសួរអស់អ្នកដែលបានឮសេចក្ដីខ្ញុំនិយាយនោះទៅ
ដ្បិតគេសុទ្ធតែដឹងអំពីអ្វីៗ ដែលខ្ញុំបាននិយាយ» ។

អ- [២២]ពេលឮព្រះយេស៊ូមានព្រះបន្ទូលដូច្នោះ ទាហានម្នាក់ក្នុងកងរក្សាព្រះវិហារដែលឈរនៅក្បែរ
នោះ ទះកំផ្លៀងព្រះអង្គទាំងពោលថា៖

ឆ- «ម្ដេចក៏អ្នកឯងហ៊ានឆ្លើយរបៀបនេះទៅលោកមហាបូជាចារ្យ ! » ។

អ- [២៣]ព្រះយេស៊ូមាន ព្រះបន្ទូលតបទៅទាហាននោះវិញថា៖

យ- «បើខ្ញុំនិយាយខុសឆ្គង សុំប្រាប់មើល៍! តើមានឆ្គងត្រង់ណា ! តែបើខ្ញុំនិយាយត្រឹមត្រូវ ម្ដេចក៏អ្នក
វាយខ្ញុំ ? » ។

អ- [២៤]ពេលនោះ លោកហាណ្ណាបញ្ជូនព្រះអង្គទាំងជាប់ចំណង ទៅលោកកៃផាស ជាមហាបូជាចារ្យ ។

* * *

អ- [២៥]លោកស៊ីម៉ូនសិលាអាំងភ្លើងនៅទីនោះ ។ មានគេសួរលោកថា៖

ឆ- «អ្នកឯងជាសាវ័ករបស់អ្នកនោះដែរមែនឬ ? » ។

អ- លោកសិលាប្រកែកថា៖

ឆ- «ទេ ! មិនមែនទេ ! » ។

អ- [២៦]មានអ្នកបំរើរបស់មហាបូជាចារ្យម្នាក់ ត្រូវជាបងប្អូននឹងអ្នកដែលលោកសិលាកាប់ដាច់ស្លឹកត្រ
ចៀក ពោលថា៖

ឆ- «ខ្ញុំក៏បានឃើញអ្នកឯងនៅក្នុងសួនជាមួយគាត់ដែរ ! » ។

អ- [២៧]លោកសិលាប្រកែកសាជាថ្មីម្ដងទៀត ។ រំពេចនោះ ស្រាប់តែមាន់រងាវឡើង ។

* * *

អ- [២៨]បន្ទាប់មក គេបណ្ដើរព្រះយេស៊ូចេញពីដំណាក់លោកកៃផាស ទៅបន្ទាយរបស់លោកទេសាភិបា
ល ។ ពេលនោះ ភ្លឺស្រាងៗហើយ ។ ជនជាតិយូដាពុំបានចូលក្នុងបន្ទាយទេ ព្រោះគេខ្លាចមានបាប
នាំឲ្យធ្វើពិធីជប់លៀងក្នុងឱកាសបុណ្យចម្លងមិនបាន ។ [២៩]ដូច្នេះ លោកពីឡាតចេញមកជួបពួកគេ
សួរថា៖

ឆ- «តើអ្នករាល់គ្នាចោទប្រកាន់អ្នកនេះអំពីរឿងអ្វី ? » ។

អ- [៣០]គេជំរាបលោកថា៖

ឆ- «ប្រសិនបើគាត់មិនបានប្រព្រឹត្តអំពើទុច្ចរិតទេ យើងខ្ញុំនាំគាត់មកជូនលោកធ្វើអ្វី ! » ។

អ- [៣១]លោកពីឡាតមានប្រសាសន៍ ទៅគេថា៖

ឆ- «ចូរអ្នករាល់គ្នាយកគាត់ទៅវិនិច្ឆ័យទោស តាមវិន័យរបស់អ្នករាល់គ្នាទៅ !» ។

អ- ជនជាតិយូដាជំរាបទៅលោកវិញថា៖

ឆ- «យើងខ្ញុំគ្មានសិទ្ធិប្រហារជីវិតអ្នកណាសោះឡើយ» ។

អ- [៣២]គេនិយាយដូច្នេះ ស្របតាមសេចក្ដី ដែលព្រះយេស៊ូមានព្រះបន្ទូលអំពីរបៀបព្រះអង្គត្រូវសោយ
ទិវង្គត ។ [៣៣]លោកពីឡាតចូលទៅក្នុងបន្ទាយវិញ រួចហៅព្រះយេស៊ូមកសួរថា៖

ឆ- «តើអ្នកជាស្ដេចរបស់ជនជាតិយូដាមែនឬ ? » ។

អ- [៣៤]ព្រះយេស៊ូមានព្រះបន្ទូលតបថា៖

យ- «លោកមានប្រសាសន៍ដូច្នេះ តើមកពីគំនិតរបស់លោកផ្ទាល់ ឬមានអ្នកផ្សេងទៀតជំរាបលោក ?» ។

អ- [៣៥]លោកពីឡាតតបវិញថា៖

ឆ- «ខ្ញុំមិនមែនជាជនជាតិយូដាទេ! គឺជនជាតិរបស់អ្នក និងពួកនាយកបូជាចារ្យទេតើ ដែលបាន បញ្ជូនអ្នកមកខ្ញុំ តើអ្នកបានធ្វើអ្វី ? » ។

អ- [៣៦]ព្រះយេស៊ូមានព្រះបន្ទូលតបថា៖

យ- «រាជ្យរបស់ខ្ញុំមិនមែននៅក្នុងលោកនេះទេ ។ ប្រសិនបើរាជ្យរបស់ខ្ញុំនៅក្នុងលោកនេះមែន ពួកបំរើរបស់ខ្ញុំមុខជានាំគ្នាតយុទ្ធមិនឲ្យគេបញ្ជូនខ្ញុំទៅ ក្នុងកណ្ដាប់ដៃរបស់សាសន៍យូដាបានឡើយ ។ ប៉ុន្តែ រាជ្យរបស់ខ្ញុំ មិនមែននៅលោកនេះទេ» ។

អ- [៣៧]លោកពីឡាតទូលសួរព្រះអង្គថា៖

ឆ- «បើដូច្នេះ តើអ្នកជាស្ដេចមែនឬ ? » ។

អ- ព្រះយេស៊ូមានព្រះបន្ទូលតបថា៖

យ- «លោកទេតើ ដែលមានប្រសាសន៍ថា ខ្ញុំជាស្ដេច ។ ខ្ញុំកើតមក ហើយខ្ញុំមកក្នុងលោកនេះ ដើម្បីផ្ដល់សក្ខីភាពអំពីសេចក្ដីពិត អ្នកណាកើតពីសេចក្ដីពិត អ្នកនោះនឹងស្ដាប់សំឡេងខ្ញុំ» ។

អ- [៣៨]លោកពីឡាតទូលព្រះអង្គថា៖

ឆ- «អ្វីទៅសេចក្ដីពិតនោះ ? » ។

* * *

អ- លោកពីឡាតមានប្រសាសន៍ដូច្នោះហើយ លោកក៏ចេញទៅជួបជនជាតិយូដាជាថ្មីម្ដងទៀតប្រាប់ថា៖

ឆ- «ខ្ញុំពុំឃើញអ្នកនេះមានទោសអ្វីសោះឡើយ ។ [៣៩]តាមទំនៀមទម្លាប់របស់អ្នករាល់គ្នា ខ្ញុំត្រូវដោះលែងអ្នកទោសម្នាក់ក្នុងឱកាសបុណ្យចម្លង ។ តើអ្នករាល់គ្នាចង់ឲ្យខ្ញុំដោះលែងស្ដេចយូដាឬទេ? » ។

អ- [៤០]ពេលនោះ គេនាំគ្នាស្រែកឡើងសាជាថ្មីថា៖

ឆ- «កុំដោះលែងអ្នកនេះឡើយ សូមដោះលែងបារ៉ាបាសវិញ» ។

អ- រីឯឈ្មោះបារ៉ាបាសនេះជាចោរព្រៃ ។ ១៩ [១]ពេលនោះ លោកពីឡាតបង្គាប់ឲ្យទាហានយកព្រះយេស៊ូទៅវាយនឹងរំពាត់ ។ [២]ពួកទាហានយកបន្លាមកក្រងធ្វើជាមកុដបំពាក់ព្រះសិរសាព្រះអង្គ ហើយយកអាវពណ៌ក្រហមទុំមកពាក់ឲ្យព្រះអង្គដែរ ។ [៣]បន្ទាប់មក គេនាំគ្នាចូលទៅជិតព្រះអង្គទាំងពោលថា៖

ឆ- «ស្ដេចយូដាអើយ! សូមថ្វាយបង្គំ»

អ- ហើយក៏ទះកំផ្លៀងព្រះអង្គ ។

* * *

អ- [៤]លោកពីឡាតចេញទៅជួបជនជាតិយូដាសាជាថ្មី មានប្រសាសន៍ទៅគេថា៖

ឆ- «មើល៍! ខ្ញុំនាំគាត់មកខាងក្រៅ ដើម្បីឲ្យអ្នករាល់គ្នាដឹងថា ខ្ញុំពុំឃើញអ្នកនេះមានទោសអ្វីសោះ» ។

អ- [៥]ពេលនោះ ព្រះយេស៊ូយាងចេញមក ទាំងពាក់ភួងបន្លាជាមកុដ និងពាក់អាវពណ៌ក្រហមទុំផង ។ លោកពីឡាតមានប្រសាសន៍ទៅគេថា៖

ឆ- «មើល៍! មនុស្សហ្នឹងហើយ ! » ។

អ- [៦]កាលពួកនាយកបូជាចារ្យ និងកងរក្សាព្រះវិហារ*ឃើញព្រះអង្គគេនាំគ្នាស្រែកឡើងថា៖

ឆ- «ឆ្កាងទៅ ! ឆ្កាងទៅ ! » ។

អ- លោកពីឡាតមានប្រសាសន៍ថា៖
ឆ- «ចូរអ្នករាល់គ្នាយកគាត់ទៅឆ្កាងខ្លួនឯងទៅ ដ្បិតខ្ញុំពុំឃើញអ្នកនេះមានទោសអ្វីសោះ» ។
អ- ៧ជនជាតិយូដាជំរាបលោក ពីឡាតថា៖
ឆ- «យើងខ្ញុំមានវិន័យហើយតាមវិន័យនោះ ជននេះត្រូវតែស្លាប់ ព្រោះគាត់តាំងខ្លួនជាព្រះបុត្រារបស់ព្រះជាម្ចាស់» ។
អ- ៨កាលលោកពីឡាតឮដូច្នោះ លោករឹតតែភ័យខ្លាចថែមទៀត ។ ៩លោកចូលទៅក្នុងបន្ទាយវិញ សួរព្រះយេស៊ូថា៖
ឆ- «អ្នកមកពីណា ? » ។
អ- ព្រះយេស៊ូពុំបានឆ្លើយតបទៅលោកវិញសោះ ។ ១០ហេតុនេះលោកពីឡាតសួរព្រះអង្គថា៖
ឆ- «ម្ដេចក៏អ្នកមិននិយាយមកខ្ញុំដូច្នេះ ? អ្នកមិនដឹងថាខ្ញុំមានអំណាចដោះលែងអ្នកក៏បាន ឬឆ្កាងអ្នកក៏បានទេឬ ? » ។
អ- ១១ព្រះយេស៊ូមានព្រះបន្ទូលតបទៅគាត់ថា៖
យ- «ប្រសិនបើមិនបានទទួលអំណាចពីស្ថានលើមកទេ លោកគ្មានអំណាចលើខ្ញុំឡើយ ហេតុនេះហើយបានជាអ្នក ដែលចាប់បញ្ជូនខ្ញុំមកលោក មានបាបធ្ងន់ជាង លោកទៅទៀត» ។
អ- ១២តាំងពីពេលនោះមក លោកពីឡាតរកមធ្យោបាយដោះលែងព្រះយេស៊ូ ប៉ុន្តែ ជនជាតិយូដានាំគ្នាស្រែកឡើងថា៖
ឆ- «បើលោកដោះលែងជននេះ លោកមិនមែនជាមិត្តសម្លាញ់របស់ព្រះចៅអធិរាជឡើយ ដ្បិតអ្នកណាតាំងខ្លួនជាស្ដេច អ្នកនោះប្រឆាំងនឹងព្រះចៅអធិរាជ ! » ។
អ- ១៣កាលលោកពីឡាតឮពាក្យនេះ លោកនាំព្រះយេស៊ូទៅខាងក្រៅ ឲ្យគង់លើវេទិកាសំរាប់កាត់ក្ដី នៅត្រង់កន្លែងមួយឈ្មោះ “លានក្រាលថ្ម” ដែលគេហៅជាភាសាហេប្រឺថា “កាប្បាថា” ១៤ពេលនោះ ជាថ្ងៃ ដែលគេរៀបចំបុណ្យចម្លង ហើយប្រមាណជាពេលថ្ងៃត្រង់ ។ លោកពីឡាតមានប្រសាសន៍ទៅកាន់ជនជាតិយូដាថា៖
ឆ- «នេះនែ៎ ! ស្ដេចរបស់អ្នករាល់គ្នា! » ។
អ- ១៥ប៉ុន្តែ ជនជាតិយូដាស្រែកឡើងថា៖
ឆ- «សម្លាប់ចោលទៅ ! ឆ្កាងទៅ ! » ។
អ- លោកពីឡាតសួរពួកគេថា៖
ឆ- «ឲ្យខ្ញុំឆ្កាងស្ដេចរបស់អ្នករាល់គ្នាឬ ? » ។

អ-	ពួកនាយកបូជាចារ្យឆ្លើយឡើងថា៖
ឆ-	«ក្រៅពីព្រះចៅអធិរាជ យើងខ្ញុំគ្មានស្ដេចឯណាទៀតឡើយ» ។
អ-	[១៦]ពេលនោះ លោកពីឡាតប្រគល់ព្រះយេស៊ូទៅឲ្យគេឆ្កាង ។ គេនាំគ្នាចាប់ព្រះយេស៊ូយកទៅ ។

* * *

អ-	[១៧]ព្រះយេស៊ូលីឈើឆ្កាង ដោយផ្ទាល់ព្រះអង្គ ចេញពីទីក្រុងឆ្ពោះទៅកន្លែងមួយឈ្មោះ "ទួលលលាដ៍ក្បាល" ដែលគេហៅជាភាសាហេប្រឺថា "កុលកូថា" [១៨]គេឆ្កាងព្រះអង្គនៅទីនោះ ។ គេឆ្កាង
អ្នកទោសពីរនាក់ទៀតនៅសងខាងព្រះអង្គដែរ ព្រះយេស៊ូនៅកណ្ដាល ។ [១៩]លោកពីឡាតឲ្យគេ
សរសេរប្រកាសបោះភ្ជាប់នឹងឈើឆ្កាង ។ នៅលើប្រកាសនោះ មានសរសេរថា «យេស៊ូអ្នកភូមិណាសារ៉ែតជាស្ដេចយូដា» ។ [២០]ជនជាតិយូដាជាច្រើន បានមើលប្រកាសនោះ ដ្បិតកន្លែង ដែលគេ
ឆ្កាងព្រះយេស៊ូនៅក្បែរទីក្រុង ហើយប្រកាសនោះសរសេរជាអក្សរហេប្រឺ ឡាតាំង និងក្រិក ។ [២១]
ពួកនាយកបូជាចារ្យ របស់ជនជាតិយូដាជំរាបលោកពីឡាតថា៖
ឆ-	«សូមកុំសរសេរថា "ស្ដេចយូដា" ដូច្នេះ តែសរសេរថា "អ្នកនេះនិយាយថា ខ្ញុំជាស្ដេចយូដា" វិញ» ។
អ-	[២២]លោកពីឡាតមានប្រសាសន៍តបថា៖
ឆ-	«ខ្ញុំសរសេរយ៉ាងណាហើយ ត្រូវទុកយ៉ាងនោះទៅ ! » ។

* * *

អ-	[២៣]ក្រោយពីបានឆ្កាងព្រះយេស៊ូរួចហើយ ពួកទាហានយកសម្លៀកបំពាក់របស់ព្រះអង្គ មកធ្វើជាបួនចំណែកចែកគ្នាម្នាក់មួយចំណែកៗ ។ រីឯអាវវែងរបស់ព្រះអង្គវិញ ជាអាវធ្វើពីក្រណាត់តែមួយផ្ទាំង គ្មានថ្នេរសោះ តាំងពីលើដល់ក្រោម ។ ដូច្នេះ គេនិយាយគ្នាថា៖
ឆ-	[២៤]«កុំហែកអាវនេះធ្វើអ្វី យើងចាប់ឆ្នោតវិញ ដើម្បីឲ្យដឹងថាអាវនេះនឹងបានទៅលើអ្នកណា» ។
អ-	ពួកទាហានធ្វើដូច្នេះ ស្របតាមសេចក្ដី ដែលមានចែងទុកក្នុងគម្ពីរមកថា៖ «គេបានយកសម្លៀកបំពាក់របស់ទូលបង្គំចែកគ្នា ហើយចាប់ឆ្នោតយកអាវវែងរបស់ទូលបង្គំ» ។ [២៥]មាតាព្រះយេស៊ូ ប្អូន
ស្រីមាតាព្រះអង្គ នាងម៉ារី ជាភរិយាលោកក្លូប៉ាស និងនាងម៉ារី ជាអ្នកស្រុកម៉ាដាឡា ឈរក្បែរឈើឆ្កាងរបស់ព្រះអង្គ ។ [២៦]ព្រះយេស៊ូឃើញមាតា ព្រមទាំងសាវ័ក ដែលព្រះអង្គស្រឡាញ់ នោះ
ឈរនៅជិត ទ្រង់មានព្រះបន្ទូលទៅមាតាថា៖
យ-	«អ្នកអើយ ! នេះហើយកូនរបស់អ្នក» ។
អ-	[២៧]បន្ទាប់មក ព្រះអង្គមានព្រះបន្ទូលទៅសាវ័កថា៖

យ- «នេះហើយម្ដាយរបស់អ្នក» ។

អ- តាំងពីពេលនោះមក សាវ័កនោះយកគាត់មកនៅជាមួយ ។

* * *

អ- [២៨]បន្ទាប់មក ព្រះយេស៊ូជ្រាបថា ព្រះអង្គបានបង្ហើយកិច្ចការទាំងអស់ចប់សព្វគ្រប់ ព្រះអង្គមាន
ព្រះបន្ទូលថា៖

យ- «ខ្ញុំស្រេកទឹក»

អ- ព្រះអង្គមានព្រះបន្ទូលដូច្នេះ ដើម្បីឲ្យបានស្របតាមសេចក្ដីគ្រប់ប្រការ ដែលមានចែងទុកក្នុងគម្ពី
រ ។ [២៩]នៅទីនោះ មានក្រឡមួយមានទឹកខ្មេះពេញ ។ ពួកទាហានយកសារាយស្ងួត ជ្រលក់ទឹកខ្មេះ
ជោក រួចរុំនៅចុងត្រែងមួយដើម រុញទៅដល់ព្រះឱស្ឋរបស់ព្រះអង្គ ។ [៣០]កាលព្រះយេស៊ូសោយ
ទឹក ខ្មេះហើយ ព្រះអង្គមានព្រះបន្ទូលថា៖

យ- «ខ្ញុំបានសំរេចសព្វគ្រប់អស់ហើយ!» ។

អ- ព្រះអង្គក៏ឱនព្រះសិរសាចុះ ហើយប្រគល់វិញ្ញាណទៅ ។

*គ្រីស្តបរិស័ទអោនខ្លួន អធិដ្ឋានមួយរយៈពេល*

អ- [៣១]ថ្ងៃនោះជាថ្ងៃរៀបចំបុណ្យចម្លង ជនជាតិយូដាមិនចង់ឲ្យមានសាកសពជាប់នឹងឈើឆ្កាងនៅថ្ងៃស
ប្ប័ទ*ឡើយ ព្រោះថ្ងៃសប្ប័ទនោះ ជាថ្ងៃបុណ្យធំ ។ ហេតុនេះហើយបានជាគេសុំលោកពីឡាត
ចេញបញ្ជាទៅទាហាន ឲ្យបំបាក់ជើងអ្នកជាប់ឆ្កាង ហើយយកសាកសពចុះមក ។ [៣២]ពួកទាហាន
នាំគ្នាមកវាយបំបាក់ជើងអ្នកទោសទីមួយ និងអ្នកទោសទីពីរ ដែលជាប់លើឈើឆ្កាងជាមួយព្រះអ
ង្គ ។ [៣៣]លុះមកដល់ព្រះយេស៊ូ គេឃើញព្រះអង្គសោយទិវង្គតផុតទៅហើយ គេមិនបំបាក់ព្រះបាទា
ព្រះអង្គទេ [៣៤]ប៉ុន្តែ ទាហានម្នាក់យកលំពែងចាក់ត្រង់ចន្លោះឆ្អឹងជំនីរព្រះអង្គ ស្រាប់តែមានទឹក និង
លោហិតហូរចេញមកមួយរំពេច ។ [៣៥]សាវ័កម្នាក់ ដែលបាន ឃើញ ធ្វើជាបន្ទាល់អំពីហេតុការណ៍
នេះ ហើយសក្ខីភាពរបស់គាត់ពិតប្រាកដមែន ។ ព្រះអង្គដឹងថាសាវ័កនោះនិយាយសេចក្ដីពិត
ដើម្បីឲ្យអ្នករាល់គ្នាជឿដែរ ។ [៣៦]ហេតុការណ៍នេះកើតឡើង ស្របតាមសេចក្ដីដែលមានចែងទុក
ក្នុងគម្ពីរមកថា៖ «គ្មានឆ្អឹងណាមួយរបស់លោកត្រូវបាក់បែកឡើយ» ។ [៣៧]មានអត្ថបទគម្ពីរមួយ
ទៀតចែងថា៖ «គេនាំគ្នាមើលអ្នកដែលគេចាក់ទម្លុះ» ។

* * *

អ- [៣៨]បន្ទាប់មក លោកយ៉ូសែប ជាអ្នកស្រុកអរីម៉ាថេ បានទៅសុំច្បាប់លោកពីឡាត យកព្រះសពព្រះ
យេស៊ូ ។ លោកយ៉ូសែបនេះក៏ជាសាវ័ក របស់ព្រះយេស៊ូដែរតែមិនហ៊ានចេញមុខទេ ព្រោះខ្លាចជន

ជាតិយូដា ។ លោកពីឡាតអនុញ្ញាតឲ្យ ហើយលោកយ៉ូសែបក៏មកដោះព្រះសពយកទៅ ។ [៣៩]រីឯ
លោកនីកូដេម ដែលមកគាល់ព្រះយេស៊ូទាំងយប់កាលពីមុន ក៏បានមកដែរ ។ លោកយកជ័រល្វីង
ទេស លាយនឹងគ្រឿងក្រអូបប្រមាណជាកន្លះហាបមកផង ។ [៤០]លោកទាំងពីរយកព្រះសពព្រះ
យេស៊ូមករុំនឹងសំពត់ស្ដប អប់គ្រឿងក្រអូបតាមទំនៀមទម្លាប់ពិធីបញ្ចុះសពរបស់ជនជាតិយូដា ។
[៤១]នៅកន្លែងគេឆ្កាងព្រះយេស៊ូមានសួនឧទ្យានមួយ ក្នុងសួននោះមានផ្នូរមួយថ្មី ពុំទាន់ដែលដាក់សព
ណានៅឡើយ ។ [៤២]គេដាក់ព្រះយេស៊ូនៅក្នុងផ្នូរនោះ ព្រោះនៅជិតស្រាប់ ដ្បិតថ្ងៃនោះជាថ្ងៃ
រៀបចំបុណ្យចម្លង ។

# រដូវបុណ្យចម្លង

# ថ្ងៃអាទិត្យបុណ្យចម្លង រាត្រីបុណ្យចម្លង ឆ្នាំ ខ

## ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ

**អាលេលូយ៉ា! អាលេលូយ៉ា! អាលេលូយ៉ា!** សូមលើកតម្កើងព្រះយេស៊ូៗ ដែលទ្រង់បានឈ្នះសេចក្ដីស្លាប់ ចូរយើងទទួលដោយសប្បាយ ជីវិតថ្មីពីព្រះអម្ចាស់ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** ១៦,១-៨

១ពេលថ្ងៃសប្ប័ទផុតទៅហើយ នាងម៉ារី ជាអ្នកស្រុកម៉ាដាឡា នាងម៉ារី ជាម្ដាយយ៉ាកុប និងនាង
សាឡូមេ បានទិញគ្រឿងក្រអូប យកទៅអប់ព្រះសពព្រះយេស៊ូ ។ ២ព្រលឹមឡើងថ្ងៃអាទិត្យនាងនាំគ្នាធ្វើ
ដំណើរ ទៅកាន់ផ្នូរ នៅពេលថ្ងៃរះ ។ ៣ពួកនាងនិយាយគ្នាថា៖ «តើបាននរណាជួយប្រមៀលថ្មចេញពី
មាត់ផ្នូរឲ្យយើង?» ។ ៤ពេលស្ត្រីទាំងនោះងើបមុខឡើង ក៏ឃើញថ្មបានរមៀលចេញរួចស្រេចទៅ
ហើយ ថ្មនោះមានទំហំធំណាស់ ។ ៥នាងចូលទៅក្នុងផ្នូរ ឃើញកំឡោះម្នាក់អង្គុយខាងស្ដាំ មានសម្លៀក
បំពាក់ពណ៌ស ពួកនាងភ័យស្រឡាំងកាំង ។ ៦អ្នកនោះពោលមកកាន់នាងថា៖ «កុំភ័យស្រឡាំងកាំងធ្វើ
អ្វី! នាងនាំគ្នាមករកព្រះយេស៊ូ ជាអ្នកភូមិណាសារ៉ែតដែលគេបានឆ្កាង ព្រះជាម្ចាស់បានប្រោសព្រះអង្គ
ឲ្យមានព្រះជន្មថ្មីហើយ! ទ្រង់មិននៅទីនេះទេ មើលចុះទីនេះហើយដែលគេបានដាក់ព្រះសពព្រះអង្គ ។
៧ចូរនាងទៅប្រាប់សាវ័ករបស់ព្រះអង្គ ព្រមទាំងលោកសិលាផងថា “ព្រះអង្គយាងទៅស្រុកកាលីឡេមុន
អ្នករាល់គ្នា ។ នៅទីនោះអ្នករាល់គ្នានឹងឃើញព្រះអង្គ ដូចទ្រង់មានព្រះបន្ទូលទុកស្រាប់”» ។ ៨ស្ត្រីទាំង
នោះក៏ចាកចេញពីផ្នូរ ហើយរត់ទៅ ទាំងញ័ររន្ធត់ ស្លុតស្មារតី ។ នាងពុំបាននិយាយរឿងនេះប្រាប់អ្នក
ណាសោះ ព្រោះនាងភ័យខ្លាំងពេក ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យបុណ្យចម្លង អភិបូជានៅពេលថ្ងៃ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម យហ ១៣,៣៤

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះគ្រីស្តដែលជាយញ្ញបូជារបស់យើងក្នុងឱកាសបុណ្យចម្លង បានបូជាព្រះជន្មរួចស្រេចទៅហើយ! យើងនាំគ្នាបរិភោគយ៉ាងសប្បាយ នៅពិធីជប់លៀងរបស់ព្រះអម្ចាស់! **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** ២០,១-៩

[1]នៅព្រឹកថ្ងៃអាទិត្យ កាលនៅងងឹតនៅឡើយ នាងម៉ារី ជាអ្នកស្រុកម៉ាដាឡា ចេញដំណើរឆ្ពោះទៅ
ផ្នូរ ហើយឃើញថា មានគេយកថ្មពីមាត់ផ្នូរផុតទៅហើយ ។ [2]នាងក៏រត់មកជំរាបលោកស៊ីម៉ូនសិលា
និងសាវ័កម្នាក់ទៀតដែលព្រះយេស៊ូស្រឡាញ់ថា៖ «គេយកព្រះអម្ចាស់ចេញពីផ្នូរបាត់ហើយ យើងមិន
ដឹងជាគេយកដាក់ឯណាទេ!» ។ [3]លោកសិលានិងសាវ័កម្នាក់ទៀតនោះ ក៏ចេញទៅផ្នូរ ។ [4]សាវ័កទាំង
ពីររត់ទៅជាមួយគ្នាតែសាវ័កម្នាក់នោះរត់លឿនជាងលោកសិលា ទៅដល់ផ្នូរមុន ។ [5]គាត់ឈ្ងោកមើល
ទៅឃើញ សំពត់ស្នប តែគាត់មិនបានចូលទៅក្នុងផ្នូរឡើយ ។ [6]លោកស៊ីម៉ូនសិលារត់តាមក្រោយ មក
ដល់ គាត់ចូលទៅក្នុងផ្នូរ ហើយសម្លឹងមើលសំពត់ស្នបនៅទីនោះ [7]ព្រមទាំងក្រណាត់ដែលគេ គ្របព្រះ
សិរសាព្រះអង្គ មូរទុកដោយឡែក គឺមិននៅជាមួយសំពត់ស្នបទេ ។ [8]ពេលនោះ សាវ័កដែលទៅដល់
ផ្នូរមុន ក៏ចូលទៅខាងក្នុងដែរ គាត់បានឃើញហើយជឿ ។ [9]កាលណោះ ក្រុមសាវ័កពុំទាន់យល់អត្ថន័យ
គម្ពីរដែលចែងទុកមកថា ព្រះយេស៊ូត្រូវមានព្រះជន្មរស់ឡើងវិញនៅឡើយទេ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២ ក្នុងរដូវបុណ្យចម្លង ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម យហ ២០,២៩

**អាលេលូយ៉ា! អាលេលូយ៉ា!** លោកថូម៉ាសបានឃើញព្រះអម្ចាស់ហើយបានជឿ ។
អ្នកជឿដោយឥតបានឃើញ ពិតជាមានសុភមង្គលហើយ! **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** ២០,១៩-៣១

១៩នៅល្ងាចថ្ងៃអាទិត្យក្រោយព្រះយេស៊ូសោយទិវង្គត ក្រុមសាវ័កនៅក្នុងផ្ទះ ខ្ទាស់ទ្វារយ៉ាងជាប់
ព្រោះខ្លាចជនជាតិយូដា ។ ស្រាប់តែព្រះយេស៊ូយាងមកឈរនៅកណ្ដាលចំណោមពួកគេ ហើយមានព្រះ
បន្ទូលថា៖ «សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខសាន្ត!» ។ ២០ព្រះអង្គមានព្រះបន្ទូលដូច្នេះ
ទាំងបង្ហាញស្នាមរបួសនៅព្រះហស្ត និងនៅត្រង់ឆ្អឹងជំនីរឲ្យគេឃើញផង ។ ក្រុមសាវ័កសប្បាយចិត្តជា
ខ្លាំង ដោយបានឃើញព្រះអម្ចាស់ ។ ២១ព្រះយេស៊ូមានព្រះបន្ទូលទៅគេសាជាថ្មីថា៖ «សូមឲ្យអ្នករាល់
គ្នាបានប្រកបដោយសេចក្ដីសុខសាន្ត! ដូចព្រះបិតាបានចាត់ខ្ញុំឲ្យមកយ៉ាងណា ខ្ញុំចាត់អ្នករាល់គ្នាឲ្យទៅ
យ៉ាងនោះដែរ» ។

២២បន្ទាប់ពីមានព្រះបន្ទូលហើយ ព្រះអង្គផ្លុំលើពួកគេ ទាំងមានព្រះបន្ទូលថា៖ «ចូរទទួលព្រះ
វិញ្ញាណ! ។ ២៣បើអ្នករាល់គ្នាលើកលែងទោសអ្នកណាឲ្យរួចពីបាប ព្រះជាម្ចាស់ក៏នឹងលើកលែងទោស
អ្នកនោះឲ្យរួចពីបាបដែរ ។ ផ្ទុយទៅវិញ បើអ្នករាល់គ្នាប្រកាន់ទោសអ្នកណា អ្នកនោះមុខជាត្រូវជាប់
ទោសមិនខាន» ។

២៤កាលព្រះយេស៊ូយាងមកនោះ លោកថូម៉ាសហៅឌីឌីម ជាសាវ័កម្នាក់ក្នុងចំណោមសាវ័កទាំងដប់
ពីរ មិនបាននៅជាមួយពួកគេទេ ។ ២៥សាវ័កឯទៀតៗប្រាប់គាត់ថា៖ «យើងបានឃើញព្រះអម្ចាស់» ។
ប៉ុន្តែ គាត់និយាយទៅពួកគេវិញថា៖ «បើខ្ញុំមិនឃើញស្នាមដែកគោលនៅបាតដៃ មិនបានដាក់ម្រាមដៃ
ក្នុងស្នាមដែកគោល ហើយបើខ្ញុំមិនបានដាក់ដៃត្រង់ឆ្អឹងជំនីររបស់លោកទេ ខ្ញុំមិនជឿជាដាច់ខាត» ។
២៦ប្រាំបីថ្ងៃក្រោយមក ក្រុមសាវ័កជួបជុំគ្នានៅក្នុងផ្ទះសាជាថ្មី លោកថូម៉ាសក៏នៅជាមួយដែរ ។
ពេលនោះ ទ្វារផ្ទះនៅខ្ទាស់ជាប់ ព្រះយេស៊ូយាងមកឈរនៅកណ្ដាលចំណោមពួកគេទាំងមានព្រះបន្ទូល
ថា៖ «សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខសាន្ត!» ។ ២៧បន្ទាប់មក ព្រះអង្គមានព្រះបន្ទូល
ទៅលោកថូម៉ាសថា៖ «មើលដៃខ្ញុំនេះចូរដាក់ម្រាមដៃអ្នកមក ហើយដាក់ដៃអ្នកត្រង់ឆ្អឹងជំនីរខ្ញុំ ។ ចូរ

ជឿទៅ! កុំរឹងរូសមិនព្រមជឿដូច្នេះ!» ។ [២៨]លោកថូម៉ាសទូលព្រះអង្គថា៖ «ព្រះអង្គពិតជាព្រះអម្ចាស់
និងជាព្រះរបស់ទូលបង្គំមែន!» ។ [២៩]ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «អ្នកជឿមកពីអ្នកបាន
ឃើញខ្ញុំ អ្នកណាជឿដោយឥតបានឃើញសោះ អ្នកនោះមានសុភមង្គលហើយ!» ។
[៣០]ព្រះយេស៊ូបានធ្វើទីសំគាល់ជាច្រើនទៀតឲ្យក្រុមសាវ័កឃើញ តែគ្មានកត់ត្រាទុកក្នុងសៀវភៅនេះ
ទេ ។ [៣១]រីឯសេចក្ដីដែលមានកត់ត្រាមកនេះ គឺក្នុងគោលបំណងឲ្យអ្នករាល់គ្នាជឿថា ព្រះយេស៊ូពិតជា
ព្រះគ្រីស្ដនិងពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយឲ្យអ្នករាល់គ្នាដែលជឿ មានជីវិតដោយរួមជាមួយ
ព្រះអង្គ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៣ ក្នុងរដូវបុណ្យចម្លង ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ**

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះអម្ចាស់ដែលមានព្រះជន្មរស់ឡើងវិញ
បង្ហាញព្រះអង្គឲ្យក្រុមគ្រីស្តទូតឃើញ ហើយទ្រង់ប្រទានសេចក្តីសុខសាន្ត
ឲ្យអស់លោកផង ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត លូកា** ២៤,៣៥-៤៨

[៣៥]សាវ័កទាំងពីរនាក់រៀបរាប់ ហេតុការណ៍ដែលកើតឡើងនៅតាមផ្លូវ ហើយគេបានស្គាល់ព្រះអង្គ
នៅពេលព្រះអង្គកាច់នំប៉័ង ។
[៣៦]នៅពេល សាវ័កទាំងពីរនាក់កំពុងតែនិយាយរៀបរាប់ ព្រះអម្ចាស់យាង
មកគង់នៅកណ្តាលចំណោមសាវ័កទាំងអស់ ហើយមានព្រះបន្ទូលថា៖ «សូមឲ្យអ្នករាល់គ្នាប្រកបដោយ
សេចក្តីសុខសាន្ត
[៣៧]គេភ័យតក់ស្លុតញ័ររន្ធត់យ៉ាងខ្លាំង ព្រោះស្មានថាខ្មោចលង ។
[៣៨]ព្រះយេស៊ូមានព្រះ
បន្ទូលថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នារន្ធត់ចិត្តដូច្នេះ? ម្តេចក៏អ្នករាល់គ្នានៅសង្ស័យ?
[៣៩]ចូរមើលដៃ
ជើងខ្ញុំ គឺពិតជាខ្ញុំមែន! ចូរស្ទាបមើល៍ខ្មោចគ្មានសាច់គ្មានឆ្អឹងដូចខ្ញុំទេ» ។
[៤០]ព្រះអង្គមានព្រះបន្ទូល
ដូច្នោះហើយ ក៏បង្ហាញព្រះហស្ត និង ព្រះបាទាឲ្យគេឃើញ ។
[៤១]សាវ័កពុំទាន់ជឿនៅឡើយទេ ព្រោះគេ
អរផងហើយងឿងឆ្ងល់ផង ។ ដូច្នេះព្រះយេស៊ូមានព្រះបន្ទូលសួរគេថា៖ «នៅទីនេះ តើអ្នករាល់គ្នាមាន
អ្វីបរិភោគឬទេ?» ។
[៤២]គេយកត្រីអាំងមួយដុំមកថ្វាយព្រះអង្គ
[៤៣]ព្រះអង្គទទួលយក ហើយសោយនៅ
មុខពួកគេទាំងអស់គ្នា ។
[៤៤]បន្ទាប់មកព្រះអង្គមានព្រះបន្ទូលថា៖ «កាលខ្ញុំនៅជាមួយអ្នករាល់គ្នានៅ
ឡើយ ខ្ញុំបាននិយាយប្រាប់អ្នករាល់គ្នាថា សេចក្តីទាំងអស់ដែលមានចែងទុកអំពីខ្ញុំ ក្នុងធម្មវិន័យរបស់
លោកម៉ូសេក្នុងគម្ពីរព្យាការី និងក្នុងគម្ពីរទំនុកតម្កើង ត្រូវតែកើតមាន» ។
[៤៥]ព្រះអង្គក៏បំភ្លឺចិត្តគំនិតគេ
ឲ្យយល់អត្ថន័យគម្ពីរ
[៤៦]ព្រះអង្គមានព្រះបន្ទូលថា៖ «ហេតុការណ៍នេះកើតឡើង ស្របតាមសេចក្តីដែល
មានចែងទុកក្នុងគម្ពីរមែន គឺព្រះគ្រីស្ត*ត្រូវរងទុក្ខលំបាក ហើយមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបី ។
[៤៧] អ្នករាល់គ្នាត្រូវប្រកាសក្នុងព្រះនាមព្រះអង្គ ឲ្យមនុស្សគ្រប់ជាតិសាសន៍កែប្រែចិត្តគំនិត ដើម្បីឲ្យបាន
រួចពីបាប គឺត្រូវប្រកាសចាប់តាំងពីក្រុងយេរូសាឡឹមតទៅ ។
[៤៨]អ្នករាល់គ្នាជាសាក្សីអំពីហេតុការណ៍ទាំង
នេះ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៤ ក្នុងរដូវបុណ្យចម្លង ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម យហ ១០,១៤-១៥**

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះយេស៊ូជាគង្វាលដ៏ល្អប្រសើរ! ព្រះអង្គស្គាល់ចៀមរបស់ព្រះអង្គ ហើយចៀមក៏ស្គាល់ព្រះអង្គដែរ ។ ព្រះអង្គស៊ូប្ដូរជីវិតដើម្បីចៀមរបស់ព្រះអង្គ ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** **១០,១១-១៨**

ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ជនជាតិយូដាថា៖ «[១១]ខ្ញុំហ្នឹងហើយជាគង្វាលដ៏ល្អ គង្វាលដ៏ល្អតែងតែស៊ូប្ដូរជីវិត ដើម្បីចៀមរបស់ខ្លួន ។ [១២]រីឯអ្នកស៊ីឈ្នួលវិញ កាលគេឃើញចចកមកដល់ គេរត់បោលចៀម ទុកឲ្យចចកខាំអូសយកទៅ ហើយដេញកំចាត់កំចាយជាមិនខាន ពីព្រោះអ្នកនោះមិនមែនជាគង្វាល ហើយក៏មិនមែនជាម្ចាស់របស់ចៀមផង ។ [១៣]អ្នកនោះមិនខ្វល់ខ្វាយនឹងចៀមឡើយ ព្រោះគេគ្រាន់តែស៊ីឈ្នួលប៉ុណ្ណោះ ។ ខ្ញុំហ្នឹងហើយជាគង្វាលដ៏ល្អ ។ [១៤]ខ្ញុំស្គាល់ចៀមរបស់ខ្ញុំ ចៀមរបស់ខ្ញុំក៏ស្គាល់ខ្ញុំ [១៥]គឺដូចព្រះបិតាស្គាល់ខ្ញុំ ហើយខ្ញុំស្គាល់ព្រះបិតាដូច្នោះដែរ ។ ខ្ញុំស៊ូប្ដូរជីវិតដើម្បីចៀមរបស់ខ្ញុំ ។ [១៦]ខ្ញុំមានចៀមឯទៀតៗ ដែលមិននៅក្នុងក្រោលនេះទេ ។ ខ្ញុំត្រូវតែនាំចៀមទាំងនោះមកដែរ ។ ចៀមទាំងនោះនឹងស្ដាប់សំឡេងខ្ញុំ ហើយនៅពេលនោះ នឹងមានហ្វូងចៀមតែមួយ មានគង្វាលតែមួយ ។ [១៧]ព្រះបិតាស្រឡាញ់ខ្ញុំ ព្រោះខ្ញុំសុខចិត្តស៊ូប្ដូរជីវិត ដើម្បីឲ្យបានជីវិតនោះមកវិញ ។ [១៨]គ្មាននរណាដកហូតជីវិតរបស់ខ្ញុំបានឡើយ គឺខ្ញុំស៊ូប្ដូរជីវិតដោយខ្លួនខ្ញុំផ្ទាល់តែម្ដង ។ ខ្ញុំមានអំណាចនឹងស៊ូប្ដូរជីវិតរបស់ខ្ញុំ ហើយខ្ញុំក៏មានអំណាចនឹងយកជីវិតនោះមកវិញ តាមព្រះបញ្ជាដែលខ្ញុំបានទទួលពីព្រះបិតាមក» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៥ ក្នុងរដូវបុណ្យចម្លង ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម ទន ១,៣

**អាលេលូយ៉ា! អាលេលូយ៉ា!** អ្នកណារួមរស់ជាមួយព្រះអម្ចាស់ អ្នកនោះប្រៀបដូច
ដើមឈើដុះក្បែរទឹក ដែលឲ្យផលផ្លែតាមរដូវកាល ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** ១៥,១-៨

នៅពេលកំណត់ដែលព្រះយេស៊ូត្រូវឆ្លងពីលោកនេះ ឆ្ពោះទៅព្រះបិតា ព្រះអង្គមានព្រះបន្ទូលទៅ
កាន់ក្រុមសាវ័កថា៖ ១«ខ្ញុំហ្នឹងហើយជាដើមទំពាំងបាយជូរដ៏ពិតប្រាកដ រីឯព្រះបិតាខ្ញុំជាម្ចាស់ចម្ការ ។
២មែកណានៅជាប់នឹងខ្ញុំ តែឥតមានផ្លែ ព្រះបិតាកាត់មែកនោះចោល ។ រីឯមែកណាមានផ្លែ ព្រះអង្គ
លួសមែកនោះ ដើម្បីឲ្យមានផ្លែកាន់តែច្រើនឡើងទៀត ។ ៣ពាក្យដែលខ្ញុំបានប្រាប់ ធ្វើឲ្យអ្នករាល់គ្នា
បរិសុទ្ធរួចទៅហើយ ។ ៤ចូរស្ថិតនៅជាប់នឹងខ្ញុំ ដូចខ្ញុំស្ថិតនៅជាប់នឹងអ្នករាល់គ្នាដែរ ។ ប្រសិនបើមែក
មិនស្ថិតនៅជាប់នឹងដើមទេ វាពុំអាចបង្កើតផលដោយឯកឯងឡើយ ។ រីឯអ្នករាល់គ្នាក៏ដូច្នោះដែរ បើ
មិនស្ថិតនៅជាប់នឹងខ្ញុំទេ អ្នករាល់គ្នាពុំអាចបង្កើតផលបានទាល់តែសោះ ។ ៥ខ្ញុំនេះហើយជាដើម
ទំពាំងបាយជូរ អ្នករាល់គ្នាជាមែក អ្នកណាស្ថិតនៅជាប់នឹងខ្ញុំ ហើយខ្ញុំនៅជាប់នឹងអ្នកនោះ ទើបអ្នក
នោះបង្កើតផលបានច្រើន ។ បើដាច់ពីខ្ញុំ អ្នករាល់គ្នាពុំអាចធ្វើអ្វីកើតឡើយ ។ ៦អ្នកណាមិនស្ថិតនៅជាប់
នឹងខ្ញុំ អ្នកនោះប្រៀបដូចជាមែក ដែលគេបោះចោលទៅខាងក្រៅ ហើយស្វិតក្រៀម ។ បន្ទាប់មក គេ
រើសមែកទាំងនោះបោះទៅក្នុងភ្លើងឆេះអស់ទៅ ។ ៧បើអ្នករាល់គ្នាស្ថិតនៅជាប់នឹងខ្ញុំ ហើយបើពាក្យខ្ញុំ
ស្ថិតនៅជាប់នឹងអ្នករាល់គ្នា ចូរទូលសុំអ្វីៗតាមតែអ្នករាល់គ្នាប្រាថ្នាចង់បានចុះ នោះអ្នករាល់គ្នាមុខតែ
បានទទួលជាមិនខាន ។ ៨ព្រះបិតារបស់ខ្ញុំសម្តែងសិរីរុងរឿង ដោយអ្នករាល់គ្នាបង្កើតផលផ្លែបានច្រើន
និងដោយអ្នករាល់គ្នាជាសិស្សរបស់ខ្ញុំមែន» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៦ ក្នុងរដូវបុណ្យចម្លង ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម យហ ១៣,៣៤

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះអម្ចាស់ផ្ដាំឲ្យកាន់វិន័យថ្មីគឺ "អ្នករាល់គ្នា ត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ" ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** ១៥,៩-១៧

នៅពេលកំណត់ដែលព្រះយេស៊ូត្រូវឆ្លងពីលោកនេះ ឆ្ពោះទៅព្រះបិតា ព្រះអង្គមានព្រះបន្ទូលទៅ
កាន់ក្រុមសាវ័កថា៖ ⁹«ខ្ញុំបានស្រឡាញ់អ្នករាល់គ្នា ដូចព្រះបិតាស្រឡាញ់ខ្ញុំដែរ ។ ចូរទុកសេចក្ដី
ស្រឡាញ់របស់ខ្ញុំឲ្យស្ថិតនៅជាប់នឹងអ្នករាល់គ្នាចុះ ។ ¹⁰បើអ្នករាល់គ្នាប្រតិបត្តិតាមវិន័យរបស់ខ្ញុំ អ្នករាល់
គ្នាពិតជាទុកសេចក្ដីស្រឡាញ់របស់ខ្ញុំ ឲ្យស្ថិតនៅជាប់នឹងអ្នករាល់គ្នាមែន ដូចខ្ញុំប្រតិបត្តិតាមវិន័យរបស់
ព្រះបិតា ហើយទុកឲ្យសេចក្ដីស្រឡាញ់របស់ព្រះអង្គស្ថិតនៅជាប់នឹងខ្ញុំដែរ ។ ¹¹ខ្ញុំបាននិយាយសេចក្ដី
ទាំងនេះប្រាប់អ្នករាល់គ្នា ដើម្បីឲ្យអំណររបស់ខ្ញុំស្ថិតនៅក្នុងអ្នករាល់គ្នា ហើយដើម្បីឲ្យអ្នករាល់គ្នាមាន
អំណរពេញលក្ខណៈ ។
¹²វិន័យរបស់ខ្ញុំ មានដូចតទៅនេះ គឺអ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នក
រាល់គ្នាដែរ ។ ¹³គ្មាននរណាមានសេចក្ដីស្រឡាញ់ ខ្លាំងជាងអ្នកដែលស៊ូប្ដូរជីវិត ដើម្បីមិត្តសំឡាញ់របស់
ខ្លួននោះឡើយ ។ ¹⁴បើអ្នករាល់គ្នាប្រព្រឹត្តតាមសេចក្ដីដែលខ្ញុំបានបង្គាប់មក អ្នករាល់គ្នាពិតជាមិត្តសំ
ឡាញ់របស់ខ្ញុំមែន ។ ¹⁵ខ្ញុំមិនចាត់ទុកអ្នករាល់គ្នាជាអ្នកបម្រើទៀតទេ ព្រោះអ្នកបម្រើមិនយល់កិច្ចការ
ដែលម្ចាស់របស់ខ្លួនប្រព្រឹត្តនោះឡើយ ។ ខ្ញុំចាត់ទុកអ្នករាល់គ្នាជាមិត្តសំឡាញ់ ដ្បិតអ្វីៗដែលខ្ញុំបានឮពី
ព្រះបិតាមក ខ្ញុំក៏បានប្រាប់ឲ្យអ្នករាល់គ្នាដឹងហើយដែរ ។ ¹⁶មិនមែនអ្នករាល់គ្នាទេ ដែលបានជ្រើសរើស
ខ្ញុំ គឺខ្ញុំទេតើដែលបានជ្រើសរើសអ្នករាល់គ្នា ហើយបានតែងតាំងអ្នករាល់គ្នាឲ្យទៅ និងបង្កើតផល ព្រម
ទាំងឲ្យផលរបស់អ្នករាល់គ្នានៅស្ថិតស្ថេរ ។ ដូច្នេះ អ្វីៗដែលអ្នករាល់គ្នាទូលសូមពីព្រះបិតាក្នុងនាមខ្ញុំ
ព្រះអង្គនឹងប្រទានឲ្យអ្នករាល់គ្នាពុំខាន ។ ¹⁷រីឯសេចក្ដីដែលខ្ញុំបង្គាប់អ្នករាល់គ្នានោះ គឺត្រូវស្រឡាញ់គ្នា
ទៅវិញទៅមក» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# បុណ្យព្រះអម្ចាស់យាងឡើងស្ថានបរមសុខ ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ**

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះអម្ចាស់យាងឡើង ប្រជាជនស្រែកជ័យឃោសន៍ ។
ព្រះអង្គយាងឡើងទៅទីដ៏ខ្ពង់ខ្ពស់បំផុត ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** **១៦,១៥-២០**

ព្រះយេស៊ូដែលក្រោកឈរឡើងពីចំណោមមនុស្សស្លាប់ [១៥]មានព្រះបន្ទូលទៅកាន់ក្រុមសាវ័កថា៖
«ចូរនាំគ្នាទៅគ្រប់ទីកន្លែងក្នុងពិភពលោក ហើយប្រកាសដំណឹងល្អដល់មនុស្សលោកទាំងអស់ចុះ ។
[១៦]អ្នកណាជឿ ហើយទទួលពិធីជ្រមុជទឹក ព្រះជាម្ចាស់នឹងសង្គ្រោះអ្នកនោះ រីឯអ្នកដែលមិនព្រមជឿ
នឹងត្រូវទទួលទោស ។ [១៧]អស់អ្នកដែលជឿនឹងធ្វើទីសម្គាល់ទាំងនេះ គឺគេនឹងដេញខ្មោចក្នុងនាមខ្ញុំ គេ
និយាយភាសាថ្មី ។ [១៨]ប្រសិនបើគេកាន់ពស់ ឬផឹកអ្វីដែលមានជាតិពុល ក៏គេពុំមានគ្រោះថ្នាក់អ្វីដែរ ។
ប្រសិនបើគេដាក់ដៃលើអ្នកជំងឺ អ្នកជំងឺនឹងបានជាសះស្បើយ» ។

[១៩]កាលព្រះអម្ចាស់យេស៊ូមានព្រះបន្ទូលទាំងនេះរួចហើយ ព្រះជាម្ចាស់លើកព្រះអង្គឡើងទៅស្ថាន
បរមសុខ ឲ្យគង់នៅខាងស្ដាំព្រះអង្គ ។ [២០]ក្រុមសាវ័កនាំគ្នាចេញទៅប្រកាសដំណឹងល្អនៅគ្រប់ទីកន្លែង ។
ព្រះអម្ចាស់ធ្វើការរួមជាមួយគេ ទាំងបញ្ជាក់ព្រះបន្ទូលដោយសម្ដែងទីសម្គាល់ផ្សេងៗជាប់ជាមួយផង ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៧ ក្នុងរដូវបុណ្យចម្លង ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម យហ ១៤,១៨**

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះអម្ចាស់មិនបោលអ្នករាល់គ្នាឲ្យនៅកំព្រាឡើយ!
ព្រះអង្គនឹងយាងមករកអ្នករាល់គ្នាវិញ ។ នៅពេលនោះ អ្នករាល់គ្នានឹងមានអំណរសប្បាយ ។
**អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** **១៧,១១-១៩**

នៅពេលកំណត់ដែលព្រះយេស៊ូត្រូវឆ្លងពីលោកនេះ ឆ្ពោះទៅព្រះបិតា ព្រះអង្គងើបព្រះភ័ក្ត្រទតទៅ
លើមេឃ ហើយមានព្រះបន្ទូលថា៖ ១១«ឱព្រះបិតាដ៏វិសុទ្ធអើយ! សូមថែរក្សាអ្នកទាំងនោះ ដោយ
ព្រះនាមព្រះអង្គផង គឺព្រះនាមនេះហើយ ដែលព្រះអង្គបានប្រទានមកទូលបង្គំ ដើម្បីឲ្យគេរួមគ្នាជាអង្គ
តែមួយ ដូចយើងជាអង្គតែមួយដែរ ។ ១២កាលទូលបង្គំនៅជាមួយអ្នកទាំងនោះ ទូលបង្គំបានថែរក្សាគេ
ដោយព្រះនាមដែលព្រះអង្គបានប្រទានមកទូលបង្គំ ។ ទូលបង្គំបានការពារគេ ហើយគ្មាននរណាត្រូវ
វិនាសបាត់បង់ឡើយ លើកលែងតែម្នាក់ដែលត្រូវវិនាស ស្របតាមសេចក្តីដែលមានចែងទុកក្នុងគម្ពីរ
ប៉ុណ្ណោះ ។ ១៣ឥឡូវនេះ ទូលបង្គំទៅឯព្រះអង្គ ។ ទូលបង្គំនិយាយដូច្នេះ ពេលទូលបង្គំនៅក្នុងលោកនេះ
នៅឡើយ ដើម្បីឲ្យគេមានអំណររបស់ទូលបង្គំ ជាអំណរដ៏ពេញលក្ខណៈ ។ ១៤ទូលបង្គំបានប្រទានព្រះ
បន្ទូលរបស់ព្រះអង្គឲ្យគេ តែមនុស្សលោកស្អប់គេ ពីព្រោះគេមិនកើតពីលោកីយ៍ទេ ដូចជាទូលបង្គំមិន
កើតពីលោកីយ៍នេះដែរ ។ ១៥ទូលបង្គំមិនអង្វរព្រះអង្គឲ្យយកគេចេញពីលោកនេះឡើយ គឺសូមទ្រង់
មេត្តាការពារគេពីអំណាចមារកំណាចវិញ ។ ១៦គេមិនកើតពីលោកីយ៍ទេ ដូចទូលបង្គំមិនកើតពីលោកីយ៍
នេះដែរ ។

១៧សូមប្រោសគេឲ្យវិសុទ្ធ ដោយសារសេចក្តីពិត គឺព្រះបន្ទូលរបស់ព្រះអង្គនោះហើយជា
សេចក្តីពិត ។ ១៨ទូលបង្គំចាត់គេឲ្យទៅក្នុងលោក ដូចព្រះអង្គបានចាត់ទូលបង្គំឲ្យមកក្នុងលោកដែរ ។
១៩រីឯទូលបង្គំវិញ ទូលបង្គំបូជាជីវិតថ្វាយព្រះអង្គជាប្រយោជន៍ដល់គេ ដើម្បីឲ្យគេបានវិសុទ្ធ ដោយសារ
សេចក្តីពិត ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# បុណ្យលើកតម្កើងព្រះវិញ្ញាណយាងមក ឆ្នាំ ខ

## ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ

**អាលេលូយ៉ា! អាលេលូយ៉ា!** ឱ! ព្រះវិញ្ញាណដ៏វិសុទ្ធ! សូមយាងមក!
សូមជ្រួតជ្រាបចិត្តគំនិតអ្នកបម្រើព្រះអង្គ!
សូមប្រោសប្រទានសេចក្ដីស្រឡាញ់របស់ព្រះអង្គឲ្យយើងខ្ញុំផង! ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** **១៥,២៦-២៧ ; ១៦,១២-១៥**

នៅពេលកំណត់ដែលព្រះយេស៊ូត្រូវឆ្លងពីលោកនេះឆ្ពោះទៅព្រះបិតា ព្រះអង្គមានព្រះបន្ទូលទៅកាន់
ក្រុមសាវ័កថា៖ [២៦]«ព្រះអង្គដែលជួយការពារ គឺជាព្រះវិញ្ញាណដែលសំដែងសេចក្ដីពិត ខ្ញុំនឹងចាត់ព្រះ
អង្គនេះពីព្រះបិតាឲ្យមករកអ្នករាល់គ្នា ព្រះអង្គចេញពីព្រះបិតាមក ។ កាលណាព្រះអង្គយាងមកដល់
ទ្រង់នឹងធ្វើជាសាក្សីអំពីខ្ញុំ [២៧]ហើយអ្នករាល់គ្នាក៏ធ្វើជាសាក្សីអំពីខ្ញុំដែរ ពីព្រោះអ្នករាល់គ្នានៅជាមួយខ្ញុំ
តាំងពីដើមរៀងមក ។

[១២]ខ្ញុំមានសេចក្ដីឯទៀតៗជាច្រើន ដែលត្រូវនិយាយប្រាប់អ្នករាល់គ្នា តែអ្នករាល់គ្នាពុំអាចទទួលនៅ
ពេលនេះបានទេ ។ [១៣]កាលណាព្រះវិញ្ញាណនៃសេចក្ដីពិតយាងមកដល់ ព្រះអង្គនឹងណែនាំអ្នករាល់គ្នាឲ្យ
ស្គាល់សេចក្ដីពិតគ្រប់ចំពូក ដ្បិតសេចក្ដីផ្សេងៗដែលព្រះអង្គថ្លែង មិនចេញមកពីព្រះអង្គផ្ទាល់ទេ គឺព្រះ
អង្គថ្លែងតែសេចក្ដីណាដែលទ្រង់ព្រះសណ្ដាប់ឮ ព្រមទាំងមានព្រះបន្ទូលប្រាប់ឲ្យអ្នករាល់គ្នាដឹង អំពី
ហេតុការណ៍ ដែលត្រូវកើតមាននៅថ្ងៃមុខផង ។ [១៤]ព្រះអង្គនឹងសម្ដែងសិរីរុងរឿងរបស់ខ្ញុំ ព្រោះព្រះអង្គ
ទទួលសេចក្ដីទាំងអស់ពីខ្ញុំ យកមកប្រាប់អ្នករាល់គ្នា ។ [១៥]អ្វីៗដែលព្រះបិតាមានទាំងប៉ុន្មាន សុទ្ធតែជា
របស់ខ្ញុំទាំងអស់ ។ ហេតុនេះហើយ បានជាខ្ញុំពោលថា ព្រះអង្គទទួលសេចក្ដីទាំងអស់ពីខ្ញុំ យកមកប្រាប់
អ្នករាល់គ្នា» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# រដូវធម្មតា

# បុណ្យលើកតម្កើងព្រះត្រៃឯក ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** វវ ១,៨

**អាលេលូយ៉ា! អាលេលូយ៉ា!** សូមលើកតម្កើងសិរីរុងរឿងនៃព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ជាព្រះអម្ចាស់ដែលមានព្រះជន្មគង់នៅសព្វថ្ងៃ គង់នៅពីដើម ហើយកំពុងតែយាងមក ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាថាយ** ២៨,១៦-២០

ក្រោយបុណ្យចម្លង [១៦]សាវ័កទាំងដប់មួយរូប នាំគ្នាធ្វើដំណើរទៅស្រុកកាលីឡេ ហើយឡើងទៅលើភ្នំ
ដែលព្រះយេស៊ូបានប្រាប់ឲ្យគេទៅ ។ [១៧]កាលគេបានឃើញព្រះអង្គ គេក្រាបថ្វាយបង្គំ ប៉ុន្តែ មានអ្នកខ្លះ
នៅសង្ស័យ ។ [១៨]ព្រះយេស៊ូយាងចូលមកជិតគេ ហើយមានព្រះបន្ទូលថា៖ «ខ្ញុំបានទទួលគ្រប់អំណាច
ទាំងនៅស្ថានបរមសុខ ទាំងនៅលើផែនដី ។ [១៩]ដូច្នេះ ចូរចេញទៅបង្ហាត់មនុស្សគ្រប់ជាតិសាសន៍ ឲ្យធ្វើ
ជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកឲ្យគេ ក្នុងព្រះនាមព្រះបិតាព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។ [២០]ត្រូវ
បង្រៀនគេឲ្យប្រតិបត្តិតាមសេចក្ដីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា ។ ចូរដឹងថា ខ្ញុំនៅជាមួយ
អ្នករាល់គ្នាជារៀងរាល់ថ្ងៃ រហូតដល់អវសានកាលនៃពិភពលោក» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# បុណ្យព្រះកាយ និងព្រះលោហិត ដ៏វិសុទ្ធបំផុតរបស់ព្រះគ្រីស្ត ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម យហ ៦,៥១

**អាលេលូយ៉ា! អាលេលូយ៉ា!** បពិត្រព្រះអម្ចាស់យេស៊ូ! ព្រះអង្គពិតជាអាហារ
ដែលមានជីវិតចុះពីស្ថានបរមសុខមក ។ អ្នកណាបរិភោគអាហារនេះ
នឹងរស់នៅអស់កល្បជានិច្ច ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** ១៤,១២-១៦.២២-២៦

[១២]នៅថ្ងៃដំបូងនៃពិធីបុណ្យនំបុ័ងឥតមេ ជាថ្ងៃដែលគេត្រូវសម្លាប់កូនចៀមធ្វើយញ្ញបូជា សម្រាប់
បុណ្យចម្លង ពួកសាវ័កទូលសួរព្រះយេស៊ូថា៖ «តើព្រះគ្រូចង់ឲ្យយើងខ្ញុំរៀបចំពិធីជប់លៀងជូនក្នុង
ឱកាសបុណ្យចម្លង នៅកន្លែងណា?» ។ [១៣]ព្រះអង្គចាត់សាវ័កពីររូបឲ្យទៅ ដោយមានព្រះបន្ទូលថា៖
«ចូរអ្នកទៅទីក្រុង អ្នកនឹងជួបបុរសម្នាក់លីក្អមទឹក ។ ចូរដើរតាមគាត់ទៅ [១៤]គាត់ចូលផ្ទះណាអ្នកត្រូវ
និយាយទៅម្ចាស់ផ្ទះនោះថា "លោកគ្រូមានប្រសាសន៍ថា បន្ទប់ដែលខ្ញុំនឹងត្រូវជប់លៀងជាមួយពួក
សិស្សក្នុងពេលបុណ្យចម្លងនៅឯណា?" ។ [១៥]ម្ចាស់ផ្ទះនឹងបង្ហាញបន្ទប់មួយយ៉ាងធំនៅជាន់ខាងលើ ដែល
មានប្រដាប់ប្រដាសព្វគ្រប់រៀបចំជាស្រេច ចូររៀបចំម្ហូបអាហារសម្រាប់យើងនៅក្នុងបន្ទប់នោះចុះ» ។
[១៦]សាវ័កទាំងពីរក៏ចេញទៅ ។ លុះដល់ទីក្រុង គេបានឃើញដូចព្រះយេស៊ូមានព្រះបន្ទូលប្រាប់មែន គេក៏
រៀបចំម្ហូបអាហារសម្រាប់បុណ្យចម្លង ។

[២២]នៅពេលកំពុងបរិភោគ ព្រះយេស៊ូយកនំបុ័ងមកកាន់ ព្រះអង្គលើកតម្កើងព្រះជាម្ចាស់ ហើយកាច់
ប្រទានឲ្យគេ ទាំងមានព្រះបន្ទូលថា៖ «សុំពិសាចុះ នេះជារូបកាយរបស់ខ្ញុំ!» ។ [២៣]បន្ទាប់មក ព្រះអង្គ
យកពែងមកកាន់ អរព្រះគុណព្រះជាម្ចាស់ រួចប្រទានឲ្យក្រុមសាវ័ក ។ ក្រុមសាវ័កក៏បរិភោគទាំងអស់
គ្នា ។ [២៤]ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «នេះជាលោហិតរបស់ខ្ញុំ គឺលោហិតនៃសម្ពន្ធមេត្រីដែលត្រូវ
បង្ហូរសម្រាប់មនុស្សទាំងអស់ ។ [២៥]ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា ខ្ញុំនឹងមិនពិសាស្រាទំពាំងបាយជូរ
ទៀតឡើយ រហូតដល់ថ្ងៃដែលខ្ញុំនឹងពិសាស្រាទំពាំងបាយជូរថ្មី នៅក្នុងព្រះរាជ្យព្រះជាម្ចាស់» ។
[២៦]ក្រោយពីបានច្រៀងទំនុកតម្កើងរួចហើយ ព្រះយេស៊ូយាងឆ្ពោះទៅភ្នំដើមអូលីវ ជាមួយក្រុមសាវ័ក ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម យហ ១,៤១.១៧**

**អាលេលូយ៉ា! អាលេលូយ៉ា!** យើងបានទទួលស្គាល់ព្រះយេស៊ូទុកជាព្រះគ្រីស្ត ។
ព្រះជាម្ចាស់ប្រណីសន្ដោសដល់យើង និងប្រទានសេចក្ដីពិតដោយសារព្រះអង្គ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ដ យ៉ូហាន** **១,៣៥-៤២**

[៣៥]លោកយ៉ូហាននៅ នៅជាមួយសិស្សរបស់លោកពីរនាក់ ។ [៣៦]លោកសម្លឹងមើលព្រះយេស៊ូយាង
កាត់តាមនោះ ហើយមានប្រសាសន៍ថា៖ «មើលហ្ន៎! លោកនេះហើយ ជាកូនចៀមរបស់ព្រះជាម្ចាស់»
។ [៣៧]កាលសិស្សទាំងពីរបានឮពាក្យនេះ គេនាំគ្នាដើរតាមព្រះយេស៊ូទៅ ។ [៣៨]ព្រះយេស៊ូងាកមកក្រោយ
ទតឃើញអ្នកទាំងពីរដើរតាមព្រះអង្គ ក៏មានព្រះបន្ទូលសួរថា៖ «អ្នកទាំងពីរមករកអ្វី?» ។ គេទូល
ព្រះអង្គថា៖ «រ៉ាប៊ី! (ពាក្យ "រ៉ាប៊ី" នេះប្រែថា "លោកគ្រូ") តើលោកនៅកន្លែងណា?» ។ [៣៩]ព្រះ
អង្គមានព្រះបន្ទូលទៅគេវិញថា៖ «សុំអញ្ជើញមក អ្នកនឹងឃើញ!» ។ គេក៏ទៅឃើញកន្លែងដែលព្រះ
អង្គគង់នៅ ហើយគេក៏នៅជាមួយព្រះអង្គ នៅថ្ងៃនោះ (ពេលនោះប្រហែលជាម៉ោងបួនរសៀល) ។
[៤០]ក្នុងចំណោមសិស្សទាំងពីរ ដែលបានឮពាក្យរបស់លោកយ៉ូហាន ហើយតាមព្រះយេស៊ូទៅនោះ មាន
ម្នាក់ឈ្មោះអន់ទ្រេ ជាប្អូនរបស់លោកស៊ីម៉ូនសិលា ។ [៤១]គាត់ទៅជួបលោកស៊ីម៉ូនជាបង មុនគេដោយ
ប្រាប់ថា៖ «យើងបានរកព្រះមែស្ស៊ីឃើញហើយ!» (ពាក្យ "មែស្ស៊ី" នេះប្រែថា "ព្រះគ្រីស្ត") ។
[៤២]គាត់ក៏នាំលោកស៊ីម៉ូនទៅគាល់ព្រះយេស៊ូ ។ ព្រះយេស៊ូសម្លឹងមើលលោកស៊ីម៉ូន ក៏មានព្រះបន្ទូលថា៖
«អ្នកឈ្មោះស៊ីម៉ូន ជាកូនរបស់លោកយ៉ូហាន អំណើះតទៅអ្នកត្រូវមានឈ្មោះថា "កេផាស" (ពាក្យ
"កេផាស" នេះប្រែថា "សិលា") ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៣ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **មក ១,១៥**

**អាលេលូយ៉ា!** **អាលេលូយ៉ា!** ព្រះរាជ្យរបស់ព្រះជាម្ចាស់មកជិតបង្កើយ ។
ចូរនាំគ្នាប្រែចិត្តគំនិត ហើយជឿដំណឹងល្អចុះ! ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** **១,១៤-២០**

[១៤]ក្រោយពេលដែលគេចាប់លោកយ៉ូហានបាទីស្ដយកទៅឃុំឃាំង ព្រះយេស៊ូយាងទៅស្រុកកាលីឡេ
ហើយប្រកាសដំណឹងល្អរបស់ព្រះជាម្ចាស់ [១៥]ព្រះអង្គមានព្រះបន្ទូលថា៖ «ពេលកំណត់មកដល់ហើយ រីឯ
ព្រះរាជ្យរបស់ព្រះជាម្ចាស់ក៏មកជិតបង្កើយដែរ ។ ចូរនាំគ្នាប្រែចិត្តគំនិត ហើយជឿលើដំណឹងល្អចុះ!» ។

[១៦]កាលព្រះយេស៊ូយាងតាមឆ្នេរសមុទ្រកាលីឡេ ព្រះអង្គទតឃើញលោកស៊ីម៉ូន និងលោកអន់ដ្រេ
ជាប្អូនរបស់គាត់ កំពុងតែបង់សំណាញ់ ព្រោះអ្នកទាំងពីរជាអ្នកនេសាទត្រី ។ [១៧]ព្រះអង្គមានព្រះបន្ទូល
ទៅគេថា៖ «សូមអញ្ជើញមកតាមខ្ញុំ ខ្ញុំនឹងតាំងអ្នកឲ្យនេសាទមនុស្សវិញ» ។ [១៨]អ្នកទាំងពីរក៏ទុក
សំណាញ់នៅទីនោះភ្លាម ដើរតាមព្រះអង្គទៅ ។

[១៩]កាលព្រះយេស៊ូយាងទៅមុខបន្តិច ព្រះអង្គទតឃើញលោកយ៉ាកុប និងលោកយ៉ូហានជាប្អូន កំពុង
តែរៀបចំអួននៅក្នុងទូក អ្នកទាំងពីរជាកូនលោកសេបេដេ ។ [២០]ព្រះអង្គត្រាស់ហៅអ្នកទាំងពីរភ្លាម គេ
ទុកឪពុកឲ្យនៅក្នុងទូកជាមួយពួកកូនឈ្នួល ហើយដើរតាមព្រះយេស៊ូទៅ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៤ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម លក ១,៦៨-៧៩

**អាលេលូយ៉ា! អាលេលូយ៉ា!** សូមលើកតម្កើងព្រះអម្ចាស់ ជាព្រះរបស់យើង!
ព្រះអង្គបានប្រោសឲ្យពន្លឺយាកមកបំភ្លឺអស់អ្នកដែលស្ថិតនៅក្នុងទីងងឹត ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** ១,២១-២៨

[២១]ព្រះយេស៊ូយាងចូលក្រុងកាផានុមជាមួយក្រុមសាវ័ក ។ នៅថ្ងៃសប្ប័ទ ព្រះយេស៊ូយាងចូលក្នុងធម្ម
សាលា ហើយព្រះអង្គបង្រៀនអ្នកស្រុក ។ [២២]អ្នកដែលបានស្ដាប់ព្រះអង្គងឿងឆ្ងល់យ៉ាងខ្លាំងអំពីបែបបទ
ដែលព្រះអង្គបង្រៀន ព្រោះព្រះអង្គមានព្រះបន្ទូលប្រកបដោយអំណាច ខុសប្លែកពីពួកធម្មាចារ្យ ។
[២៣]នៅពេលនោះ ក្នុងធម្មសាលាមានបុរសម្នាក់ដែលខ្មោចចូល ស្រែកឡើងថា៖ [២៤]«ព្រះយេស៊ូជាអ្នក
ភូមិណាសារ៉ែតអើយ! តើព្រះអង្គចង់ធ្វើអ្វីយើង? ព្រះអង្គមកបំផ្លាញយើង! ខ្ញុំស្គាល់ព្រះអង្គហើយ
ព្រះអង្គជាព្រះដ៏វិសុទ្ធដែលមកពីព្រះជាម្ចាស់» ។ [២៥]ព្រះយេស៊ូគំរាមខ្មោចនោះថា៖ «ស្ងៀម! ចេញពី
អ្នកនេះភ្លាម!» ។ [២៦]ខ្មោចក៏ធ្វើឲ្យបុរសនោះដួលប្រកាច់ប្រកិន ហើយវាចេញទៅទាំងស្រែកយ៉ាងខ្លាំង
ផង ។ [២៧]មនុស្សម្នាទាំងអស់ភ័យស្រឡាំងកាំង គេនិយាយគ្នាទៅវិញទៅមកថា៖ «ម្ដេចក៏អស្ចារ្យម្ល៉េះ!
លោកបង្រៀនតាមរបៀបថ្មី ប្រកបដោយអំណាច ។ លោកបញ្ជាទៅខ្មោច ហើយខ្មោចក៏ស្ដាប់បង្គាប់
លោក» ។ [២៨]ព្រះកិត្តិនាមរបស់ព្រះយេស៊ូល្បីខ្ចរខ្ចាយពាសពេញតំបន់កាលីឡេទាំងមូល ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៥ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** មថ ៨,១៧

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះយេស៊ូបានទទួលយកភាពពិការរបស់យើង
ហើយព្រះអង្គក៏ទទួលយកជំងឺរបស់យើងដែរ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** ១,២៩-៣៩

[២៩]ព្រះយេស៊ូនិងក្រុមសាវ័កនាំគ្នាចេញពីធម្មសាលា ទៅផ្ទះលោកស៊ីម៉ូននិងលោកអន់ដ្រេ ។ លោក
យ៉ាកុបនិងលោកយ៉ូហានក៏ទៅជាមួយដែរ ។ [៣០]ម្ដាយក្មេករបស់លោកស៊ីម៉ូន កំពុងតែគ្រុន សម្រាន្តនៅ
លើគ្រែ ។ ពេលព្រះយេស៊ូយាងទៅដល់ គេទូលព្រះអង្គភ្លាមថា គាត់ឈឺ ។ [៣១]ព្រះអង្គយាងចូលទៅជិត
ចាប់ដៃគាត់ឲ្យក្រោកឡើង គាត់ក៏បាត់គ្រុន ហើយបម្រើភ្ញៀវ ។

[៣២]លុះដល់ល្ងាច ក្រោយពេលថ្ងៃលិច គេនាំអ្នកជំងឺ និងមនុស្សខ្មោចចូលទាំងអស់មករកព្រះយេស៊ូ ។
[៣៣]អ្នកក្រុងទាំងប៉ុន្មានមកជុំគ្នានៅមាត់ទ្វារក្រុង ។ [៣៤]ព្រះយេស៊ូប្រោសមនុស្សជាច្រើននាក់ដែលមានជំងឺ
ផ្សេងៗ ឲ្យបានជាសះស្បើយ ហើយព្រះអង្គដេញខ្មោចជាច្រើនចេញពីមនុស្សផង ។ ព្រះអង្គហាមខ្មោច
មិនឲ្យនិយាយជាដាច់ខាត ព្រោះពួកវាស្គាល់ឋានៈរបស់ព្រះអង្គ ។

[៣៥]ព្រឹកឡើង កាលងងឹតនៅឡើយ ព្រះយេស៊ូតើនឡើង ទ្រង់យាងចេញពីផ្ទះទៅកន្លែងមួយស្ងាត់
ហើយអធិស្ឋាននៅទីនោះ ។ [៣៦]លោកស៊ីម៉ូននិងអ្នកដែលនៅជាមួយគាត់ នាំគ្នាតាមរកព្រះអង្គ ។ [៣៧]លុះ
បានជួបហើយគេទូលថា៖ «គេខំស្វែងរកលោកគ្រប់ៗគ្នា» ។ [៣៨]ព្រះយេស៊ូមានព្រះបន្ទូលតបទៅគេ
ថា៖ «យើងត្រូវនាំគ្នាទៅភូមិឯទៀតៗ ដែលនៅជិតនេះ ខ្ញុំត្រូវប្រកាសដំណឹងល្អនៅទីនោះដែរ ដ្បិតខ្ញុំ
ចេញមក ដើម្បីបំពេញការនេះឯង» ។

[៣៩]ព្រះអង្គយាងទៅគ្រប់ទីកន្លែងក្នុងស្រុកកាលីឡេ ហើយប្រកាសដំណឹងល្អនៅតាមធម្មសាលាទាំង
ឡាយ ព្រមទាំងដេញខ្មោចចេញពីមនុស្សផង ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៦ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **លក ៧,១៦**

**អាលេលូយ៉ា! អាលេលូយ៉ា!** មានព្យាការីដ៏ប្រសើរឧត្តមម្នាក់ បានមករស់នៅក្នុងចំណោមយើងហើយ ព្រះជាម្ចាស់យាងមករំដោះប្រជារាស្ត្ររបស់ព្រះអង្គ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** **១,៤០-៤៥**

[៤០]មានមនុស្សឃ្លង់ម្នាក់ចូលមករកព្រះយេស៊ូ គាត់លុតជង្គង់ទូលអង្វរព្រះអង្គថា៖ «ប្រសិនបើលោក
មានបំណង លោកអាចប្រោសខ្ញុំប្របាទឲ្យបានជាស្អាតបរិសុទ្ធផង» ។ [៤១]ព្រះយេស៊ូមានព្រះហឫទ័យ
អាណិតអាសូរគាត់ពន់ពេកណាស់ ព្រះអង្គក៏លូកព្រះហស្តទៅពាល់គាត់ ទាំងមានព្រះបន្ទូលថា៖ «ខ្ញុំ
ចង់! ចូរឲ្យបានជាស្អាតបរិសុទ្ធចុះ!» ។ [៤២]មនុស្សឃ្លង់ក៏បានជាស្អាតបរិសុទ្ធភ្លាម ។ [៤៣]បន្ទាប់មក ព្រះ
យេស៊ូដេញគាត់ឲ្យចេញទៅទាំងមានព្រះបន្ទូលយ៉ាងម៉ឺងម៉ាត់ថា៖ [៤៤]«ចូរប្រយ័ត្នឲ្យមែនទែន កុំនិយាយ
ហេតុការណ៍នេះប្រាប់ឲ្យនរណាដឹងឮឡើយ! ផ្ទុយទៅវិញ ត្រូវទៅបង្ហាញខ្លួនដល់លោកបូជាចារ្យ រួច
ថ្វាយតង្វាយដូចលោកម៉ូសេបានបង្គាប់ទុក ដើម្បីជាសក្ខីភាពបញ្ជាក់ថា អ្នកបានជាស្អាតបរិសុទ្ធមែន» ។
[៤៥]ប៉ុន្តែ បុរសនោះចេញទៅប្រកាស និងផ្សព្វផ្សាយរឿងនេះនៅគ្រប់កន្លែងឲ្យគេដឹង ។ ហេតុនេះហើយ
បានជាព្រះយេស៊ូមិនអាចយាងចូលទីក្រុងដូចពីមុនបានទៀតឡើយ គឺព្រះអង្គគង់នៅតែខាងក្រៅទីក្រុង
ត្រង់កន្លែងស្ងាត់ៗ ហើយមានមនុស្សពីគ្រប់ទិសទីនាំគ្នាមកគាល់ព្រះអង្គ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៧ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម លក ៤,១៨-១៩

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះអម្ចាស់ចាត់ព្រះយេស៊ូជាអ្នកបម្រើរបស់ព្រះអង្គ
ឲ្យមកនាំដំណឹងល្អប្រាប់អ្នកក្រីក្រ និងប្រកាសប្រាប់ជនជាប់ជាឈ្លើយថា គេនឹងមាន
សេរីភាពហើយ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** ២,១-១២

[១]ព្រះយេស៊ូយាងត្រឡប់មកក្រុងកាផានុមវិញ ហើយអ្នកស្រុកឮដំណឹងថា ព្រះអង្គគង់នៅក្នុងផ្ទះ ។
[២]មានមនុស្សយ៉ាងច្រើនមកជុំគ្នាកកកុញ គ្មានសល់កន្លែងណាសោះឡើយ សូម្បីតែនៅមាត់ទ្វារផ្ទះ ក៏គ្មាន
សល់ដែរ ។ ព្រះយេស៊ូថ្លែងព្រះបន្ទូលឲ្យគេស្ដាប់ ។ [៣]មានបុរសបួននាក់សែងមនុស្សខ្វិនដៃខ្វិនជើងម្នាក់
មករកព្រះអង្គ ។ [៤]ប៉ុន្តែ ដោយមានមនុស្សច្រើនពេក គេពុំអាចនាំមនុស្សខ្វិននោះទៅជិតព្រះយេស៊ូបាន
ឡើយ ។ ដូច្នេះគេក៏បោះដំបូលផ្ទះ ចំពីលើកន្លែងដែលព្រះអង្គគង់ ហើយសម្រូតមនុស្សខ្វិននៅលើគ្រែ
ស្នែងចុះតាមប្រឡោះមក ។ [៥]កាលព្រះយេស៊ូឈ្វេងយល់ជំនឿរបស់អ្នកទាំងនោះ ព្រះអង្គមានព្រះបន្ទូល
ទៅកាន់អ្នកពិការថា៖ «កូនអើយ! ព្រះជាម្ចាស់អត់ទោសឲ្យអ្នកបានរួចពីបាបហើយ» ។ [៦]ពួក
ធម្មាចារ្យខ្លះដែលអង្គុយនៅទីនោះ រិះគិតក្នុងចិត្តថា៖ [៧]«ហេតុដូចម្ដេច បានជាអ្នកនេះហ៊ានប្រមាថ
ព្រះជាម្ចាស់ ដោយពោលពាក្យស្មើនឹងព្រះអង្គបែបនេះ? ក្រៅពីព្រះជាម្ចាស់មួយព្រះអង្គ តើនរណា
អាចអត់ទោសឲ្យមនុស្សរួចពីបាបបាន!» ។ [៨]ព្រះយេស៊ូឈ្វេងយល់ចិត្តគំនិតរបស់គេភ្លាម ទើបទ្រង់មាន
ព្រះបន្ទូលទៅគេថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នារិះគិតដូច្នេះ? [៩]បើខ្ញុំប្រាប់អ្នកពិការនេះថា “ព្រះជា
ម្ចាស់អត់ទោសឲ្យអ្នកបានរួចពីបាបហើយ” ឬថា “ចូរក្រោកឡើង យកគ្រែស្នែងរបស់អ្នកដើរទៅចុះ”
តើឃ្លាមួយណាស្រួលនិយាយជាង? [១០]ប៉ុន្តែ ខ្ញុំចង់ឲ្យអ្នករាល់គ្នាដឹងថាបុត្រមនុស្សមានអំណាចនឹងអត់
ទោស ឲ្យមនុស្សលោកនៅលើផែនដីនេះរួចពីបាបបាន» ។ ព្រះអង្គងាកទៅរកអ្នកខ្វិន ហើយមានព្រះ
បន្ទូលថា៖ [១១]«ចូរក្រោកឡើង យកគ្រែស្នែងរបស់អ្នក ដើរទៅផ្ទះវិញទៅ!» ។ [១២]មនុស្សខ្វិនក៏ក្រោក
ឈរឡើងភ្លាម យកគ្រែស្នែងរបស់ខ្លួន ដើរកាត់មុខមនុស្សទាំងអស់ចេញទៅ ធ្វើឲ្យគេគ្រប់គ្នាស្ញប់ស្ញែង
យ៉ាងខ្លាំង ហើយលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ទាំងពោលថា៖ «យើងមិនដែលបានឃើញ
ការអស្ចារ្យណាមួយដូចពេលនេះឡើយ!» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៨ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម មក ២,១៩.២២

**អាលេលូយ៉ា! អាលេលូយ៉ា!** អ្នកដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យចូលរួមក្នុង
ពិធីជប់លៀងមង្គលការនៃព្រះរាជ្យ ពិតជាមានសុភមង្គល! ព្រះអង្គប្រក
ស្រាទំពាំងបាយជូរនៃសម្ពន្ធមេត្រីថ្មីជូនគេ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** ២,១៨-២២

១៨ថ្ងៃមួយ ពួកសិស្សរបស់លោកយ៉ូហានបាទីស្ដ និង ពួកសិស្សខាងគណៈផារីស៊ី នាំគ្នាតមអាហារ ។
ពួកគេមកទូលសួរព្រះយេស៊ូថា៖ «សិស្សរបស់លោកយ៉ូហាន និងសិស្សខាងគណៈផារីស៊ីតមអាហារ ចុះ
ហេតុដូចម្ដេចបានជាសិស្សរបស់លោកមិនតមដូច្នេះ? » ។ ១៩ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ក្នុង
ពិធីមង្គលការ នៅពេលកូនកំឡោះនៅជាមួយ តើភ្ញៀវអាចតមអាហារកើតឬ? ។ ទេ! ដរាបណាកូន
កំឡោះនៅជាមួយភ្ញៀវ មិនអាចតមអាហារបានឡើយ ។ ២០ថ្ងៃក្រោយ ពេលគេចាប់ស្វាមីយកទៅ ទើប
ភ្ញៀវទាំងនោះតមអាហារ ។ ២១ពុំដែលមាននរណាយកក្រណាត់ថ្មី មកប៉ះសម្លៀកបំពាក់ចាស់ឡើយ បើ
ធ្វើដូច្នេះ ក្រណាត់ថ្មីនឹងបណ្ដាលឲ្យសម្លៀកបំពាក់ចាស់រហែកលើសដើមទៅទៀត ។ ២២ពុំដែលមាន
នរណាប្រកស្រាទំពាំងបាយជូរថ្មី ទៅក្នុងថង់ស្បែកចាស់ឡើយ បើធ្វើដូច្នោះស្រានឹងធ្វើឲ្យថង់ស្បែកនោះ
ធ្លាយ បណ្ដាលឲ្យខូចទាំងស្រា ទាំងថង់ស្បែកជាមិនខាន ។ ត្រូវប្រកស្រាថ្មីទៅក្នុងថង់ស្បែកថ្មី» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៩ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** ១ ករ ៦,១៧

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះវិញ្ញាណនៃព្រះដែលមានព្រះជន្មគង់នៅ ទ្រង់ប្រទានជីវិត ។ នៅទីណាមានព្រះវិញ្ញាណរបស់ព្រះអម្ចាស់ នៅទីនោះ ក៏មានសេរីភាពដែរ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** ២,២៣-៣,៦ (ឬយ៉ាងខ្លី ២,២៣-២៨)

២៣មានថ្ងៃមួយជាថ្ងៃសប្ប័ទ ព្រះយេស៊ូយាងកាត់វាលស្រែ សាវ័ករបស់ព្រះអង្គនាំគ្នាដើរបណ្ដើរ បូត
កួរស្រូវបណ្ដើរ ។ ២៤ពួកខាងគណៈផារីស៊ីទូលព្រះយេស៊ូថា៖ «សូមលោកមើលចុះ! ហេតុអ្វីបានជាសិស្ស
របស់លោកធ្វើការដែលបញ្ញត្តិហាមមិនឲ្យធ្វើនៅថ្ងៃសប្ប័ទដូច្នេះ?» ។ ២៥ព្រះយេស៊ូតបទៅគេវិញថា៖
«ក្នុងគម្ពីរមានអត្ថបទមួយស្ដីអំពីការដែលព្រះបាទដាវីឌ និងបរិពារ បានប្រព្រឹត្តនៅពេលឃ្លាន ហើយ
ត្រូវការអាហារបរិភោគ ។ ២៦នៅសម័យនោះ លោកអប៊ីយ៉ាថារធ្វើជាមហាបូជាចារ្យ ។ ព្រះបាទដាវីឌ
បានចូលទៅក្នុងដំណាក់របស់ព្រះជាម្ចាស់ យកនំបុ័ងដែលគេតាំងថ្វាយព្រះជាម្ចាស់មកសោយ ព្រមទាំង
ចែកឲ្យពួកបរិពារបរិភោគទៀតផង ។ តាមវិន័យ មានតែពួកបូជាចារ្យប៉ុណ្ណោះ ដែលមានសិទ្ធិបរិភោគ
នំបុ័ងនោះ ។ តើអ្នករាល់គ្នាមិនដែលអានអត្ថបទនោះទេឬ?» ។ ២៧ព្រះយេស៊ូមានព្រះបន្ទូលទៅគេ
ទៀតថា៖ «ព្រះជាម្ចាស់បានបង្កើតថ្ងៃសប្ប័ទដើម្បីជាប្រយោជន៍ដល់មនុស្ស ព្រះអង្គមិនបានបង្កើត
មនុស្សដើម្បីឲ្យបម្រើថ្ងៃសប្ប័ទឡើយ ។ ២៨ហេតុនេះហើយបានជាបុត្រមនុស្សជាម្ចាស់លើថ្ងៃសប្ប័ទ» ។

៣ ១ព្រះយេស៊ូយាងចូលទៅធម្មសាលាម្ដងទៀត ។ នៅទីនោះ មានបុរសម្នាក់ស្វិតដៃម្ខាង ។ ២ពួកគេ
តាមមើលព្រះយេស៊ូ ក្នុងគោលបំណងចោទប្រកាន់ព្រះអង្គ ក្រែងលោព្រះអង្គប្រោសបុរសនេះឲ្យជានៅ
ថ្ងៃសប្ប័ទ ។ ៣ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់បុរសស្វិតដៃនោះថា៖ «ចូរក្រោកឡើង មកឈរនៅ
កណ្ដាលគេឯណោះ!» ។ ៤បន្ទាប់មក ព្រះអង្គមានព្រះបន្ទូលសួរទៅគេថា៖ «នៅថ្ងៃសប្ប័ទ តើវិន័យ
អនុញ្ញាតឲ្យធ្វើអំពើល្អ ឬធ្វើអំពើអាក្រក់? ឲ្យសង្គ្រោះមនុស្ស ឬឲ្យប្រហារជីវិតចោល?» ។ ពួកគេ
នៅស្ងៀមទាំងអស់គ្នា ។ ៥ព្រះយេស៊ូបែរព្រះភ័ក្ត្រទតមើលទៅអ្នកដែលនៅជុំវិញទាំងព្រះពិរោធ ហើយ
ព្រះអង្គព្រួយព្រះហឫទ័យ ព្រោះគេមានចិត្តរឹងរូស ។ ព្រះអង្គមានព្រះបន្ទូលទៅកាន់បុរសស្វិតដៃនោះ
ថា៖ «ចូរលាតដៃមើល៍!» ។ បុរសនោះលាតដៃ ហើយដៃរបស់គាត់ក៏បានជាដូចដើមវិញ ។ ៦ពួកខាង
គណៈផារីស៊ីចេញពីធម្មសាលាទៅពិគ្រោះជាមួយបក្សពួកស្ដេចហេរ៉ូដភ្លាម ដើម្បីរកមធ្យោបាយធ្វើគុត
ព្រះយេស៊ូ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ១០ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម វវ ១២,១០ ; យហ ១២,៣១**

**អាលេលូយ៉ា! អាលេលូយ៉ា!** ឥឡូវនេះ ដល់ពេលព្រះជាម្ចាស់សង្គ្រោះមនុស្សលោកហើយ
ហើយព្រះគ្រីស្តរបស់ព្រះអង្គក៏ទទួលឫទ្ធានុភាពដែរ ។ បុត្រមនុស្សដែលគេលើកឡើងនៅលើ
ឈើឆ្កាង ទ្រង់ទាញមនុស្សទាំងអស់ មកឯព្រះអង្គ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** **៣,២០-៣៥**

[២០]ព្រះយេស៊ូយាងចូលផ្ទះមួយ ។ បណ្តាជនជួបជុំគ្នាសាជាថ្មី ជាហេតុនាំឲ្យព្រះអង្គនិងក្រុមសាវ័ករក
ពេលបរិភោគមិនបានសោះ ។ [២១]ព្រះញាតិវង្សរបស់ព្រះអង្គឮដំណឹងនេះ ក៏នាំគ្នាធ្វើដំណើរមក ដើម្បី
ចាប់ព្រះអង្គទៅវិញ ព្រោះគេថា ព្រះអង្គវង្វេងស្មារតីហើយ ។

[២២]ពួកធម្មាចារ្យដែលចុះមកពីក្រុងយេរូសាឡឹម និយាយថា៖ «អ្នកនេះមានបេលសេប៊ូល ជាស្តេច
ខ្មោចនៅក្នុងខ្លួន គាត់អាចដេញខ្មោចដូច្នេះ ព្រោះស្តេចខ្មោចប្រគល់អំណាចឲ្យ» ។ [២៣]ព្រះយេស៊ូត្រាស់
ហៅគេមក រួចមានព្រះបន្ទូលជាប្រស្នាថា៖ «តើមារសាតាំងអាចដេញមារសាតាំងដូចម្តេចកើត? [២៤]
ប្រសិនបើពលរដ្ឋក្នុងនគរណាមួយបែកបាក់ទាស់ទែងគ្នាឯង នគរនោះពុំអាចស្ថិតស្ថេរគង់វង្សតទៅមុខ
បានឡើយ ។ [២៥]ប្រសិនបើមានក្រុមគ្រួសារមួយបែកបាក់ទាស់ទែងគ្នា ក្រុមគ្រួសារនោះក៏ពុំអាចនៅស្ថិត
ស្ថេរគង់វង្សបានដែរ ។ [២៦]ដូច្នេះ ប្រសិនបើមារសាតាំងក្រោកឡើងប្រឆាំងនឹងខ្លួនឯង បែកបាក់ទាស់
ទែងនឹងខ្លួនឯង វាមិនអាចនៅស្ថិតស្ថេរគង់វង្សបានឡើយ គឺវាមុខជាត្រូវវិនាសមិនខាន ។ [២៧]គ្មាននរណា
អាចចូលទៅក្នុងផ្ទះមនុស្សខ្លាំងពូកែ ហើយប្លន់យកទ្រព្យសម្បត្តិរបស់គាត់បានឡើយ គឺត្រូវតែចង
មនុស្សខ្លាំងពូកែនោះជាមុនសិន ទើបអាចប្លន់យកទ្រព្យសម្បត្តិក្នុងផ្ទះគាត់បាន ។ [២៨]ខ្ញុំសុំប្រាប់ឲ្យអ្នក
រាល់គ្នាដឹងច្បាស់ថា បើមនុស្សលោកធ្វើអំពើបាប និងពោលពាក្យប្រមាថព្រះជាម្ចាស់ ព្រះអង្គនឹងលើក
លែងទោសទាំងអស់ ។ [២៩]រីឯអ្នកដែលពោលពាក្យប្រមាថព្រះវិញ្ញាណដ៏វិសុទ្ធវិញ ព្រះអង្គមិនលើកលែង
ទោសសោះឡើយ ដ្បិតអ្នកនោះមានទោសអស់កល្បជានិច្ច» ។ [៣០]ព្រះយេស៊ូមានព្រះបន្ទូលដូច្នេះ ព្រោះ
គេនិយាយថា ព្រះអង្គមានខ្មោចនៅក្នុងខ្លួន ។

[៣១]ពេលនោះ មាតានិងបងប្អូនរបស់ព្រះយេស៊ូមកដល់ ឈរនៅខាងក្រៅផ្ទះ ហើយចាត់គេឲ្យចូលមក
ហៅព្រះអង្គ ។ [៣២]បណ្តាជនដែលអង្គុយនៅជុំវិញព្រះយេស៊ូ ទូលព្រះអង្គថា៖ «លោកគ្រូ! ម្តាយនិងបង

ប្អូនលោកមករកលោកនៅខាងក្រៅ! » ។ [៣៣]ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «តើនរណាជាម្ដាយខ្ញុំ?
នរណាជាបងប្អូនខ្ញុំ? » ។ [៣៤]ព្រះអង្គទតមើលទៅមនុស្សដែលនៅជុំវិញព្រះអង្គ រួចមានព្រះបន្ទូលថា៖
«អ្នកទាំងនេះហើយជាមាតា និងជាបងប្អូនរបស់ខ្ញុំ [៣៥]ដ្បិតអ្នកណាប្រព្រឹត្តតាមព្រះហឫទ័យព្រះជាម្ចាស់
អ្នកនោះជាបងប្អូនប្រុសស្រី និងជាម្ដាយរបស់ខ្ញុំ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ១១ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម មថ ១៣,៤.២៣

**អាលេលូយ៉ា! អាលេលូយ៉ា!** អ្នកសាបព្រោះចេញទៅព្រោះព្រះបន្ទូល ។

អស់អ្នកទទួលព្រះបន្ទូលនេះ ពិតជាបានសុភមង្គល! ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** ៤,២៦-៣៤

២៦ព្រះយេស៊ូមានព្រះបន្ទូលទៀតថា៖ «ព្រះរាជ្យរបស់ព្រះជាម្ចាស់ ប្រៀបបីដូចជាបុរសម្នាក់
ព្រោះស្រូវនៅក្នុងស្រែរបស់ខ្លួន ។ ២៧ទោះបីគាត់ដេកក្ដី ក្រោកក្ដី យប់ក្ដី ថ្ងៃក្ដី គ្រាប់ពូជនៅតែមាន
ពន្លកដុះឡើង ដោយគាត់ពុំបានដឹងថា គ្រាប់ពូជនោះដុះរបៀបណាឡើយ ២៨ដ្បិតដីធ្វើឲ្យពូជបង្កើត
ផលដោយខ្លួនឯង មុនដំបូងមានពន្លកលេចឡើង បន្ទាប់មកក៏បែកជាកួរ ហើយចេញជាគ្រាប់ស្រូវ ។
២៩លុះស្រូវទុំ គេយកកណ្ដៀវមកច្រូត ដ្បិតដល់រដូវចម្រូតហើយ» ។

៣០ព្រះអង្គមានព្រះបន្ទូលទៀតថា៖ «តើយើងប្រដូចព្រះរាជ្យរបស់ព្រះជាម្ចាស់ទៅនឹងអ្វីខ្លះ? តើ
យើងយកប្រស្នាណាមកប្រដូចនឹងព្រះរាជ្យរបស់ព្រះអង្គ? ៣១ព្រះរាជ្យរបស់ព្រះជាម្ចាស់ប្រៀបបីដូចជា
គ្រាប់ពូជម៉្យាង កាលគេព្រោះលើដី គ្រាប់ពូជនោះល្អិតជាងគេទាំងអស់ក្នុងលោក ។ ៣២លុះព្រោះរួច
ហើយ គ្រាប់ពូជនោះក៏ដុះឡើងធំជាងដំណាំឯទៀតៗ ព្រមទាំងបែកមែកសាខាមានម្លប់ ឲ្យបក្សាបក្សី
មកធ្វើសំបុកជ្រកអាស្រ័យ» ។

៣៣ព្រះយេស៊ូតែងប្រកាសព្រះបន្ទូលដោយប្រើជាពាក្យប្រស្នារបៀបនេះ តាមតែគេអាចយល់បាន ។
៣៤ព្រះអង្គតែងមានព្រះបន្ទូលទៅគេ សុទ្ធតែជាពាក្យប្រស្នា ប៉ុន្តែ ពេលនៅដាច់ឡែកពីបណ្ដាជន ព្រះ
អង្គបកស្រាយទាំងអស់ ប្រាប់ក្រុមសាវ័ក ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ១២ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** ទន ៦៥,៥ ; ២៤,៨

**អាលេលូយ៉ា! អាលេលូយ៉ា!** សូមអញ្ជើញមកមើលស្នាព្រះហស្ដដ៏អស្ចារ្យនៃព្រះជាម្ចាស់ ។
ព្រះសូរសៀងរបស់ព្រះអម្ចាស់ខ្លាំងជាងខ្យល់ ។
ព្រះអម្ចាស់ធ្វើឲ្យសូរសន្ធឹកនៃសមុទ្រស្ងប់ស្ងៀម ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ដ ម៉ាកុស** ៤,៣៥-៤១

ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់បណ្ដាជនអស់មួយថ្ងៃ ។ [៣៥]នៅល្ងាចថ្ងៃដដែលនោះ ព្រះយេស៊ូមាន
ព្រះបន្ទូលទៅក្រុមសាវ័កថា៖ «យើងនាំគ្នាឆ្លងទៅត្រើយម្ខាង» ។ [៣៦]ក្រុមសាវ័កក៏ចេញពីបណ្ដាជន
ហើយអុំទូកដែលមានព្រះយេស៊ូគង់នៅក្នុងនោះ ដោយមានទូកឯទៀតៗទៅជាមួយដែរ ។ [៣៧]ស្រាប់តែ
មានខ្យល់ព្យុះបក់បោកមកយ៉ាងខ្លាំង ហើយរលកក៏បោកប៉ះនឹងទូក បណ្ដាលឲ្យទឹកចូលជិតពេញទូក ។
[៣៨]រីឯព្រះយេស៊ូវិញ ព្រះអង្គផ្ទំលក់លើខ្នើយនៅកន្សៃទូក ។ ក្រុមសាវ័កដាស់ព្រះអង្គថា៖ «លោកគ្រូ!
យើងស្លាប់ឥឡូវហើយ! លោកមិនអើពើទេឬ?» ។ [៣៩]ព្រះយេស៊ូតើនឡើង ហើយមានព្រះបន្ទូលគំរាម
ខ្យល់ព្យុះនិងបញ្ជាសមុទ្រថា៖ «ស្ងប់ស្ងៀមទៅ!» ។ ពេលនោះខ្យល់ព្យុះក៏ស្ងប់ ហើយផ្ទៃទឹកក៏រាបស្មើ
ដែរ ។

[៤០]បន្ទាប់មក ព្រះយេស៊ូមានព្រះបន្ទូលទៅក្រុមសាវ័កថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នាភិតភ័យ
ដូច្នេះ? អ្នករាល់គ្នាមិនទាន់មានជំនឿទេឬ?» ។ [៤១]ពួកគេកោតស្ញប់ស្ញែងជាខ្លាំង ហើយនិយាយគ្នាទៅ
វិញទៅមកថា៖ «តើលោកនេះជានរណា បានជាខ្យល់ព្យុះនិងសមុទ្រស្ដាប់បង្គាប់លោកដូច្នេះ?» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ១៣ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **២ ធម ១,១០**

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះយេស៊ូគ្រីស្តជាព្រះសង្គ្រោះរបស់យើងបានបំបាត់សេចក្តីស្លាប់ ព្រមទាំងបំភ្លឺយើងឲ្យស្គាល់ជីវិតអមតៈ ដោយសារដំណឹងល្អ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** **៥,២១-៤៣ (ឬយ៉ាងខ្លី ៥,២១-២៤.៣៥-៤៣)**

២១ព្រះយេស៊ូឆ្លងទូកពីត្រើយម្ខាងមកវិញ ព្រះអង្គគង់នៅឆ្នេរសមុទ្រ ។ មានបណ្តាជនច្រើនកុះករ
មកចោមរោមព្រះអង្គម្តង ។ ២២ពេលនោះអ្នកទទួលខុសត្រូវលើធម្មសាលាម្នាក់ឈ្មោះយ៉ៃរ៉ូស មកដល់ ។
កាលគាត់ឃើញព្រះយេស៊ូ គាត់ក្រាបទៀបព្រះបាទាព្រះអង្គ ២៣ហើយទទូចអង្វរព្រះអង្គថា៖ «កូនស្រី
របស់ខ្ញុំប្របាទឈឺធ្ងន់ជិតស្លាប់ សូមលោកអាណិតមេត្តាអញ្ជើញទៅដាក់ដៃលើនាង ដើម្បីសង្គ្រោះនាង
ឲ្យមានជីវិត» ។ ២៤ព្រះយេស៊ូយាងទៅជាមួយគាត់ ។ មានបណ្តាជនជាច្រើនកុះករតាមព្រះអង្គទៅ
ទាំងប្រជ្រៀតគ្នាជុំវិញព្រះអង្គ ។

២៥នៅពេលនោះ មានស្ត្រីម្នាក់កើតជំងឺធ្លាក់ឈាមដប់ពីរឆ្នាំមកហើយ ។ ២៦គ្រូពេទ្យជាច្រើនបាន
ព្យាបាលនាង តែនាងឈឺចុកចាប់រីតតែខ្លាំង ។ នាងបានចំណាយទ្រព្យសម្បត្តិទាំងប៉ុន្មានដែលនាងមាន
តែជំងឺរបស់នាងនៅតែមិនបានធូរស្រាលទេ ផ្ទុយទៅវិញ នាងកាន់តែឈឺខ្លាំងឡើងៗ ។ ២៧នាងឮគេ
និយាយអំពីព្រះយេស៊ូ នាងក៏ចូលក្នុងចំណោមបណ្តាជន ហើយពាល់ព្រះពស្ត្ររបស់ព្រះអង្គពីខាងក្រោយ
២៨ដ្បិតនាងនឹកក្នុងចិត្តថា៖ «បើខ្ញុំបានពាល់អាវរបស់លោក ខ្ញុំមុខជាទទួលការសង្គ្រោះមិនខាន» ។
២៩រំពេចនោះ ឈាមឈប់ធ្លាក់ភ្លាម ហើយនាងដឹងថា ខ្លួននាងបានជាសះស្បើយពីរោគា ។ ៣០នៅពេល
នោះ ព្រះយេស៊ូជ្រាបភ្លាមថា មានឫទ្ធានុភាពមួយចេញពីព្រះអង្គ ។ ព្រះអង្គបែរទៅរកបណ្តាជន ហើយ
មានព្រះបន្ទូលថា៖ «នរណាពាល់អាវខ្ញុំ ?» ។ ៣១ក្រុមសាវ័កទូលព្រះអង្គថា៖ «ព្រះគ្រូឃើញស្រាប់
ហើយ! បណ្តាជនប្រជ្រៀតប៉ះនឹងព្រះគ្រូគ្រប់គ្នា ចុះហេតុដូចម្តេចបានជាព្រះគ្រូសួរថា អ្នកណាពាល់
ព្រះគ្រូដូច្នេះ ?» ។ ៣២ព្រះយេស៊ូទតមើលជុំវិញដើម្បីឲ្យដឹងថា អ្នកណាបានពាល់ព្រះអង្គ ។ ៣៣ស្ត្រីនោះ
ភ័យញ័ររន្ធត់ ព្រោះនាងដឹងអំពីហេតុការណ៍ដែលកើតដល់ខ្លួននាង ។ នាងមកក្រាបទៀបព្រះបាទាព្រះ
យេស៊ូ ហើយទូលការពិតទាំងអស់ថ្វាយព្រះអង្គ ។ ៣៤ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «កូនស្រី

អើយ! ជំនឿរបស់នាងបានសង្គ្រោះនាងហើយ សូមអញ្ជើញទៅឲ្យបានសុខសាន្ត ហើយសូមឲ្យនាងជា
សះស្បើយពីជំងឺចុះ! » ។

[៣៥]កាលព្រះយេស៊ូកំពុងតែមានព្រះបន្ទូលនៅឡើយ មានគេមកពីផ្ទះលោកយ៉ៃរ៉ូស ជំរាបគាត់ថា៖
«កូនស្រីលោកផុតដង្ហើមទៅហើយ ម្ដេចក៏នៅរំខានលោកគ្រូធ្វើអ្វី? » ។ [៣៦]ព្រះយេស៊ូមិនយក
ព្រះហឫទ័យទុកដាក់នឹងពាក្យរបស់អ្នកទាំងនោះឡើយ តែព្រះអង្គមានព្រះបន្ទូលទៅលោកយ៉ៃរ៉ូសថា៖
«កុំខ្លាចអី គ្រាន់តែជឿប៉ុណ្ណោះបានហើយ» ។ [៣៧]ព្រះអង្គមិនអនុញ្ញាតឲ្យអ្នកណាទៅតាមព្រះអង្គឡើយ
លើកលែងតែលោកសិលា លោកយ៉ាកុប និងលោកយ៉ូហាន ជាប្អូនរបស់គាត់ប៉ុណ្ណោះ ។ [៣៨]កាលទៅដល់
ផ្ទះលោកយ៉ៃរ៉ូស ជាអ្នកទទួលខុសត្រូវលើធម្មសាលា ព្រះយេស៊ូទតឃើញមនុស្សម្នាជ្រួលច្របល់ ព្រម
ទាំងទ្រហោយំជាខ្លាំងផង ។ [៣៩]ព្រះអង្គយាងចូលទៅក្នុងផ្ទះ ហើយមានព្រះបន្ទូលទៅគេថា៖ «ហេតុដូច
ម្ដេចបានជាអ្នករាល់គ្នាជ្រួលច្របល់ ហើយទ្រហោយំដូច្នេះ? ក្មេងនេះមិនស្លាប់ទេ នាងគ្រាន់តែដេក
លក់ទេតើ! » ។ [៤០]គេនាំគ្នាចំអកដាក់ព្រះអង្គ ព្រះអង្គក៏ដេញគេឲ្យចេញទៅក្រៅទាំងអស់គ្នា រួចទ្រង់នាំ
តែឪពុកម្ដាយក្មេង និងសាវ័កទាំងបីនាក់ ចូលទៅក្នុងបន្ទប់ដែលក្មេងស្រីនោះដេក ។ [៤១]ព្រះអង្គចាប់ដៃ
ក្មេងស្រីនោះ ទាំងមានព្រះបន្ទូលថា៖ «តាលីថាគូម! » (ពាក្យនេះប្រែថា "នាងតូចអើយ ខ្ញុំប្រាប់នាង
ថាចូរក្រោកឡើង!") ។ [៤២]ក្មេងស្រីក៏ក្រោកឡើង ដើរមួយរំពេច ដ្បិតនាងមានអាយុដប់ពីរឆ្នាំហើយ ។
គេងឿងឆ្ងល់ពន់ប្រមាណ [៤៣]ប៉ុន្តែ ព្រះយេស៊ូហាមប្រាមគេ មិនឲ្យប្រាប់នរណាដឹងរឿងនេះឡើយ ។
បន្ទាប់មក ព្រះអង្គប្រាប់គេឲ្យយកចំណីអាហារមកឲ្យក្មេងស្រីនោះបរិភោគ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ១៤ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម លក ៤,១៨

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះអម្ចាស់ចាត់ព្រះយេស៊ូ ជាអ្នកបម្រើរបស់ព្រះអង្គ
ឲ្យមកនាំដំណឹងល្អស្ដីពីការសង្គ្រោះ ប្រាប់អ្នកក្រីក្រ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** ៦,១-៦

១ព្រះយេស៊ូយាងចេញទៅភូមិស្រុករបស់ព្រះអង្គ ក្រុមសាវ័កក៏ទៅតាមព្រះអង្គដែរ ។ ២លុះដល់ថ្ងៃ
សប្ប័ទ ព្រះអង្គបង្រៀនអ្នកស្រុកនៅក្នុងធម្មសាលា ។ មនុស្សជាច្រើនដែលបានស្ដាប់ព្រះអង្គ ងឿងឆ្ងល់
ក្រៃលែង ។ គេនិយាយគ្នាថា៖ «តើគាត់ដឹងសេចក្ដីទាំងនេះ មកពីណា? ប្រាជ្ញាដែលគាត់បានទទួល
នេះ ជាប្រាជ្ញាអ្វីទៅ? ការអស្ចារ្យដែលគាត់បានធ្វើនេះ កើតឡើងដោយវិធីណា? ៣តើអ្នកនេះមិនមែន
ជាជាងឈើ ជាកូននាងម៉ារី ជាបងប្អូនរបស់យ៉ាកុប យ៉ូសេ យូដា និងស៊ីម៉ូនទេឬអី? ប្អូនស្រីរបស់គាត់
ទាំងប៉ុន្មាន ក៏រស់នៅក្នុងភូមិនេះជាមួយយើងដែរ!» ។ ហេតុនេះហើយ បានជាគេមិនអាចជឿព្រះអង្គ
បានឡើយ ។ ៤ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ធម្មតា គេមើលងាយព្យាការីតែក្នុងស្រុកកំណើត
ក្នុងក្រុមគ្រួសារ និងក្នុងផ្ទះរបស់លោកប៉ុណ្ណោះ» ។ ៥នៅទីនោះ ព្រះអង្គពុំអាចធ្វើការអស្ចារ្យអ្វីបាន
ឡើយ បានត្រឹមតែដាក់ព្រះហស្ដលើអ្នកជំងឺខ្លះ ដើម្បីប្រោសគេឲ្យបានជាប៉ុណ្ណោះ ។ ៦ព្រះអង្គនឹកឆ្ងល់
ដោយឃើញគេគ្មានជំនឿបែបនេះ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ១៥ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម ទន ១៩,៦

**អាលេលូយ៉ា!** **អាលេលូយ៉ា!** គេថ្លែងព្រះបន្ទូលនៅលើផែនដីទាំងមូល
ហើយគេប្រកាសដំណឹងល្អ រហូតដល់ទីដាច់ស្រយាលនៃពិភពលោក ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** ៦,៧-១៣

៧ព្រះយេស៊ូត្រាស់ហៅសាវ័កទាំងដប់ពីររូបមក រួចព្រះអង្គចាត់គេពីរៗនាក់ឲ្យទៅទាំងប្រទានឲ្យគេ
មានអំណាចដេញខ្មោចផង ។ ៨ព្រះអង្គផ្ដែផ្ដាំគេមិនឲ្យយកអ្វីទៅជាមួយក្នុងពេលធ្វើដំណើរឡើយ លើក
លែងតែដំបងប៉ុណ្ណោះ៖ «កុំយកចំណីអាហារ ថង់យាម ឬយកប្រាក់កាសជាប់នឹងខ្លួន ៩ចូរពាក់ស្បែក
ជើង តែមិនត្រូវយកអាវពីរបន្លាស់ទៅជាមួយឲ្យសោះ» ។ ១០ព្រះអង្គមានព្រះបន្ទូលថា៖ «បើអ្នករាល់
គ្នាចូលផ្ទះណា ចូរស្នាក់នៅផ្ទះនោះ រហូតដល់ពេលអ្នករាល់គ្នាចេញពីស្រុកនោះទៅ ។ ១១បើនៅកន្លែង
ណាគេមិនព្រមទទួល មិនព្រមស្ដាប់អ្នករាល់គ្នា ចូរចេញពីកន្លែងនោះទៅ ហើយរលាស់ធូលីដីចេញពី
ជើងអ្នករាល់គ្នាផង ទុកជាសញ្ញាព្រមានគេ» ។

១២ក្រុមសាវ័កក៏ចេញទៅប្រកាសឲ្យមនុស្សម្នាប្រែចិត្តគំនិត ។ ១៣គេបានដេញអារក្សជាច្រើនចេញពី
មនុស្ស ព្រមទាំងចាក់ប្រេងលើអ្នកជំងឺច្រើននាក់ ដើម្បីប្រោសឲ្យគេបានជាសះស្បើយ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ១៦ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម យហ ១០,១៤-១៥

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះយេស៊ូជាគង្វាលដ៏ល្អប្រសើរ ព្រះអង្គស្គាល់ចៀម
របស់ព្រះអង្គ ចៀមរបស់ព្រះអង្គក៏ស្គាល់ព្រះអង្គដែរ ។
ព្រះយេស៊ូបានស៊ូប្ដូរជីវិតដើម្បីចៀមរបស់ព្រះអង្គ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** ៦,៣០-៣៤

៣០ក្រុមគ្រីស្ដទូតវិលត្រឡប់មកគាល់ព្រះយេស៊ូវិញ រៀបរាប់ទូលព្រះអង្គអំពីកិច្ចការទាំងប៉ុន្មាន
ដែលគេបានធ្វើ និងសេចក្ដីទាំងអស់ដែលគេបានបង្រៀន ។ ៣១មនុស្សជាច្រើនធ្វើដំណើរទៅមក ធ្វើឲ្យ
ព្រះយេស៊ូនិងក្រុមសាវ័ក រកពេលបរិភោគពុំបានសោះ ។ ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ក្រុមសាវ័ក
ថា៖ «ចូរនាំគ្នាមករកកន្លែងស្ងាត់ដាច់ឡែកពីបណ្ដាជន សម្រាកបន្តិចសិន» ។ ៣២ព្រះយេស៊ូក៏យាងចុះ
ទូកជាមួយក្រុមសាវ័កឆ្ពោះទៅកាន់កន្លែងមួយស្ងាត់ដាច់ឡែក ។ ៣៣ប៉ុន្តែ មានមនុស្សជាច្រើនបានឃើញ
ព្រះយេស៊ូ និងក្រុមសាវ័កចេញដំណើរទៅ គេក៏ស្គាល់ព្រះអង្គនិងសាវ័ក ហើយនាំគ្នារត់ចេញពីទីក្រុង
នានាទៅមុន ។

៣៤កាលព្រះយេស៊ូយាងឡើងពីទូកមក ទតឃើញមហាជនច្រើនយ៉ាងនេះ ទ្រង់មានព្រះហឫទ័យ
អាណិតអាសូរគេពន់ពេកណាស់ ព្រោះអ្នកទាំងនោះប្រៀបបីដូចជាចៀម ដែលគ្មានគង្វាលថែទាំ ។ ព្រះ
អង្គក៏បង្រៀនគេអំពីសេចក្ដីផ្សេងៗជាច្រើន ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ១៧ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** លក ៧,១៦

**អាលេលូយ៉ា! អាលេលូយ៉ា!** មានព្យាការីដ៏ប្រសើឧត្តមម្នាក់ បានមករស់នៅក្នុងចំណោមយើង ហើយព្រះជាម្ចាស់យាងមករំដោះប្រជារាស្ត្ររបស់ព្រះអង្គ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** ៦,១-១៥

[១]ព្រះយេស៊ូយាងទៅត្រើយខាងនាយសមុទ្រកាលីឡេ ដែលមានឈ្មោះថា សមុទ្រទីបេរីយ៉ាដ ។
[២]មានបណ្ដាជនច្រើនកុះករមកតាមព្រះអង្គ ព្រោះគេបានឃើញទីសម្គាល់ដែលព្រះអង្គបានធ្វើដោយ
ប្រោសអ្នកជំងឺឲ្យជា ។ [៣]ព្រះយេស៊ូយាងឡើងទៅលើភ្នំ ហើយគង់នៅទីនោះជាមួយក្រុមសាវ័ក ។
[៤]ពេលនោះបុណ្យចម្លង ជាបុណ្យរបស់ជនជាតិយូដា កាន់តែខិតជិតណាស់ហើយ ។ [៥]ព្រះយេស៊ូទត
ឃើញបណ្ដាជនមកតាមព្រះអង្គ ច្រើនកុះករយ៉ាងនេះ ទ្រង់មានព្រះបន្ទូលទៅលោកភីលីពថា៖ «តើ
យើងទៅរកទិញអាហារឯណា មកចែកឲ្យអ្នកទាំងនេះបរិភោគបាន?» ។ [៦]ព្រះអង្គមានព្រះបន្ទូល
ដូច្នេះ ដើម្បីល្បងមើលចិត្តលោកភីលីព តាមពិតព្រះអង្គជ្រាបអំពីកិច្ចការដែលព្រះអង្គបម្រុងនឹងធ្វើ
ស្រេចទៅហើយ ។ [៧]លោកភីលីពទូលថា៖ «ទោះបីយើងយកប្រាក់ពីររយដួងទៅទិញនំបុ័ងក៏មិនគ្រាន់
ដែរ សូម្បីតែម្នាក់មួយដុំតូចៗក៏មិនបានផង» ។ [៨]មានសាវ័កម្នាក់ឈ្មោះអន់ដ្រេ ជាប្អូនរបស់លោកសិលា
ទូលព្រះអង្គថា៖ [៩]«នៅទីនេះ ក្មេងប្រុសម្នាក់មាននំបុ័ងប្រាំដុំ និងត្រីតូចៗពីរកន្ទុយ ។ ប៉ុន្តែ បើមានតែ
ប៉ុណ្ណឹង ធ្វើម្ដេចនឹងឲ្យគ្រាន់សម្រាប់មនុស្សដ៏ច្រើនយ៉ាងនេះ?» ។ [១០]ព្រះយេស៊ូមានព្រះបន្ទូលថា៖ «សុំ
ឲ្យគេអង្គុយចុះ» ។ នៅទីនោះ មានស្មៅច្រើន ។ បណ្ដាជនក៏នាំគ្នាអង្គុយ មានមនុស្សប្រុសទាំងអស់
ប្រមាណប្រាំពាន់នាក់ ។ [១១]ព្រះយេស៊ូយកនំបុ័ងមកកាន់ អរព្រះគុណព្រះជាម្ចាស់ រួចប្រទានឲ្យអ្នកអង្គុយ
នៅទីនោះ ។ រីឯត្រីវិញ ព្រះអង្គក៏ធ្វើដូច្នោះដែរ ទ្រង់ប្រទានឲ្យគេតាមតែម្នាក់ៗចង់បាន ។ [១២]លុះគេ
បានបរិភោគឆ្អែតហើយ ព្រះយេស៊ូមានព្រះបន្ទូលទៅក្រុមសាវ័កថា៖ «ចូរប្រមូលនំបុ័ងដែលនៅសល់ កុំ
ឲ្យមានបាត់មួយដុំសោះឡើយ» ។ [១៣]ពួកសាវ័កនាំគ្នារើសសំណល់នំបុ័ងទាំងប្រាំដុំ ដែលបណ្ដាជនបរិភោគ
សល់ ប្រមូលដាក់បានពេញជប់ពីរល្អី ។ [១៤]កាលមនុស្សម្នាឃើញទីសម្គាល់ ដែលព្រះយេស៊ូបានធ្វើនោះ
គេពោលថា៖ «លោកនេះពិតជាព្យាការីដែលត្រូវមកក្នុងពិភពលោកមែន» ។ [១៥]ព្រះយេស៊ូជ្រាបថា
គេបម្រុងនឹងចាប់ព្រះអង្គយកទៅតែងតាំងជាស្ដេច ។ ហេតុនេះ ព្រះអង្គយាងចាកចេញពីគេ ឡើងទៅ
លើភ្នំសាជាថ្មី តែមួយព្រះអង្គឯង ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ១៨ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម ទន ៧៨,២៤**

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះអម្ចាស់ប្រទានអាហារឲ្យប្រជារាស្ត្ររបស់ព្រះអង្គ
នៅវាលរហោស្ថាន គឺព្រះអង្គប្រទានអាហារដែលចុះពីស្ថានបរមសុខមក ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** **៦,២៤-៣៥**

[២៤]បណ្ដាជនពុំឃើញព្រះយេស៊ូ និងក្រុមសាវ័កនៅតាមមាត់បឹង ។ គេក៏នាំគ្នាចុះទូកឆ្លងទៅក្រុងកា
ផានុមតាមរកព្រះអង្គ ។
[២៥]បណ្ដាជនបានជួបព្រះអង្គ នៅត្រើយម្ខាង គេទូលសួរព្រះអង្គថា៖ «លោកគ្រូ ! តើលោកមកដល់
ពីអង្កាល់ ?» ។ [២៦]ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នករាល់
គ្នាតាមរកខ្ញុំ មិនមែនមកពីអ្នករាល់គ្នាបានឃើញទីសម្គាល់ទេ គឺមកពីអ្នករាល់គ្នាបានបរិភោគអាហារ
ឆ្អែតតែប៉ុណ្ណោះ ។ [២៧]កុំធ្វើកិច្ចការ ដើម្បីឲ្យគ្រាន់តែបានអាហារ ដែលតែងរលួយខូចនោះឡើយ គឺត្រូវ
ធ្វើឲ្យបានអាហារដែលនៅស្ថិតស្ថេរ និងផ្ដល់ជីវិតអស់កល្បជានិច្ចវិញ ជាអាហារដែលបុត្រមនុស្សនឹង
ប្រទានឲ្យអ្នករាល់គ្នា ដ្បិតបុត្រមនុស្សនេះហើយ ដែលព្រះជាម្ចាស់ជាព្រះបិតាបានដៅសញ្ញាសម្គាល់»
។ [២៨]គេនាំគ្នាទូលសួរព្រះអង្គថា៖ «តើឲ្យយើងខ្ញុំប្រព្រឹត្តដូចម្ដេច ដើម្បីនឹងធ្វើកិច្ចការរបស់ព្រះជា
ម្ចាស់ ?» ។ [២៩]ព្រះយេស៊ូមានព្រះបន្ទូលថា៖ «កិច្ចការរបស់ព្រះជាម្ចាស់ គឺឲ្យអ្នករាល់គ្នាជឿលើអ្នក
ដែលព្រះអង្គបានចាត់ឲ្យមក» ។ [៣០]គេទូលសួរព្រះអង្គទៀតថា៖ «តើលោកធ្វើកិច្ចការអ្វីជាទីសម្គាល់ឲ្យ
យើងខ្ញុំឃើញ និងជឿលោក? តើលោកធ្វើកិច្ចការអ្វីខ្លះ? ។ [៣១]បុព្វបុរសរបស់យើងបានបរិភោគនំម៉ា
ណានៅវាលរហោស្ថាន ដូចមានសេចក្ដីចែងទុកក្នុងគម្ពីរថា "ព្រះអង្គបានប្រទានឲ្យគេបរិភោគនំប៉័ង
ដែលធ្លាក់ពីស្ថានបរមសុខមក"» ។ [៣២]ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នា
ដឹងច្បាស់ថា មិនមែនលោកម៉ូសេទេ ដែលបានផ្ដល់អាហារពីស្ថានបរមសុខមកនោះ គឺព្រះបិតារបស់ខ្ញុំ
ទេតើ ដែលប្រទានអាហារដ៏ពិតប្រាកដពីស្ថានបរមសុខ មកឲ្យអ្នករាល់គ្នា [៣៣]ដ្បិតអាហារ ដែលព្រះជា
ម្ចាស់ប្រទានឲ្យនោះ គឺអាហារដែលចុះពីស្ថានបរមសុខមក ហើយដែលផ្ដល់ជីវិតឲ្យមនុស្សលោក» ។ [៣៤]
គេនាំគ្នាទូលព្រះអង្គថា៖ «លោកម្ចាស់អើយ! សូមលោកប្រទានអាហារនោះឲ្យយើងខ្ញុំរហូតតទៅ» ។
[៣៥]ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ខ្ញុំនេះហើយជាអាហារដែលផ្ដល់ជីវិត ។ អ្នកណាមករកខ្ញុំ លែងឃ្លាន
ទៀតហើយ អ្នកណាជឿលើខ្ញុំ ក៏លែងស្រេកទៀតដែរ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ១៩ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម យហ ៦,៥១-៥២

**អាលេលូយ៉ា! អាលេលូយ៉ា!** បពិត្រព្រះអម្ចាស់យេស៊ូ! ព្រះអង្គជាអាហារដែលមានជីវិត ចុះមកពីស្ថានបរមសុខ ។ អ្នកបរិភោគអាហារនេះនឹងរស់នៅអស់កល្បជានិច្ច ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** ៦,៤១-៥១

៤១ជនជាតិយូដារអ៊ូរទាំអំពីព្រះយេស៊ូ ព្រោះព្រះអង្គមានព្រះបន្ទូលថា៖ «ខ្ញុំជាអាហារ ដែលចុះមក
ពីស្ថានបរមសុខ» ។ ៤២ គេពោលថា៖ «អ្នកនេះឈ្មោះយេស៊ូ ជាកូនរបស់លោកយ៉ូសែបទេតើ! យើង
ស្គាល់ទាំងឪពុក ទាំងម្ដាយ ម្ដេចក៏គាត់ពោលថា គាត់ចុះមកពីស្ថានបរមសុខដូច្នេះ? » ។ ៤៣ព្រះយេស៊ូ
មានព្រះបន្ទូលទៅគេថា៖ «ឈប់នាំគ្នារអ៊ូរទាំទៅ! ។ ៤៤ប្រសិនបើព្រះបិតាដែលចាត់ខ្ញុំឲ្យមក មិនទាក់
ទាញចិត្តគេទេ គ្មាននរណាម្នាក់អាចមករកខ្ញុំបានឡើយ ។ រីឯខ្ញុំ ខ្ញុំនឹងប្រោសអ្នកនោះឲ្យមានជីវិថ្មីដ៏
រុងរឿងនៅថ្ងៃចុងក្រោយបំផុត ។ ៤៥ក្នុងគម្ពីរព្យាការី មានចែងទុកមកថា "ព្រះជាម្ចាស់នឹងប្រៀន
ប្រដៅមនុស្សទាំងអស់" ។ អស់អ្នកដែលស្ដាប់ព្រះបិតា ហើយទទួលយកការប្រៀនប្រដៅរបស់ព្រះអង្គ
មុខជាមករកខ្ញុំពុំខាន ។ ៤៦គ្មាននរណាម្នាក់បានឃើញព្រះបិតាឡើយ លើកលែងតែអ្នកមកពីព្រះជា
ម្ចាស់ប៉ុណ្ណោះ គឺអ្នកនោះហើយដែលបានឃើញព្រះអង្គ ។ ៤៧ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នក
ណាជឿ អ្នកនោះមានជីវិតរស់នៅអស់កល្បជានិច្ច ។ ៤៨ខ្ញុំនេះហើយជាអាហារដែលផ្ដល់ជីវិត ។
៤៩បុព្វបុរសរបស់អ្នករាល់គ្នា បានបរិភោគនំម៉ាណានៅវាលរហោស្ថាន ហើយគាត់ទទួលមរណភាពអស់ ។
៥០រីឯអាហារដែលចុះមកពីស្ថានបរមសុខនេះ អ្នកណាបរិភោគ អ្នកនោះមិនស្លាប់ឡើយ ។ ៥១ខ្ញុំនេះហើយ
ជាអាហារដែលមានជីវិតចុះមកពីស្ថានបរមសុខ ។ អ្នកណាបរិភោគអាហារនេះ នឹងរស់នៅអស់កល្បជា
និច្ច ។ អាហារដែលខ្ញុំនឹងឲ្យនោះ គឺរូបកាយខ្ញុំផ្ទាល់ ដែលត្រូវបូជាសម្រាប់ឲ្យមនុស្សលោកមានជីវិត» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២០ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម ទន ១៤៥,១៥**

**អាលេលូយ៉ា! អាលេលូយ៉ា!** បពិត្រព្រះអម្ចាស់! មនុស្សទាំងអស់សម្លឹងមើលព្រះអង្គ
ដោយចិត្តសង្ឃឹម ។ ព្រះអង្គប្រទានឲ្យគេមានអាហារបរិភោគនៅពេលគេត្រូវការ
គឺព្រះកាយ និងព្រះលោហិតនៃកូនចៀមដែលគេបានបូជា ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** **៦,៥១-៥៨**

ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់បណ្ដាជនថា៖ [៥១]«ខ្ញុំនេះហើយជាអាហារដែលមានជីវិត ចុះមកពី
ស្ថានបរមសុខ ។ អ្នកណាបរិភោគអាហារនេះ នឹងរស់នៅអស់កល្បជានិច្ច ។ អាហារដែលខ្ញុំនឹងឲ្យនោះ
គឺរូបកាយខ្ញុំផ្ទាល់ ដែលត្រូវបូជាសម្រាប់ឲ្យមនុស្សលោកមានជីវិត» ។

[៥២]ជនជាតិយូដាទាស់ទែងគ្នាយ៉ាងខ្លាំង ហើយគេនិយាយថា៖ «តើអ្នកនេះអាចឲ្យរូបកាយគាត់មក
យើងបរិភោគដូចម្ដេចកើត? » ។

[៥៣] ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា ប្រសិនបើអ្នករាល់គ្នា
មិនពិសាសាច់ និងលោហិតរបស់បុត្រមនុស្សទេ អ្នករាល់គ្នាគ្មានជីវិតនៅក្នុងខ្លួនឡើយ ។ [៥៤]អ្នកណាពិសា
សាច់និងលោហិតរបស់ខ្ញុំ អ្នកនោះមានជីវិតអស់កល្បជានិច្ច ហើយនៅថ្ងៃចុងក្រោយបំផុត ខ្ញុំក៏នឹង
ប្រោសគេឲ្យមានជីវិតដ៏រុងរឿងផង ។ [៥៥]សាច់របស់ខ្ញុំជាអាហារដ៏ពិតប្រាកដ លោហិតរបស់ខ្ញុំ ក៏ជាភេ
សជ្ជៈដ៏ពិតប្រាកដដែរ ។ [៥៦]អ្នកណាពិសាសាច់និងលោហិតរបស់ខ្ញុំ អ្នកនោះស្ថិតនៅក្នុងខ្ញុំ ហើយខ្ញុំក៏ស្ថិត
នៅក្នុងអ្នកនោះដែរ ។ [៥៧]ព្រះបិតាដែលបានចាត់ខ្ញុំឲ្យមក ទ្រង់មានព្រះជន្ម ហើយខ្ញុំមានជីវិតដោយសារ
ព្រះអង្គយ៉ាងណា អ្នកបរិភោគខ្ញុំ ក៏នឹងមានជីវិតក៏ដោយសារខ្ញុំយ៉ាងនោះដែរ ។ [៥៨]អាហារដែលបានចុះ
ពីស្ថានបរមសុខមក ខុសប្លែកពីអាហារដែលបុព្វបុរសរបស់អ្នករាល់គ្នាបានបរិភោគ ដ្បិតលោកទទួល
មរណភាពអស់ទៅហើយ ។ រីឯអ្នកដែលបរិភោគអាហារនេះនឹងរស់នៅអស់កល្បជានិច្ច» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២១ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម យហ ៦,៦៣.៦៨

**អាលេលូយ៉ា! អាលេលូយ៉ា!** បពិត្រព្រះអម្ចាស់! ព្រះបន្ទូលរបស់ព្រះអង្គជាព្រះវិញ្ញាណ
និងជាជីវិត! ព្រះអង្គមានព្រះបន្ទូលដែលផ្ដល់ជីវិតអស់កល្បជានិច្ច ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** ៦,៦០-៦៩

ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់បណ្ដាជនក្នុងធម្មសាលាក្រុងកាផានុមថា៖ «អ្នកណាពិសាសាច់និង
លោហិតរបស់ខ្ញុំ អ្នកនោះមានជីវិតអស់កល្បជានិច្ច» ។ ៦០ក្រោយពីបានស្ដាប់ព្រះបន្ទូលរបស់ព្រះអង្គ
ហើយ មានគ្នាច្រើនក្នុងចំណោមសាវ័កពោលថា៖ «ពាក្យទាំងនេះទាស់ត្រចៀកណាស់ តើនរណាអាច
ទ្រាំស្ដាប់បាន?» ។ ៦១ព្រះយេស៊ូឈ្វេងយល់ថា ក្រុមសាវ័ករអ៊ូរទាំពីពាក្យទាំងនេះ ព្រះអង្គមានព្រះ
បន្ទូលទៅគេថា៖ «តើសេចក្ដីទាំងនេះនាំឲ្យអ្នករាល់គ្នារវាតចិត្ត បាត់ជំនឿឬ? ៦២ចុះបើអ្នករាល់គ្នា
ឃើញបុត្រមនុស្សឡើងទៅស្ថានដែលលោកនៅពីមុនវិញ តើចិត្តអ្នករាល់គ្នានឹងទៅជាយ៉ាងណា? ។
៦៣មានតែព្រះវិញ្ញាណទេដែលផ្ដល់ជីវិត និស្ស័យលោកីយ៍មិនអាចផ្ដល់ជីវិតបានឡើយ ។ រីឯពាក្យទាំង
ប៉ុន្មានដែលខ្ញុំបាននិយាយប្រាប់អ្នករាល់គ្នា សុទ្ធតែចេញមកពីព្រះវិញ្ញាណដែលផ្ដល់ជីវិត ។ ៦៤ប៉ុន្តែ ក្នុង
ចំណោមអ្នករាល់គ្នា អ្នកខ្លះគ្មានជំនឿទេ» ។ តាំងពីដើមដំបូងមក ព្រះយេស៊ូស្គាល់អស់អ្នកដែលមិនជឿ
ព្រមទាំងស្គាល់អ្នកដែលនឹងក្បត់ព្រះអង្គរួចស្រេចទៅហើយ ។ ៦៥ព្រះអង្គមានព្រះបន្ទូលទៀតថា៖
«ហេតុនេះហើយ បានជាខ្ញុំប្រាប់អ្នករាល់គ្នារួចមកហើយថា ប្រសិនបើព្រះបិតាមិនប្រោសប្រទានទេនោះ
គ្មាននរណាអាចមករកខ្ញុំបានឡើយ» ។ ៦៦ចាប់ពីពេលនោះមក មានគ្នាច្រើនក្នុងចំណោមសាវ័ក ដកខ្លួន
ថយ ឈប់តាមព្រះអង្គទៀត ។ ៦៧ព្រះយេស៊ូក៏មានព្រះបន្ទូលសួរសាវ័កទាំងដប់ពីរនាក់ថា៖ «ចុះអ្នក
រាល់គ្នាវិញ តើអ្នករាល់គ្នាចង់ចេញទៅដែរឬ?» ។ ៦៨លោកស៊ីម៉ូនសិលាទូលព្រះអង្គថា៖ «បពិត្រព្រះ
អម្ចាស់! តើឲ្យយើងខ្ញុំទៅរកនរណាវិញ? ព្រះបន្ទូលរបស់ព្រះអង្គផ្ដល់ជីវិតអស់កល្បជានិច្ច ។ ៦៩យើង
ខ្ញុំជឿ ហើយដឹងថា ព្រះអង្គពិតជាព្រះដ៏វិសុទ្ធដែលព្រះជាម្ចាស់ចាត់ឲ្យមក» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២២ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម ១ សម ១៦,៧**

**អាលេលូយ៉ា! អាលេលូយ៉ា!** បពិត្រព្រះអម្ចាស់! ព្រះបន្ទូលរបស់ព្រះអង្គជាព្រះវិញ្ញាណ និងជាជីវិត! ព្រះអង្គមានព្រះបន្ទូលដែលផ្ដល់ជីវិតអស់កល្បជានិច្ច ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** **៧,១-៨.១៤-១៥.២១-២៣**

[១]ពួកខាងគណៈផារីស៊ីនិងធម្មាចារ្យខ្លះ នាំគ្នាមកពីក្រុងយេរូសាឡឹម ទៅជួបព្រះយេស៊ូ ។ [២]គេឃើញសាវ័កខ្លះបរិភោគអាហារដោយដៃមិនបរិសុទ្ធ គឺសាវ័កមិនបានលាងដៃជាមុន ។ [៣]ធម្មតា ពួកផារីស៊ីនិងជនជាតិយូដាទាំងអស់ តែងតែធ្វើពិធីលាងដៃយ៉ាងស្អាតហ្មត់ចត់ មុននឹងបរិភោគ តាមទំនៀមទម្លាប់របស់ចាស់បុរាណ ។ [៤]នៅពេលត្រឡប់មកពីផ្សារវិញ ដរាបណាគេមិនបានធ្វើពិធីលាងសម្អាតខ្លួនជាមុនទេ គេមិនបរិភោគឡើយ ។ គេកាន់ទំនៀមទម្លាប់ផ្សេងៗទៀតជាច្រើន ដូចជាពិធីលាងពែង លាងថូទឹក លាងឆ្នាំង លាងតុជាដើម ។ [៥]ពួកខាងគណៈផារីស៊ីនិងពួកធម្មាចារ្យទូលសួរព្រះយេស៊ូថា៖ «ហេតុអ្វីបានជាសិស្សរបស់លោកមិនកាន់តាមទំនៀមទម្លាប់ចាស់បុរាណ គឺនាំគ្នាបរិភោគដោយដៃមិនបរិសុទ្ធដូច្នេះ?» ។ [៦]ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ព្យាការីអេសាយបានថ្លែងទុកថា "អ្នករាល់គ្នាជាមនុស្សមានពុត" ត្រូវណាស់! ដូចមានចែងថា៖ "ប្រជារាស្ត្រនេះគោរពយើង តែបបូរមាត់ ឯចិត្តគេនៅឆ្ងាយពីយើង ។ [៧]គេថ្វាយបង្គំយើង តែឥតបានការអ្វីសោះ ព្រោះគេបង្រៀនតែក្បួនច្បាប់របស់មនុស្សប៉ុណ្ណោះ" ។ [៨]អ្នករាល់គ្នាបោះបង់ចោលវិន័យរបស់ព្រះជាម្ចាស់ បែរទៅកាន់តាមទំនៀមទម្លាប់របស់មនុស្សវិញ» ។

[១៤]បន្ទាប់មក ព្រះយេស៊ូត្រាស់ហៅបណ្ដាជនមកម្ដងទៀត រួចមានព្រះបន្ទូលទៅគេថា៖ «ចូរស្ដាប់ខ្ញុំទាំងអស់គ្នា ហើយយល់ឲ្យច្បាស់ថា [១៥]អ្វីៗពីខាងក្រៅ ចូលទៅក្នុងមនុស្ស មិនអាចធ្វើឲ្យមនុស្សក្លាយទៅជាមិនបរិសុទ្ធបានឡើយ ។ ផ្ទុយទៅវិញ មានតែអ្វីៗចេញពីមនុស្សប៉ុណ្ណោះ ដែលធ្វើឲ្យមិនបរិសុទ្ធ» ។

ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ក្រុមសាវ័កដោយឡែកពីបណ្ដាជនថា៖ [២១]«គំនិតអាក្រក់ទាំងប៉ុន្មានសុទ្ធតែចេញមកពីខាងក្នុងចិត្តរបស់មនុស្ស គឺគំនិតដែលនាំឲ្យប្រព្រឹត្តកាមគុណថោកទាប លួចប្លន់ កាប់សម្លាប់ [២២]ផិតក្បត់ លោភលន់ចង់បានទ្រព្យគេ កាចសាហាវ បោកប្រាស់គេ ប្រព្រឹត្តអបាយមុខ ច្រណែនឈ្នានីស អំនួត និង គំនិតលេលា ។ [២៣]ការអាក្រក់ទាំងនេះហើយ ដែលចេញពីខាងក្នុងមនុស្សមក ធ្វើឲ្យគេក្លាយទៅជាមិនបរិសុទ្ធ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២៣ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម ១ សម ១៦,៧

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះយេស៊ូប្រកាសដំណឹងល្អអំពីព្រះរាជ្យ
ហើយប្រោសប្រជារាស្ត្ររបស់ព្រះអង្គឲ្យបានជាសះស្បើយផង ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** ៧,៣១-៣៧

[៣១]ព្រះយេស៊ូយាងចេញពីតំបន់ក្រុងទីរ៉ូស កាត់តាមតំបន់ក្រុងស៊ីដូន និងតំបន់ស្រុកដេកាប៉ូល ឆ្ពោះ
ទៅសមុទ្រកាលីឡេវិញ ។ [៣២]គេនាំបុរសថ្លង់ម្នាក់មកគាល់ព្រះអង្គ ។ ម្យ៉ាងទៀត បុរសនោះពុំអាច
និយាយបានស្រួលដូចធម្មតាផង ។ គេទូលអង្វរសូមឲ្យព្រះអង្គដាក់ព្រះហស្ដលើគាត់ ។ [៣៣]ព្រះអង្គនាំ
គាត់ចេញទៅដោយឡែកដាច់ពីបណ្ដាជន ទ្រង់ដាក់ព្រះអង្គុលីក្នុងត្រចៀកគាត់ ហើយស្ដោះទឹកព្រះឱស្ឋ
យកទៅផ្ជិតលើអណ្ដាតគាត់ [៣៤]រួចព្រះអង្គងើបព្រះភ័ក្ត្រឡើង ទតទៅលើមេឃ ដកដង្ហើមធំ ហើយមាន
ព្រះបន្ទូលថា៖ «អេផាថា» (ពាក្យនេះប្រែថា "ចូរបើកឡើង") ។ [៣៥]រំពេចនោះ ស្រាប់តែត្រចៀក
របស់បុរសនោះអាចស្ដាប់ឮ អណ្ដាតរបស់គាត់ក៏គ្រលាស់បាន ហើយគាត់ក៏និយាយស្ដីបានច្បាស់លាស់ ។
[៣៦]ព្រះយេស៊ូហាមប្រាមពួកគេ មិនឲ្យនិយាយហេតុការណ៍នេះប្រាប់នរណាសោះឡើយ ។ ប៉ុន្តែ ទោះបី
ព្រះអង្គហាមប្រាមយ៉ាងណាក៏ដោយ ក៏គេរឹតតែប្រកាសខ្លាំងឡើងៗ ។ [៣៧]មនុស្សម្នាងឿងឆ្ងល់ពន់ពេក
ណាស់ ហើយពោលថា៖ «គ្រប់កិច្ចការដែលលោកធ្វើ សុទ្ធតែល្អទាំងអស់! សូម្បីតែមនុស្សថ្លង់ ក៏លោក
ធ្វើឲ្យឮបាន មនុស្សគក៏លោកធ្វើឲ្យនិយាយបានដែរ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២៤ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម កាឡ ៦,១៤

**អាលេលូយ៉ា! អាលេលូយ៉ា!** យើងខ្ពស់មុខដោយសារតែឈើឆ្កាងរបស់ព្រះអម្ចាស់! ។ ដោយសារព្រះអង្គ យើងបាត់ទុកមនុស្សលោកដូចជាជាប់ឆ្កាង ។ ដោយសារឈើឆ្កាងនេះ អ្វីៗក្នុងពិភពលោកលែងមានទាក់ទាមនឹងយើងទៀតហើយ ហើយខ្ញុំក៏លែងមានទាក់ទាមអ្វីនឹងពិភពលោកទៀតដែរ ។ **អាលេលូយ៉ា!**

## ✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស ៨,២៧-៣៦

[២៧]ព្រះយេស៊ូចេញទៅជាមួយក្រុមសាវ័កតាមភូមិនានា ដែលនៅជិតក្រុងសេសារេភីលីព ។ នៅតាម
ផ្លូវ ព្រះអង្គមានព្រះបន្ទូលសួរគេថា៖ «តើមនុស្សទាំងឡាយថា ខ្ញុំជានរណា?» ។ [២៨]ក្រុមសាវ័កទូល
ឆ្លើយថា៖ «អ្នកខ្លះថា លោកជាលោកយ៉ូហានបាទីស្ដ អ្នកខ្លះថា លោកជាព្យាការីអេលី ហើយអ្នកខ្លះ
ទៀតថា លោកជាព្យាការីម្នាក់» ។ [២៩]ព្រះអង្គមានព្រះបន្ទូលសួរគេថា៖ «ចុះអ្នករាល់គ្នាវិញ តើអ្នក
រាល់គ្នាថាខ្ញុំជានរណាដែរ?» ។ លោកសិលាទូលព្រះអង្គថា៖ «លោកជាព្រះគ្រីស្ដ» ។ [៣០]ព្រះយេស៊ូ
ហាមប្រាមសាវ័កមិនឲ្យនិយាយប្រាប់គេ អំពីព្រះអង្គឡើយ ។

[៣១]បន្ទាប់មក ព្រះយេស៊ូក៏ចាប់ផ្ដើមបង្រៀនពួកសាវ័កថា បុត្រមនុស្សត្រូវរងទុក្ខលំបាកយ៉ាងខ្លាំង ។
ពួកព្រឹទ្ធាចារ្យ ពួកនាយកបូជាចារ្យ ពួកធម្មាចារ្យនឹងបោះបង់ព្រះអង្គចោល ថែមទាំងធ្វើគុតព្រះអង្គ
ទៀតផង តែបីថ្ងៃក្រោយមក ព្រះអង្គនឹងមានព្រះជន្មរស់រុងរឿង ។ [៣២]ព្រះអង្គមានព្រះបន្ទូលបញ្ជាក់
ប្រាប់គេដោយឥតលាក់លៀមអ្វីឡើយ ។ លោកសិលាយាងព្រះអង្គចេញទៅឆ្ងាយពីគេបន្តិច ហើយស្ដី
បន្ទោសព្រះអង្គ ។ [៣៣]ព្រះយេស៊ូងាកទតទៅក្រុមសាវ័កឯទៀតៗ ហើយទ្រង់មានព្រះបន្ទូលបន្ទោស
លោកសិលាវិញថា៖ «នែ៎! មារសាតាំង ថយទៅក្រោយខ្ញុំទៅ! ដ្បិតគំនិតអ្នកមិនមែនជាគំនិតរបស់
ព្រះជាម្ចាស់ទេ គឺជាគំនិតរបស់មនុស្សសុទ្ធសាធ» ។

[៣៤]បន្ទាប់មក ព្រះអង្គត្រាស់ហៅបណ្ដាជននិងសាវ័ក រួចមានព្រះបន្ទូលទៅគេថា៖ «បើអ្នកណាចង់
មកតាមក្រោយខ្ញុំ ត្រូវលះបង់ខ្លួនឯងចោល ត្រូវលីឈើឆ្កាងរបស់ខ្លួន ហើយមកតាមខ្ញុំចុះ [៣៥]ដ្បិតអ្នកណា
ចង់បានរួចជីវិត អ្នកនោះនឹងបាត់បង់ជីវិតពុំខាន រីឯអ្នកដែលបាត់បង់ជីវិតព្រោះតែខ្ញុំនិងព្រោះតែ
ដំណឹងល្អ នឹងបានជីវិតវិញ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២៥ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម ២ ថស ២,១៤

**អាលេលូយ៉ា! អាលេលូយ៉ា!** ដោយគ្រីស្តទូតប្រកាសដំណឹងល្អ ព្រះជាម្ចាស់ត្រាស់ហៅយើង ឲ្យទទួលសិរីរុងរឿងរបស់ព្រះយេស៊ូគ្រីស្ត ជាអម្ចាស់នៃយើង ។ **អាលេលូយ៉ា!**

## ✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស ៩,៣០-៣៧

[៣០]ព្រះយេស៊ូជាមួយក្រុមសាវ័ក យាងកាត់តាមស្រុកកាលីឡេ ។ ព្រះអង្គមិនសព្វព្រះហឫទ័យ ឲ្យ
នរណាដឹងឮឡើយ ។ [៣១]ព្រះអង្គបង្រៀនក្រុមសាវ័កឲ្យដឹងថា បុត្រមនុស្សនឹងត្រូវគេបញ្ជូនទៅក្នុងក
ណ្ដាប់ដៃរបស់មនុស្សលោក គេនឹងធ្វើគុតព្រះអង្គ ប៉ុន្តែ បីថ្ងៃក្រោយពីគេធ្វើគុត ទ្រង់នឹងទទួលព្រះជន្ម
ដ៏រុងរឿង ។ [៣២]ក្រុមសាវ័កពុំបានយល់ព្រះបន្ទូលនេះឡើយ តែគេមិនហ៊ានទូលសួរព្រះអង្គទេ ។

[៣៣]ព្រះយេស៊ូនិងក្រុមសាវ័កធ្វើដំណើរមកដល់ក្រុងកាផានុម ។ កាលព្រះអង្គគង់នៅក្នុងផ្ទះ ព្រះអង្គ
មានព្រះបន្ទូលសួរក្រុមសាវ័កថា៖ «ពេលដើរតាមផ្លូវ អ្នករាល់គ្នានិយាយអំពីរឿងអ្វី?» ។ [៣៤]ក្រុម
សាវ័កនៅស្ងៀម ដ្បិតកាលធ្វើដំណើរតាមផ្លូវ គេបានប្រកែកគ្នាចង់ដឹងថា ក្នុងចំណោមពួកគេ អ្នកណា
ធំជាង ។ [៣៥]ព្រះយេស៊ូគង់ចុះ ព្រះអង្គត្រាស់ហៅសាវ័កទាំងដប់ពីរនាក់មក ហើយមានព្រះបន្ទូលថា៖
«អ្នកណាចង់ធ្វើមេគេ អ្នកនោះត្រូវដាក់ខ្លួនឲ្យតូចជាងគេ ព្រមទាំងបម្រើគេទាំងអស់គ្នាផង» ។
[៣៦]បន្ទាប់មក ព្រះអង្គយកក្មេងម្នាក់ឲ្យមកឈរនៅកណ្ដាលក្រុមសាវ័ក ។ ព្រះអង្គឱបក្មេងនោះ រួចមាន
ព្រះបន្ទូលទៅកាន់ក្រុមសាវ័កថា៖ [៣៧]«អ្នកណាទទួលក្មេងណាម្នាក់ដូចក្មេងនេះ ក្នុងនាមខ្ញុំ ក៏ដូចជា
ទទួលខ្ញុំ ហើយអ្នកណាទទួលខ្ញុំ មិនត្រឹមតែទទួលខ្ញុំប៉ុណ្ណោះទេ គឺទទួលព្រះអង្គដែលបានចាត់ខ្ញុំឲ្យមក
នោះដែរ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២៦ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម ២ ធម ២,១៤**

**អាលេលូយ៉ា! អាលេលូយ៉ា!** បពិត្រព្រះអម្ចាស់! ព្រះបន្ទូលរបស់ព្រះអង្គជាសេចក្ដីពិត!
សូមប្រោសយើងខ្ញុំឲ្យបានវិសុទ្ធ ដោយសារសេចក្ដីពិតនេះ! ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** **៩,៣៨-៤៣.៤៥.៤៧-៤៨**

[៣៨]លោកយ៉ូហាន ជាសាវ័កម្នាក់ក្នុងចំណោមសាវ័កទាំងដប់ពីរ ទូលព្រះអង្គថា៖ «ព្រះគ្រូ! យើងខ្ញុំ
ឃើញបុរសម្នាក់ដេញខ្មោចក្នុងនាមព្រះគ្រូ ។ យើងខ្ញុំបានឃាត់គេ ព្រោះគេមិនមកតាមយើងខ្ញុំទេ» ។
[៣៩]ព្រះយេស៊ូមានព្រះបន្ទូលថា៖ «កុំឃាត់គេអី ពុំដែលមាននរណាអាចធ្វើការអស្ចារ្យក្នុងនាមខ្ញុំ រួចបែរ
ជានិយាយអាក្រក់អំពីខ្ញុំភ្លាមនោះឡើយ [៤០]ដ្បិតអ្នកណាមិនជំទាស់នឹងយើង អ្នកនោះជាគ្នាយើងហើយ ។
[៤១]ម្យ៉ាងទៀត បើអ្នកណាឲ្យទឹកមួយកែវដល់អ្នករាល់គ្នា ក្នុងនាមអ្នករាល់គ្នាជាសិស្សរបស់ព្រះគ្រីស្ត ខ្ញុំសុំ
ប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នកនោះនឹងទទួលរង្វាន់ជាមិនខាន» ។

[៤២]អ្នកណានាំអ្នកតូចតាចម្នាក់ក្នុងបណ្ដាអ្នកជឿទាំងនេះ ឲ្យប្រព្រឹត្តអំពើបាប ចំពោះអ្នកនោះប្រសិន
បើគេយកត្បាល់ថ្មយ៉ាងធំ មកចងកគាត់ទម្លាក់ទៅក្នុងសមុទ្រ នោះប្រសើរជាជាងទុកឲ្យគាត់នៅរស់ ។
[៤៣]ប្រសិនបើ ដៃនាំអ្នកឲ្យប្រព្រឹត្តអំពើបាប ចូរកាត់បោលទៅ បើអ្នកចូលទៅក្នុងជីវិតមានដៃតែម្ខាង
ប្រសើរជាងមានដៃពីរ ហើយត្រូវធ្លាក់ទៅក្នុងនរកដែលមានភ្លើងមិនចេះរលត់ ។ [៤៥]ប្រសិនបើ ជើងនាំ
អ្នកឲ្យប្រព្រឹត្តអំពើបាប ចូរកាត់បោលទៅ បើអ្នកចូលទៅក្នុងជីវិត មានតែជើងមួយ នោះប្រសើរជាង
មានជើងពីរ ហើយត្រូវគេបោះទៅក្នុងនរក ។ [៤៧]ប្រសិនបើ ភ្នែកនាំអ្នកឲ្យប្រព្រឹត្តអំពើបាប ចូរខ្វេះ
ចេញទៅ បើអ្នកចូលទៅក្នុងព្រះរាជ្យព្រះជាម្ចាស់ មានតែភ្នែកម្ខាងនោះ ប្រសើរជាងមានភ្នែកពីរ
ហើយត្រូវគេបោះទៅក្នុងនរក [៤៨]ជាកន្លែងដែលមានដង្កូវមិនចេះងាប់ មានភ្លើងមិនចេះរលត់» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២៧ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម ១ យហ ៤,១៦

**អាលេលូយ៉ា! អាលេលូយ៉ា!** ប្រសិនបើយើងស្ថិតនៅជាប់ក្នុងសេចក្តីស្រឡាញ់
យើងនឹងស្ថិតនៅជាប់ក្នុងព្រះជាម្ចាស់! ព្រះអម្ចាស់ជាសេចក្តីស្រឡាញ់ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** ១០,២-១៦ (ឬយ៉ាងខ្លី ១០,២-១២)

២មានថ្ងៃមួយ ពួកខាងគណៈផារីស៊ីចូលមកជិតព្រះយេស៊ូ ក្នុងគោលបំណងល្បងលមើលព្រះអង្គ ។
គេទូលសួរព្រះអង្គថា៖ «តើស្វាមីមានសិទ្ធិលែងភរិយាបានឬទេ?» ។ ៣ព្រះអង្គមានព្រះបន្ទូលថា៖
«តើលោកម៉ូសេបង្គាប់អ្នករាល់គ្នាឲ្យធ្វើអ្វី?» ។ ៤គេទូលតបថា៖ «លោកម៉ូសេអនុញ្ញាតឲ្យស្វាមីធ្វើ
លិខិតលែងលះភរិយាបាន» ។ ៥ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «លោកម៉ូសេចែងវិន័យនេះឲ្យអ្នក
រាល់គ្នា ព្រោះតែអ្នករាល់គ្នាមានចិត្តរឹងរូស ។ ៦ប៉ុន្តែ កាលដើមដំបូង នៅពេលដែលព្រះជាម្ចាស់បង្កើត
ពិភពលោក ព្រះអង្គបង្កើតមនុស្សមកជាបុរស ជាស្ត្រី ។ ៧ហេតុនេះហើយ បានជាបុរសត្រូវចាកចេញពី
ឪពុកម្ដាយ ទៅរួមរស់ជាមួយភរិយារបស់ខ្លួន ៨ហើយអ្នកទាំងពីរត្រឡប់ទៅជារូបកាយតែមួយ គេមិន
មែនជាបុគ្គលពីរនាក់ទៀតទេ គឺជារូបកាយតែមួយវិញ ។ ៩ដូច្នេះ មនុស្សមិនត្រូវបំបាក់បំបែកគូស្រករ
ដែលព្រះជាម្ចាស់បានផ្សំផ្គុំនោះឡើយ» ។ ១០ពេលទៅដល់ផ្ទះ ក្រុមសាវ័កទូលសួរព្រះយេស៊ូអំពីរឿងនេះ
ម្ដងទៀត ។ ១១ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «ប្រសិនបើ ស្វាមីណាលែងភរិយា ហើយទៅរៀបការ
នឹងស្ត្រីម្នាក់ទៀត ស្វាមីនោះបានផិតក្បត់ភរិយារបស់ខ្លួន ។ ១២រីឯ ភរិយាណាដែលលែងស្វាមី ហើយទៅ
រៀបការនឹងបុរសម្នាក់ទៀត ស្ត្រីនោះក៏បានប្រព្រឹត្តអំពើផិតក្បត់ដែរ» ។

១៣មានមនុស្សម្នានាំក្មេងតូចៗមកឲ្យព្រះយេស៊ូដាក់ព្រះហស្តលើពួកវា ប៉ុន្តែ ក្រុមសាវ័កស្ដីបន្ទោស
អ្នកទាំងនោះ ។ ១៤កាលព្រះយេស៊ូឃើញដូច្នោះ ព្រះអង្គទាស់ព្រះហឫទ័យណាស់ ហើយមានព្រះបន្ទូល
ថា៖ «ទុកឲ្យក្មេងៗមករកខ្ញុំចុះ កុំឃាត់ពួកវាឡើយ ដ្បិតមានតែអ្នកមានចិត្តដូចក្មេងៗទាំងនេះ
ប៉ុណ្ណោះ ដែលចូលក្នុងព្រះរាជ្យព្រះជាម្ចាស់បាន ។ ១៥ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នកណាមិន
ព្រមទទួលព្រះរាជ្យព្រះជាម្ចាស់ ដូចក្មេងតូចមួយទេ អ្នកនោះមិនអាចចូលក្នុងព្រះរាជ្យព្រះអង្គបាន
ឡើយ» ។ ១៦បន្ទាប់មក ព្រះអង្គឱបក្មេងទាំងនោះ រួចប្រទានពរឲ្យពួកវាដោយដាក់ព្រះហស្តពីលើ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២៨ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **មថ ៥,៣**

**អាលេលូយ៉ា! អាលេលូយ៉ា!** អ្នកដែលដាក់ចិត្តជាអ្នកក្រខ្សត់ ពិតជាបានសុភមង្គល
ដ្បិតគេទទួលព្រះរាជ្យនៃស្ថានបរមសុខហើយ! ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** **១០,១៧-៣០ (ឬយ៉ាងខ្លី ១០,១៧-២៧)**

[១៧]ព្រះយេស៊ូកំពុងចេញដំណើរទៅ មានបុរសម្នាក់រត់មកដល់ លុតជង្គង់ចុះនៅមុខព្រះអង្គទូលថា៖
«លោកគ្រូដ៏សប្បុរសអើយ! តើខ្ញុំត្រូវធ្វើអ្វីដើម្បីឲ្យបានទទួលជីវិតអស់កល្បជានិច្ចទុកជាមត៌ក?» ។
[១៨]ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «ហេតុអ្វីបានជាអ្នកថា ខ្ញុំសប្បុរសដូច្នេះ? ក្រៅពីព្រះជាម្ចាស់មួយ
ព្រះអង្គ គ្មាននរណាម្នាក់សប្បុរសឡើយ ។ [១៩]អ្នកស្គាល់វិន័យស្រាប់ហើយថា "កុំសម្លាប់មនុស្ស កុំ
ប្រព្រឹត្តអំពើផិតក្បត់ កុំលួចទ្រព្យសម្បត្តិគេ កុំនិយាយកុហកធ្វើឲ្យគេមានទោស កុំកែប្រវ័ញ្ចយក
សម្បត្តិនរណាឲ្យសោះ ចូរគោរពមាតាបិតា"» ។ [២០]បុរសនោះទូលព្រះអង្គថា៖ «លោកគ្រូអើយ! ខ្ញុំ
បានប្រតិបត្តិតាមវិន័យទាំងនេះតាំងពីក្មេងមក» ។ [២១]ព្រះយេស៊ូទតមើលទៅគាត់ ហើយមានព្រះហឫទ័
យស្រឡាញ់គាត់ ព្រះអង្គមានព្រះបន្ទូលថា៖ «នៅខ្វះកិច្ចការមួយទៀតដែលអ្នកមិនទាន់ធ្វើ គឺអញ្ជើញ
ទៅលក់អ្វីៗទាំងអស់ដែលអ្នកមាន រួចចែកឲ្យជនក្រីក្រទៅ! ធ្វើដូច្នេះទើបអ្នកមានសម្បត្តិសួគ៌ បន្ទាប់
មកសឹមអញ្ជើញមកតាមខ្ញុំ» ។ [២២]កាលបុរសនោះឮដូច្នេះ គាត់ធ្លាក់ទឹកមុខស្រពោន ហើយវិលត្រឡប់
ទៅវិញទាំងព្រួយចិត្ត ដ្បិតគាត់មានទ្រព្យសម្បត្តិស្ដុកស្ដម្ភណាស់ ។

[២៣]ព្រះយេស៊ូទតមើលជុំវិញ រួចមានព្រះបន្ទូលទៅក្រុមសាវ័កថា៖ «អ្នកមានមិនងាយចូលទៅក្នុង
ព្រះរាជ្យព្រះជាម្ចាស់បានទេ» ។ [២៤]ក្រុមសាវ័កងឿងឆ្ងល់នឹងព្រះបន្ទូលរបស់ព្រះអង្គជាខ្លាំង ។ ព្រះ
យេស៊ូមានព្រះបន្ទូលទៅគេទៀតថា៖ «កូនចៅអើយ! ព្រះរាជ្យព្រះជាម្ចាស់ ពិបាកចូលណាស់! [២៥]សត្វ
អូដ្ឋចូលតាមប្រហោងម្ជុល ងាយជាងអ្នកមានចូលក្នុងព្រះរាជ្យព្រះជាម្ចាស់» ។ [២៦]ក្រុមសាវ័ករឹតតែឆ្ងល់
ថែមទៀត ហើយនិយាយគ្នាថា៖ «បើដូច្នេះ តើអ្នកណាអាចទទួលការសង្គ្រោះបាន?» ។ [២៧]ព្រះយេស៊ូ
ទតមើលគេ រួចមានព្រះបន្ទូលថា៖ «ការនេះមនុស្សធ្វើពុំកើតទេ តែព្រះជាម្ចាស់ធ្វើកើត ដ្បិតព្រះអង្គ
ធ្វើគ្រប់ការទាំងអស់បាន» ។

[២៨]លោកសិលាទូលព្រះអង្គថា៖ «ព្រះអង្គទតឃើញស្រាប់ហើយថា យើងខ្ញុំបានលះបង់ចោលអ្វីៗ

ទាំងអស់ ហើយយើងខ្ញុំបានមកតាមព្រះអង្គ» ។ [២៩]ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នក
រាល់គ្នាដឹងច្បាស់ថា អ្នកណាលះបង់ផ្ទះសម្បែង បងប្អូនប្រុសស្រី ឪពុកម្ដាយ កូន ឬស្រែចំការ ព្រោះតែ
ខ្ញុំ និងព្រោះតែដំណឹងល្អ [៣០]អ្នកនោះនឹងទទួលមួយជាមួយរយ ក្នុងពេលឥឡូវនេះ គឺផ្ទះសម្បែង បងប្អូន
ប្រុសស្រី ម្ដាយ កូន និងស្រែចំការ ព្រមទាំងទទួលការបៀតបៀន ហើយក៏នឹងមានជីវិតអស់កល្បជានិច្ច
នៅលោកខាងមុខ ថែមទៀតផង» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ២៩ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** មក ១០,៤៥

**អាលេលូយ៉ា! អាលេលូយ៉ា!** បុត្រមនុស្សមកក្នុងពិភពលោកនេះ ដើម្បីបម្រើមនុស្ស
ព្រមទាំងបូជាជីវិត និងលោះមនុស្សទាំងអស់ផង ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** ១០,៣៥-៤៥ (ឬយ៉ាងខ្លី ១០,៤២-៤៥)

[៣៥]លោកយ៉ាកុបនិងលោកយ៉ូហាន ជាកូនលោកសេបេដេ ចូលមកគាល់ព្រះយេស៊ូហើយទូលថា៖
«ព្រះគ្រូ! សូមមេត្តាយល់ព្រមតាមពាក្យសុំរបស់យើងខ្ញុំផង» ។ [៣៦]ព្រះយេស៊ូមានព្រះបន្ទូលសួរគេថា៖
«តើអ្នកទាំងពីរចង់ឲ្យខ្ញុំធ្វើអ្វី?» ។ [៣៧]គេទូលព្រះអង្គថា៖ «ពេលព្រះគ្រូគ្រងរាជ្យប្រកបដោយសិរីរុង
រឿង សូមប្រទានឲ្យយើងខ្ញុំបានអង្គុយអមព្រះគ្រូផង គឺម្នាក់នៅខាងស្ដាំ ម្នាក់នៅខាងឆ្វេង» ។ [៣៨]ព្រះ
យេស៊ូមានព្រះបន្ទូលថា៖ «អ្នកទាំងពីរមិនដឹងថា ខ្លួនសុំអ្វីឡើយ តើអ្នកអាចទទួលពែងដែលខ្ញុំត្រូវទទួល
នោះបានឬទេ? តើអ្នកអាចទទួលពិធីជ្រមុជដែលខ្ញុំត្រូវទទួលបានឬទេ?» ។ [៣៩]គេទូលព្រះអង្គថា៖
«យើងខ្ញុំអាចទទួលបាន» ។ ព្រះយេស៊ូមានព្រះបន្ទូលថា៖ «អ្នកនឹងទទួលពែងដែលខ្ញុំត្រូវទទួល និង
ទទួលពិធីជ្រមុជដែលខ្ញុំត្រូវទទួលបានមែន [៤០]ចំណែកឯអង្គុយនៅខាងស្ដាំ ឬខាងឆ្វេងខ្ញុំ ខ្ញុំមិនអាច
សម្រេចបានឡើយ ព្រោះកន្លែងនោះបម្រុងទុកសម្រាប់តែអ្នកដែលព្រះជាម្ចាស់បានសម្រេចឲ្យប៉ុណ្ណោះ»
។ [៤១]កាលសាវ័កដប់រូបទៀតបានឮដូច្នោះ គេទាស់ចិត្តនឹងលោកយ៉ាកុបនិងលោកយ៉ូហានជាខ្លាំង ។

[៤២]ព្រះយេស៊ូត្រាស់ហៅសាវ័កទាំងអស់មក ហើយមានព្រះបន្ទូលថា៖ «អ្នករាល់គ្នាដឹងស្រាប់ហើយ
អ្នកដែលគេចាត់ទុកជាមេគ្រប់គ្រងស្រុក តែងជិះជាន់ប្រជារាស្ត្ររបស់ខ្លួន រីឯអ្នកធំតែងតែប្រើអំណាច
ខ្លួនលើប្រជារាស្ត្រ ។ [៤៣]ក្នុងចំណោមអ្នករាល់គ្នាមិនមែនដូច្នោះទេ ។ ផ្ទុយទៅវិញ ក្នុងចំណោមអ្នករាល់
គ្នា បើមានម្នាក់ចង់ធ្វើធំជាងគេ ត្រូវឲ្យអ្នកនោះបម្រើអ្នករាល់គ្នា ។ [៤៤]ក្នុងចំណោមអ្នករាល់គ្នា បើមាន
ម្នាក់ចង់ធ្វើមេគេ ត្រូវធ្វើជាទាសកររបស់គេគ្រប់គ្នាសិន [៤៥]ដ្បិតបុត្រមនុស្សមកក្នុងពិភពលោកនេះ មិន
មែនដើម្បីឲ្យគេបម្រើលោកឡើយ គឺលោកមកបម្រើគេវិញ ព្រមទាំងបូជាជីវិតដើម្បីលោះមនុស្សទាំង
អស់ផង» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៣០ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម លក ១,៦៨.៧៩

**អាលេលូយ៉ា! អាលេលូយ៉ា!** សូមលើកតម្កើងព្រះអម្ចាស់ជាព្រះរបស់យើង
ព្រះអង្គប្រោសឲ្យពន្លឺបំភ្លឺអស់អ្នកដែលរស់នៅភាពងងឹត ។ **អាលេលូយ៉ា!**

✠ **សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** ១០,៤៦-៥២

[៤៦]ព្រះយេស៊ូយាងចេញពីទីក្រុងយេរីខូជាមួយក្រុមសាវ័ក និងបណ្ដាជនដ៏ច្រើនកុះករ មានមនុស្ស
ខ្វាក់ម្នាក់ ឈ្មោះបារទីមេ ជាកូនរបស់លោកទីមេ អង្គុយសុំទាននៅក្បែរផ្លូវ ។ [៤៧]កាលគាត់ឮថា ព្រះ
យេស៊ូជាអ្នកភូមិណាសារ៉ែតយាងតាមនោះ គាត់ក៏ស្រែកឡើងថា៖ «ឱព្រះយេស៊ូជាព្រះរាជវង្សព្រះបាទ
ដាវីឌអើយ! សូមអាណិតមេត្តាទូលបង្គំផង» ។ [៤៨]មនុស្សជាច្រើនគំរាមគាត់ឲ្យនៅស្ងៀម ប៉ុន្តែ គាត់
ស្រែករឹតតែខ្លាំងឡើងៗ ថា៖ «ឱព្រះរាជវង្សព្រះបាទដាវីឌអើយ! សូមអាណិតមេត្តាទូលបង្គំផង!» ។
[៤៩]ព្រះយេស៊ូក៏ឈប់ ហើយមានព្រះបន្ទូលថា៖ «សុំហៅគាត់មក» ។ គេហៅមនុស្សខ្វាក់មកដោយ
ពោលថា៖ «កុំអស់សង្ឃឹម ចូរក្រោកឡើង លោកហៅអ្នក» ។ [៥០]គាត់ក៏បោះអាវធំចោល ស្ទុះក្រោក
ឡើងតម្រង់ទៅរកព្រះយេស៊ូ ។ [៥១]ព្រះយេស៊ូមានព្រះបន្ទូលសួរគាត់ថា៖ «តើអ្នកចង់ឲ្យខ្ញុំធ្វើអ្វីសម្រាប់
អ្នក?» ។ អ្នកខ្វាក់ទូលព្រះអង្គថា៖ «ព្រះគ្រូ! សូមប្រោសឲ្យភ្នែកទូលបង្គំបានភ្លឺផង» ។ [៥២]ព្រះយេស៊ូ
មានព្រះបន្ទូលទៅគាត់ថា៖ «សុំអញ្ជើញទៅចុះ! ជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ!» ។ រំពេច
នោះ គាត់មើលឃើញភ្លាម ហើយដើរតាមផ្លូវជាមួយព្រះយេស៊ូទៅ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៣១ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** **តាម ១ យហ ៤,៨.៧**

**អាលេលូយ៉ា! អាលេលូយ៉ា!** ព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់ ។ អ្នកដែលមានចិត្តស្រឡាញ់កើតមកពីព្រះជាម្ចាស់ ហើយស្គាល់ព្រះអង្គផង ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** **១២,២៨-៣៤**

[២៨]មានធម្មាចារ្យម្នាក់ចូលទៅជិតព្រះយេស៊ូ ហើយទូលព្រះអង្គថា៖ «ក្នុងបណ្ដាវិន័យទាំងអស់ តើ
វិន័យណាសំខាន់ជាងគេ?» ។ [២៩]ព្រះយេស៊ូមានព្រះបន្ទូលឆ្លើយថា៖ «នេះជាវិន័យទីមួយ៖ “អ៊ីស្រា
អែលអើយ! ចូរស្ដាប់! មានតែព្រះអម្ចាស់ជាព្រះរបស់យើងមួយព្រះអង្គគត់ ដែលពិតជាព្រះអម្ចាស់ ។
[៣០]ត្រូវស្រឡាញ់ព្រះអម្ចាស់ ជាព្រះរបស់អ្នកឲ្យអស់ពីចិត្តគំនិត អស់ពីស្មារតី អស់ពីប្រាជ្ញា និងអស់ពី
កម្លាំងកាយ” ។ [៣១]រីឯវិន័យទីពីរមានចែងថា “ត្រូវស្រឡាញ់បងប្អូនឯទៀតៗ ឲ្យបានដូចស្រឡាញ់ខ្លួន
ឯង” ។ គ្មានវិន័យណាសំខាន់ជាងវិន័យទាំងពីរនេះទេ» ។ [៣២]ធម្មាចារ្យនោះទូលព្រះអង្គថា៖ «លោក
គ្រូ! លោកមានប្រសាសន៍ត្រូវណាស់ ហើយពិតផង ។ មានព្រះជាម្ចាស់តែមួយព្រះអង្គគត់ ក្រៅពីព្រះ
អង្គ គ្មានព្រះឯណាទៀតឡើយ ។ [៣៣]បើយើងស្រឡាញ់ព្រះអង្គអស់ពីចិត្តគំនិត អស់ពីប្រាជ្ញា និងអស់ពី
កម្លាំងកាយ ហើយបើយើងស្រឡាញ់បងប្អូនឯទៀតៗ ឲ្យបានដូចស្រឡាញ់ខ្លួនឯង នោះប្រសើរជាង
ថ្វាយតង្វាយ និងថ្វាយយញ្ញបូជាទៅទៀត» ។ [៣៤]កាលព្រះយេស៊ូឮគាត់ឆ្លើយ ដោយប្រាជ្ញាវាងវៃដូច្នេះ
ព្រះអង្គមានព្រះបន្ទូលថា៖ «អ្នកនៅមិនឆ្ងាយពីព្រះរាជ្យរបស់ព្រះជាម្ចាស់ទេ» ។ បន្ទាប់មក គ្មាន
នរណាហ៊ានដេញដោលសួរព្រះអង្គទៀតឡើយ ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៣២ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** មថ ៥,៣

**អាលេលូយ៉ា! អាលេលូយ៉ា!** អ្នកដាក់ចិត្តជាអ្នកក្រខ្សត់ ពិតជាមានសុភមង្គល
ដ្បិតអ្នកទាំងនោះបានទទួលព្រះរាជ្យនៃស្ថានបរមសុខហើយ! ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** ១២,៣៨-៤៤ (ឬយ៉ាងខ្លី ១២,៤១-៤៤)

[៣៨]ព្រះយេស៊ូមានព្រះបន្ទូលបង្រៀនបណ្ដាជនថា៖ «ចូរប្រយ័ត្ននឹងពួកធម្មាចារ្យឲ្យមែនទែន អ្នក
ទាំងនោះចូលចិត្តពាក់អាវវែង ដើរចុះដើរឡើង ហើយចូលចិត្តឲ្យគេឱនកាយគោរពនៅតាមផ្សារ
[៣៩]ព្រមទាំងរើសកន្លែងអង្គុយមុខគេក្នុងធម្មសាលា និងចូលចិត្តកន្លែងកិត្តិយសនៅពេលជប់លៀង ។
[៤០]គេតែងនាំគ្នាឆបោកយកទ្រព្យសម្បត្តិរបស់ស្ត្រីមេម៉ាយ ដោយធ្វើឫកជាសូត្រធម៌យ៉ាងយូរ ។ អ្នកទាំង
នេះនឹងត្រូវទទួលទោសយ៉ាងធ្ងន់បំផុត» ។

[៤១]ព្រះយេស៊ូគង់នៅមុខហិបតង្វាយ ព្រះអង្គទតមើលរបៀបដែលបណ្ដាជនយកប្រាក់ មកដាក់ក្នុង
ហិបនោះ ។ អ្នកមានច្រើននាក់ដាក់ប្រាក់ជាច្រើន ។ [៤២]មានស្ត្រីមេម៉ាយក្រីក្រម្នាក់មកដល់ នាងយក
ប្រាក់ពីរសេនជាចំនួនដ៏តិចតួចបំផុត ដាក់ក្នុងហិបតង្វាយនោះដែរ ។ [៤៣]ព្រះយេស៊ូត្រាស់ហៅក្រុមសាវ័ក
មក ហើយមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាបានដឹងច្បាស់ថា ស្ត្រីមេម៉ាយក្រីក្រនេះ
ដាក់ប្រាក់ក្នុងហិបច្រើនជាងគេទាំងអស់ [៤៤]ដ្បិតអ្នកទាំងនោះ យកប្រាក់សំណល់របស់ខ្លួនមកដាក់ ។ រីឯ
ស្ត្រីមេម៉ាយនេះវិញ ទោះបីនាងក្រីក្រយ៉ាងណាក៏ដោយ ក៏នាងបានយកប្រាក់ដែលនាងត្រូវការជាចាំ
បាច់ មកដាក់ដែរ គឺប្រាក់ទាំងប៉ុន្មានដែលនាងមានសម្រាប់ចិញ្ចឹមជីវិត» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៣៣ ក្នុងរដូវធម្មតា ឆ្នាំ ខ

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** លក ២១,៣៦

**អាលេលូយ៉ា! អាលេលូយ៉ា!** ចូរប្រុងស្មារតីឡើង! ចូរអង្វរព្រះជាម្ចាស់គ្រប់ពេលវេលា ដូច្នេះ អ្នករាល់គ្នាសមនឹងឈរនៅចំពោះព្រះភក្ត្រនៃបុត្រមនុស្ស ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត ម៉ាកុស** ១៣,២៤-៣២

ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ក្រុមសាវ័ក អំពីពេលដែលព្រះអង្គនឹងយាងមកវិញ ។ ព្រះអង្គមាន
ព្រះបន្ទូលថា៖ [២៤]«នៅគ្រានោះ កើតទុក្ខវេទនាយ៉ាងខ្លាំង ។ ក្រោយពីទុក្ខវេទនានេះកន្លងផុតទៅ ព្រះ
អាទិត្យនឹងបាត់រស្មី ព្រះច័ន្ទលែងមានពន្លឺទៀតហើយ [២៥]រីឯផ្កាយទាំងឡាយនឹងធ្លាក់ចុះពីលើមេឃ
អំណាចនានានៅលើមេឃនឹងត្រូវកក្រើករំពើក ។ [២៦]ពេលនោះ គេនឹងឃើញបុត្រមនុស្សយាងមកក្នុង
ពពក ប្រកបដោយឫទ្ធានុភាពដ៏ខ្លាំងក្លា និងដោយសិរីរុងរឿង ។ [២៧]លោកនឹងចាត់ពួកទេវទូតរបស់
លោកឲ្យទៅទិសទាំងបួន ចាប់តាំងពីជើងមេឃម្ខាង ទៅជើងមេឃម្ខាងទៀត ដើម្បីប្រមូលពួកអ្នក
ដែលព្រះជាម្ចាស់បានជ្រើសរើស ។

[២៨]ចូរអ្នករាល់គ្នាយកពាក្យប្រស្នាស្ដីអំពីដើមស្វាយទៅរិះគិតចុះ ។ កាលណាមែករបស់វាមានស្លឹក
លាស់ខៀវខ្ចី អ្នករាល់គ្នាដឹងថា រដូវប្រាំងជិតមកដល់ហើយ ។ [២៩]ដូច្នេះ កាលណាអ្នករាល់គ្នាឃើញព្រឹត្តិ
ការណ៍ទាំងនោះកើតឡើង ត្រូវដឹងថា បុត្រមនុស្សក៏ជិតមកដល់ហើយដែរ គឺលោកមកជិតបង្កើយ
ហើយ ។ [៣០]ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា ហេតុការណ៍ទាំងនោះនឹងកើតឡើង នៅពេលដែល
មនុស្សជំនាន់នេះមានជីវិតនៅឡើយ ។ [៣១]ផ្ទៃមេឃនិងផែនដីនឹងរលាយបាត់ទៅ តែពាក្យដែលខ្ញុំនិយាយ
មិនរលាយបាត់ទេ ។ [៣២]រីឯថ្ងៃកំណត់និងពេលវេលា គ្មាននរណាដឹងឡើយ ទោះបីទេវទូតនៅស្ថានបរម
សុខ ឬព្រះបុត្រាក៏ពុំជ្រាបដែរ មានតែព្រះបិតាប៉ុណ្ណោះដែលជ្រាប» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។

# ថ្ងៃអាទិត្យទី ៣៤ ក្នុងរដូវធម្មតា ឆ្នាំ ខ

# ព្រះគ្រីស្តជាព្រះមហាក្សត្រនៃពិភពលោក

**ពិធីអបអរសាទរព្រះគម្ពីរដំណឹងល្អ** តាម មក ១១,១០

**អាលេលូយ៉ា! អាលេលូយ៉ា!** សូមលើកតម្កើងព្រះរាជ្យរបស់ព្រះបាទដាវីឌ
ជាបិតារបស់យើង! ជាព្រះរាជ្យនៃជំនាន់ថ្មី ។ សូមលើកតម្កើងអ្នកដែលមក
ក្នុងនាមនៃព្រះអម្ចាស់ ។ **អាលេលូយ៉ា!**

**✠ សូមថ្លែងព្រះគម្ពីរដំណឹងល្អតាមសន្ត យ៉ូហាន** ១៨,៣៣-៣៧

៣៣នៅពេលនោះ លោកពីឡាតកាត់ក្តីព្រះយេស៊ូ ។ លោកសួរព្រះយេស៊ូថា៖ «តើអ្នកជាស្តេចរបស់
ជនជាតិយូដាមែនឬ?» ។ ៣៤ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «លោកមានប្រសាសន៍ដូច្នេះ តើមកពី
គំនិតរបស់លោកផ្ទាល់ ឬមានអ្នកផ្សេងទៀតជំរាបលោក?» ។ ៣៥លោកពីឡាតតបវិញថា៖ «ខ្ញុំមិន
មែនជាជនជាតិយូដាទេ! គឺជនជាតិរបស់អ្នក និងពួកនាយកបូជាចារ្យទេតើ ដែលបានបញ្ជូនអ្នកមក
ខ្ញុំ ។ តើអ្នកបានធ្វើអ្វី?» ។ ៣៦ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ «រាជ្យរបស់ខ្ញុំមិនមែននៅក្នុងលោក
នេះទេ ។ ប្រសិនបើរាជ្យរបស់ខ្ញុំនៅក្នុងលោកនេះមែន ពួកបម្រើរបស់ខ្ញុំមុខជានាំគ្នាតយុទ្ធ មិនឲ្យគេ
បញ្ជូនខ្ញុំទៅក្នុងកណ្តាប់ដៃរបស់សាសន៍យូដាបានឡើយ ។ ប៉ុន្តែ រាជ្យរបស់ខ្ញុំ មិនមែននៅលោកនេះទេ»
។ ៣៧លោកពីឡាតទូលសួរព្រះអង្គថា៖ «បើដូច្នេះ តើអ្នកជាស្តេចមែនឬ?» ។ ព្រះយេស៊ូមានព្រះ
បន្ទូលតបថា៖ «លោកទេតើដែលមានប្រសាសន៍ថា ខ្ញុំជាស្តេច ។ ខ្ញុំកើតមក ហើយខ្ញុំក៏មកក្នុងលោក
នេះ ដើម្បីផ្តល់សក្ខីភាពអំពីសេចក្តីពិត ។ អ្នកណាកើតពីសេចក្តីពិត អ្នកនោះនឹងស្តាប់សំឡេងខ្ញុំ» ។

— នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់ ។